# Khmer: Unlocked Literal Bible for យ៉ូហាន
Formatted for Translators

©2022 Wycliffe Associates
Released under a Creative Commons Attribution-ShareAlike 4.0 International License.

Bible Text: The English Unlocked Literal Bible (ULB)
©2017 Wycliffe Associates
Available at https://bibleineverylanguage.org/translations
The English Unlocked Literal Bible is based on the unfoldingWord® Literal Text, CC BY-SA 4.0. The original work of the unfoldingWord® Literal Text is available at https://unfoldingword.bible/ult/.
The ULB is licensed under the Creative Commons Attribution-ShareAlike 4.0 International License.

Notes: English ULB Translation Notes
©2017 Wycliffe Associates
Available at https://bibleineverylanguage.org/translations
The English ULB Translation Notes is based on the unfoldingWord translationNotes, under CC BY-SA 4.0. The original unfoldingWord work is available at https://unfoldingword.bible/utn.
The ULB Notes is licensed under the Creative Commons Attribution-ShareAlike 4.0 International License.

To view a copy of the CC BY-SA 4.0 license visit http://creativecommons.org/licenses/by-sa/4.0/

Below is a human-readable summary of (and not a substitute for) the license.
You are free to:

Share — copy and redistribute the material in any medium or format. Adapt — remix, transform, and build upon the material for any purpose, even commercially.

The licensor cannot revoke these freedoms as long as you follow the license terms.
Under the following conditions:

Attribution — You must attribute the work as follows: "Original work available at https://BibleInEveryLanguage.org." Attribution statements in derivative works should not in any way suggest that we endorse you or your use of this work. ShareAlike — If you remix, transform, or build upon the material, you must distribute your contributions under the same license as the original. No additional restrictions — You may not apply legal terms or technological measures that legally restrict others from doing anything the license permits.

Notices:
You do not have to comply with the license for elements of the material in the public domain or where your use is permitted by an applicable exception or limitation.
No warranties are given. The license may not give you all of the permissions necessary for your intended use. For example, other rights such as publicity, privacy, or moral rights may limit how you use the material.

# យ៉ូហាន

1 [1]កាលដើមដំបូងឡើយមានព្រះបន្ទូល ហើយព្រះបន្ទូលនៅជាមួយព្រះជាម្ចាស់ ហើយព្រះបន្ទូលគឺជាព្រះជាម្ចាស់។
[2]ព្រះអង្គនេះហើយនៅជាមួយព្រះជាម្ចាស់តាំងពីដំបូង។[3]អ្វីៗទាំងអស់ត្រូវបានបង្កើតឡើងដោយសារព្រះអង្គ
ហើយគ្មានអ្វីដែលបានកើតមកដោយព្រះអង្គមិនបានបង្កើតឡើយ។
[4]នៅក្នុងព្រះអង្គមានជីវិត ហើយជីវិតនោះគឺជាពន្លឺនៃមនុស្សលោកគ្រប់គ្នា។[5]ពន្លឺបំភ្លឺនៅក្នុងទីងងឹត ហើយទីងងឹតមិនអាចយកឈ្នះពន្លឺបានទេ។
[6]មានបុរសម្នាក់ដែលព្រះជាម្ចាស់បានចាត់មក គាត់ឈ្មោះថាលោកយ៉ូហាន។[7]គាត់បានមកក្នុងនាមជាសាក្សី ដើម្បីធ្វើបន្ទាល់អំពីពន្លឺ
ដើម្បីឲ្យមនុស្សគ្រប់គ្នាបានជឿតាមរយៈគាត់។[8]លោកយ៉ូហានមិនមែនជាពន្លឺទេ ប៉ុន្តែ គាត់បានមក ដើម្បីធ្វើបន្ទាល់អំពីពន្លឺវិញ។
[9]ព្រះអង្គជាពន្លឺដ៏ពិត ដែលបានយាងមកលើផែនដី ដើម្បីផ្តល់ពន្លឺដល់មនុស្សគ្រប់គ្នា។
[10]ព្រះអង្គបានយាងមកនៅលោកីយ៍នេះ ហើយលោកីយ៍ត្រូវបានបង្កើតឡើងដោយសារព្រះអង្គ ហើយលោកីយ៍មិនស្គាល់ព្រះអង្គទេ។[11]ព្រះអង្គបានយាងមកលោកីយ៍នេះ
ប៉ុន្តែ លោកីយ៍នេះ មិនទទួលព្រះអង្គទេ។
[12]ប៉ុន្តែ មានមនុស្សជាច្រើនបានទទួលព្រះអង្គ គឺជាអ្នកដែលជឿលើព្រះនាមព្រះអង្គ ទ្រង់បានប្រទានសិទ្ធិឲ្យត្រឡប់ទៅជាបុត្ររបស់ព្រះជាម្ចាស់។[13]ទាំងនេះ
មិនមែនកើតឡើងពីឈាម ឬពីបំណងខាងសាច់ឈាម ឬពីបំណងរបស់មនុស្សទេ ប៉ុន្តែ ជាព្រះហឫទ័យរបស់ព្រះជាម្ចាស់វិញ។
[14]ព្រះបន្ទូលបានត្រឡប់ទៅជាសាច់ឈាម ហើយរស់នៅក្នុងចំណោមយើង។ យើងបានឃើញសិរីល្អរបស់ព្រះអង្គ ជាសិរីល្អរបស់ព្រះតែមួយអង្គគត់ដែលមកពីព្រះបិតា
ពេញដោយព្រះគុណ និងសេចក្តីពិត។[15]លោកយ៉ូហានបានធ្វើបន្ទាល់អំពីព្រះអង្គ ហើយបានស្រែកឡើង ហើយនិយាយថា៖ «នេះគឺជាព្រះអង្គដែលខ្ញុំបានប្រាប់ថា
ព្រះអង្គដែលយាងមកក្រោយខ្ញុំ ព្រះអង្គធំជាងខ្ញុំ ដ្បិតព្រះអង្គគង់នៅមុនខ្ញុំ»។
[16]ដ្បិត ចេញពីភាពបរិបូរណ៌របស់ព្រះអង្គ យើងបានទទួលគ្រប់ទាំងព្រះគុណថែមហើយថែមទៀត។[17]ដ្បិត ក្រឹត្យវិន័យដែលបានប្រទានមកតាមរយៈលោកម៉ូសេ។
តែព្រះគុណ និងសេចក្តីពិតបានមកតាមរយៈព្រះយេស៊ូគ្រិស្ត។[18]គ្មាននរណាបានឃើញព្រះជាម្ចាស់នៅពេលណាមួយឡើយ។
មានតែព្រះអង្គជាព្រះជាម្ចាស់តែមួយប៉ុណ្ណោះដែលនៅជិតព្រះវរបិតា គឺព្រះអង្គបានសំដែងឲ្យស្គាល់ព្រះជាម្ចាស់។
[19]នេះគឺជាទីបន្ទាល់របស់លោកយ៉ូហាន នៅពេលពួកយូដាចាត់ពួកបូជាចារ្យ និងពួកលេវីទៅឯព្រះអង្គពីក្រុងយេរ៉ូសាឡិម ដើម្បីទូលសួរគាត់ថា៖
«តើគាត់ជានរណា?»[20]គាត់ថ្លែងយ៉ាងងាយ និងមិនបានបដិសេធទេ ប៉ុន្តែ ឆ្លើយថា៖ «ខ្ញុំមិនមែនជាព្រះគ្រិស្តទេ»។[21]ដូច្នេះ គេបានសួរគាត់ទៀតថា «អ៊ីចឹង
តើអ្នកជានរណា?» តើអ្នកជាលោកអេលីយ៉ា?» គាត់ឆ្លើយថា៖ «ខ្ញុំមិនមែនទេ»។ ពួកគេសួរថា៖ «តើអ្នកជាព្យាការី?» គាត់ឆ្លើយថា៖ «មិនមែនទេ»។
[22]បន្ទាប់មក ពួកគេបានសួរគាត់ទៀតថា៖ «តើអ្នកជានរណា អ៊ីចឹង ដើម្បីឲ្យយើងអាចឆ្លើយទៅអស់អ្នកដែលចាត់យើងឲ្យមក? តើអ្នកនិយាយពីខ្លួនអ្នកយ៉ាងដូចម្តេច»?
[23]គាត់ឆ្លើយថា៖ «ខ្ញុំជាសម្លេងមួយ ដែលស្រែកនៅក្នុងទីរហោស្ថានថា៖ «ចូររៀបចំផ្លូវត្រង់ថ្វាយព្រះអម្ចាស់ ដូចព្យាការីអេលីយាបានថ្លែង»។
[24]មានអ្នកខ្លះត្រូវបានពួកគណៈផារីស៊ីចាត់មក[25]ពួកគេសួរគាត់ ហើយនិយាយទៅកាន់គាត់ថា៖ «ម្តេចក៏អ្នកធ្វើពិធីជ្រមុជអ៊ីចឹង ប្រសិនបើ អ្នកមិនមែនជាព្រះគ្រិស្ត
ឬលោកអេលីយា ឬជាព្យាការី?»
[26]លោកយ៉ូហានបានឆ្លើយទៅកាន់ពួកគេថា៖ «ខ្ញុំជ្រមុជជាមួយនឹងទឹក។ ប៉ុន្តែ នៅក្នុងចំណោមអ្នករាល់គ្នាដែលឈរនេះ នឹងមានម្នាក់ដែលអ្នកមិនស្គាល់។
[27]លោកជាម្នាក់ដែលនឹងមកក្រោយខ្ញុំ ហើយខ្ញុំមិនស័ក្តិសមសូម្បីតែស្រាយខ្សែស្បែកជើងព្រះអង្គផង»។[28]ការទាំងនេះបានកើតឡើងនៅក្នុងភូមិបេតថានី
នៅផ្នែកម្ខាងទៀតនៃទន្លេយ័រដាន់ ជាកន្លែងដែលលោកយ៉ូហានធ្វើពិធីជ្រមុជ។
[29]នៅថ្ងៃបន្ទាប់ លោកយ៉ូហានបានឃើញព្រះយេស៊ូយាងមករកគាត់ ហើយគាត់មានប្រសាសន៍ថា «មើល! លោកជាកូនចៀមនៃព្រះដែលដកយកបាបរបស់មនុស្សលោក។
[30]លោកជាម្នាក់ដែលខ្ញុំបាននិយាយ «គឺជាម្នាក់ដែលមកក្រោយខ្ញុំ ធំជាងខ្ញុំ ដ្បិតព្រះអង្គគង់នៅមុនខ្ញុំ»។[31]ខ្ញុំមិនបានស្គាល់ព្រះអង្គទេ
ប៉ុន្តែគឺដូច្នេះហើយដែលព្រះអង្គបានបង្ហាញដល់អ៊ីស្រាអែលថាខ្ញុំបានមកធ្វើពិធីជ្រមុជដោយទឹកប៉ុណ្ណោះ»។
[32]លោកយ៉ូហានបានធ្វើបន្ទាល់ហើយមានប្រសាសន៍ថា៖ «ខ្ញុំបានឃើញព្រះវិញ្ញាណយាងចុះពីស្ថានសួគ៌មក ដូចជាសត្វព្រាប
ហើយសត្វព្រាបនោះបានសណ្ឋិតលើព្រះអង្គ។[33]ខ្ញុំមិនបានស្គាល់ព្រះអង្គទេ ប៉ុន្តែ ព្រះអង្គគឺជាព្រះដែលបានចាត់ខ្ញុំមកជ្រមុជដោយទឹក ទ្រង់មានបន្ទូលមកកាន់ខ្ញុំថា៖
«នៅពេលអ្នកឃើញព្រះវិញ្ញាណសណ្ឋិតលើនរណា ហើយស្ថិតនៅជាមួយអ្នកនោះ អ្នកនោះហើយជាអ្នកដែលធ្វើពិធីជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។
[34]ខ្ញុំបានឃើញទាំងពីរ ហើយបានធ្វើបន្ទាល់ថា នេះគឺជាបុត្រារបស់ព្រះជាម្ចាស់»។
[35]នៅថ្ងៃបន្ទាប់ ជាថ្មីម្តងទៀត ក្នុងការដែលលោកយ៉ូហានឈរជាមួយសិស្សពីរនាក់របស់គាត់[36]ពួកគេបានឃើញព្រះយេស៊ូយាងមកជិត
ហើយលោកយ៉ូហានមានប្រសាសន៍ថា៖ «មើល! កូនចៀមនៃព្រះ»។
[37]សិស្សពីរនាក់របស់គាត់បានឮគាត់ដូច្នេះ ពួកគេក៏ដើរតាមព្រះយេស៊ូទៅ។[38]បន្ទាប់មកបានបែរមក ហើយឃើញពួកគេដើរតាមព្រះអង្គ
ហើយព្រះអង្គមានបន្ទូលទៅកាន់ពួកគេថា៖ «តើអ្នកចង់បានអ្វី?» ពួកគេឆ្លើយថា៖ «រ៉ាប៊ី (ដែលប្រែមានន័យថា លោកគ្រូ)
តើលោកគ្រូស្នាក់នៅឯណា?»[39]ទ្រង់មានបន្ទូលទៅកាន់ពួកគេថា៖ «សូមមកតាមខ្ញុំ នោះអ្នកនឹងឃើញ»។ ដូច្នេះ ពួកគេក៏ទៅ ហើយឃើញកន្លែងដែលព្រះអង្គស្នាក់នៅ
ពួកគេបាននៅជាមួយព្រះអង្គនៅថ្ងៃនោះ ដ្បិតនៅពេលនោះប្រហែលជាម៉ោងដប់។
[40]សិស្សម្នាក់ក្នុងចំណោមសិស្សទាំងពីរបានឮលោកយ៉ូហាននិយាយ ហើយបន្ទាប់មកបានដើរតាមព្រះយេស៊ូ គាត់ឈ្មោះអនទ្រេ ជាបងប្រុសរបស់លោកស៊ីម៉ូនពេត្រុស។
[41]គាត់ជាមនុស្សដំបូងដែលរកបងប្រុសគាត់ផ្ទាល់គឺលោកស៊ីម៉ូន ហើយនិយាយទៅគាត់ថា «យើងបានរកព្រះមេស្ស៊ីឃើញហើយ» (ដែលប្រែថាៈ ព្រះគ្រិស្ត)។
[42]អនទ្រេបាននាំគាត់ទៅជួបព្រះយេស៊ូ ហើយព្រះយេស៊ូបានសម្លឹងមកឯគាត់ ហើយមានបន្ទូលថា «អ្នកជាស៊ីម៉ូនកូនរបស់លោកយ៉ូហាន គេនឹងហៅអ្នកថា៖ កៃផាស់»
(ដែលប្រែថាពេត្រុស)។
[43]នៅថ្ងៃបន្ទាប់ នៅពេលព្រះយេស៊ូចង់ចាកចេញ ដើម្បីទៅឯកាលីឡេវិញ ព្រះអង្គបានជួបលោកភីលីព ហើយមានបន្ទូលទៅគាត់ថា៖ «ចូរមកតាមខ្ញុំ»។
[44]លោកភីលីពមកពីបេតសៃដា ជាក្រុងរបស់លោកអនទ្រេ និងលោកពេត្រុស។[45]លោកភីលីពបានជួបលោកណាថាណែល ហើយនិយាយទៅគាត់ថា៖
«ព្រះដែលលោកម៉ូសេសរសេរនៅក្នុងគម្ពីរក្រឹត្យវិន័យ និងពួកព្យាការីបានសរសេរ យើងបានជួបព្រះអង្គហើយ
គឺព្រះយេស៊ូជាកូនរបស់លោកយ៉ូសែបមកពីស្រុកណាសារ៉ែត»។
[46]លោកណាថាណែលមានប្រសាសន៍ទៅកាន់គាត់ថា៖ «តើមានការល្អណាចេញពីណាសារ៉ែត?» លោកភីលីពឆ្លើយថា៖ «សូមមកតាមខ្ញុំនោះអ្នកនឹងឃើញ»។
[47]ព្រះយេស៊ូបានឃើញលោកណាថាណែលដើរចូលមករកព្រះអង្គ ហើយព្រះអង្គមានបន្ទូលពីគាត់ថា៖ «មើល ឱជនជាតិអ៊ីស្រាអែលដ៏ពិតអើយ
អ្នកគ្មានសេចក្តីកុហកក្នុងខ្លួនឡើយ»។[48]លោកណាថាណែលមានប្រសាសន៍ទៅព្រះអង្គវិញថា៖ «តើលោកអាចស្គាល់ខ្ញុំបានយ៉ាងដូចម្តេច?» ព្រះយេស៊ូឆ្លើយ
ហើយមានបន្ទូលថា៖ «មុនពេលភីលីពហៅអ្នក ខ្ញុំបានឃើញអ្នក នៅពេលដែលអ្នកនៅក្រោមដើមឧទុម្ពររួចហើយ។
[49]លោកណាថាណែលឆ្លើយថា៖ «រ៉ាប៊ី ព្រះអង្គគឺជាព្រះបុត្រានៃព្រះជាម្ចាស់ ព្រះអង្គគឺជាព្រះមហាក្សត្ររបស់អ៊ីស្រាអែល»។[50]ព្រះយេស៊ូឆ្លើយទៅគាត់វិញថា៖
«ដោយសារខ្ញុំបាននិយាយទៅកាន់អ្នកថា៖ «ខ្ញុំបានឃើញអ្នកនៅខាងក្រោមដើមឧទុម្ពរ ទើបអ្នកជឿខ្ញុំមែនទេ? អ្នកនឹងឃើញការដ៏អស្ចារ្យជាងនេះ»។[51]បន្ទាប់មក
ព្រះអង្គមានបន្ទូលថា ប្រាកដណាស់ ខ្ញុំប្រាប់អ្នកជាប្រាកដថា អ្នកនឹងឃើញស្ថានសួគ៌បើកចំហ ហើយឃើញពួកទេវតារបស់ព្រះជាម្ចាស់ចុះឡើងពីលើបុត្រមនុស្ស»។

2 1បីថ្ងៃក្រោយមក មានពិធីមង្គលការមួយនៅភូមិកាណាក្នុងស្រុកកាលីឡេ ហើយមាតារបស់ព្រះយេស៊ូក៏នៅទីនោះដែរ។2ព្រះយេស៊ូ
និងពួកសិស្សរបស់ព្រះអង្គក៏ត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងមង្គលការនោះដែរ។
3នៅពេលអស់ស្រា មាតារបស់ព្រះយេស៊ូទូលទៅកាន់ព្រះអង្គថា៖ «ពួកគេអស់ស្រាហើយ»។4ព្រះយេស៊ូមានបន្ទូលទៅនាងថា៖ «អ្នកម្ដាយអើយ
ហេតុអ្វីបានជាអ្នកម្ដាយមកឯខ្ញុំ? មិនទាន់ដល់ពេលខ្ញុំនៅឡើយទេ»។5មាតារបស់ព្រះអង្គនិយាយទៅកាន់ពួកអ្នកបម្រើថា៖ «អ្វីដែលព្រះអង្គមានបន្ទូលទៅអ្នក
ចូរធ្វើវាចុះ!»។
6ឥឡូវនេះ មានពាងទឹកថ្មប្រាំមួយដែលប្រើសម្រាប់ពិធីជម្រះកាយរបស់សាសន៍យូដា ពាងនីមួយៗអាចផ្ទុកបានពីរទៅបីអម្រែក។7ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖
«ចូរចាក់ទឹកបំពេញពាងទឹកទាំងអស់នេះទៅ»។ ដូច្នេះ ពួកគេក៏ចាក់ទឹកពេញមាត់ពាង។8បន្ទាប់មក ទ្រង់ប្រាប់ទៅពួកអ្នកបម្រើ «ឥឡូវ ចូរយកខ្លះចេញមក
ហើយយកវាទៅឲ្យមេការ»។ ពួកគេក៏ធ្វើតាម។
9មេការបានភ្លក់ទឹកដែលបានត្រឡប់ទៅជាស្រានោះ ប៉ុន្តែ គាត់មិនបានដឹងថាស្រានោះបានមកពីណាទេ (ប៉ុន្តែ អ្នកបម្រើដែលដងទឹកនោះទើបដឹង)។ បន្ទាប់មក
គាត់បានហៅកូនកម្លោះឲ្យមក10ហើយនិយាយទៅគាត់ថា «មនុស្សគ្រប់រូបគេដាក់ស្រាល្អមុន ហើយបន្ទាប់ពីស្រវឹងហើយ ទើបគេដាក់ស្រាមិនសូវល្អវិញ។ ប៉ុន្តែ អ្នកវិញ
អ្នកបានទុកស្រាល្អរហូតមកដល់ពេលនេះ»។
11នេះគឺជាការអស្ចារ្យទីមួយដែលព្រះយេស៊ូបានធ្វើនៅភូមិកាណាស្រុកកាលីឡេ ហើយព្រះអង្គបានបង្ហាញសិរីល្អរបស់ព្រះអង្គ
ហើយពួកសិស្សរបស់ព្រះអង្គបានជឿលើព្រះអង្គ។
12បន្ទាប់ពីនេះ ព្រះយេស៊ូ មាតា និងបងប្អូនរបស់ព្រះអង្គ ព្រមទាំងពួកសិស្សរបស់ព្រះអង្គបានធ្វើដំណើរចុះទៅភូមិកាពើណិម ហើយពួកគេក៏ស្នាក់នៅទីនោះពីរបីថ្ងៃ។
13ឥឡូវ ពិធីបុណ្យចម្លងរបស់សាសន៍យូដាក៏ជិតមកដល់ ហើយព្រះយេស៊ូបានយាងឡើងទៅក្រុងយេរូសាឡិម។14ព្រះអង្គបានជួបជាមួយនឹងពួកអ្នកលក់គោ ចៀម
និងព្រាប ព្រមទាំងពួកអ្នកប្តូរប្រាក់អង្គុយនៅទីនោះ។
15ដូច្នេះ ព្រះអង្គក៏ធ្វើខ្សែតី ហើយបានបណ្តេញពួកគេទាំងអស់ចេញពីព្រះវិហារ រួមទាំងចៀម និងគោផងដែរ។ ព្រះអង្គបានធ្វើឲ្យលុយកាក់របស់ពួកអ្នកប្ដូរប្រាក់ខ្ចាត់ខ្ចាយ
ហើយបានក្រឡាប់តុរបស់ពួកគេចោល។16ចំពោះអ្នកលក់ព្រាបវិញ ព្រះអង្គមានបន្ទូលថា៖ «ចូរយករបស់ទាំងអស់នេះចេញពីទីនេះ។
ឈប់ធ្វើឲ្យដំណាក់របស់ព្រះបិតាយើងក្លាយជាកន្លែងលក់ដូរទៀត។
17ពួកសិស្សរបស់ព្រះអង្គបានចាំសេចក្តីដែលបានចែងថា៖ «ដោយសារតែខ្ញុំស្រឡាញ់ដំណាក់របស់ព្រះអង្គ ធ្វើឲ្យគេសម្លាប់ខ្ញុំ»។18ពេលនោះ
ពួកអាជ្ញាធររបស់យូដាបានឆ្លើយតបវិញ ហើយសួរទៅកាន់ព្រះអង្គថា៖ «តើអ្នកមានទីសម្គាល់អ្វីបង្ហាញយើង នៅពេលដែលអ្នកកំពុងធ្វើការទាំងនេះ?»
19ព្រះយេស៊ូបានឆ្លើយថា៖ «ខ្ញុំនឹងបំផ្លាញព្រះវិហារនេះ ហើយសង់វាឡើងវិញក្នុងរយៈពេលតែបីថ្ងៃប៉ុណ្ណោះ»។
20បន្ទាប់មក ពួកអាជ្ញាធររបស់យូដានិយាយថា៖ «ព្រះវិហារនេះ ត្រូវបានសង់ឡើងអស់រយៈពេលសែសិបប្រាំមួយឆ្នាំ ហើយអ្នកនឹងសង់ឡើងវិញ
ក្នុងរយៈពេលតែបីថ្ងៃ?»21ប៉ុន្តែ ព្រះអង្គកំពុងមានបន្ទូលអំពីព្រះវិហារនៃព្រះកាយរបស់ព្រះអង្គ។22ថាបន្ទាប់ពីព្រះអង្គសុគត ព្រះអង្គរស់ឡើងវិញ
ពួកសិស្សរបស់ព្រះអង្គចងចាំថាព្រះអង្គមានបន្ទូលពីការនេះ ហើយពួកគេជឿលើបទគម្ពីរ ហើយនឹងសេចក្ដីដែលព្រះយេស៊ូបានថ្លែង។
23ឥឡូវនេះ នៅពេលព្រះអង្គចូលរួមពិធីបុណ្យរំលងនៅក្នុងក្រុងយេរូសាឡិម មានមនុស្សជាច្រើនបានជឿលើព្រះនាមព្រះអង្គ
នៅពេលដែលពួកគេបានឃើញទីសម្គាល់ដែលព្រះអង្គបានធ្វើ។24ប៉ុន្តែ ព្រះយេស៊ូមិនបានទុកចិត្តលើពួកគេឡើយ ដោយសារព្រះអង្គស្គាល់ពួកគេទាំងអស់គ្នា។
25ព្រោះព្រះអង្គមិនត្រូវការនរណាឲ្យធ្វើបន្ទាល់ពីព្រះអង្គនៅចំពោះមនុស្សឡើយ ដ្បិតព្រះអង្គជ្រាបពីគំនិតពួកគេ។

3 1ឥឡូវនេះ មានគណៈផារីស៊ីម្នាក់ មានឈ្មោះថាលោកនីកូដេម ជាអ្នកដឹកនាំរបស់យូដា។2បុរសនេះបានមករកព្រះយេស៊ូនៅពេលយប់ ហើយទូលទៅកាន់ព្រះអង្គថា៖
«រ៉ាប៊ី យើងដឹងថា លោកគឺជាគ្រូដែលបានមកពីព្រះជាម្ចាស់ ដ្បិតគ្មាននរណាអាចធ្វើទីសម្គាល់ដែលលោកបានធ្វើទាំងនេះទេ
លើកលែងតែព្រះជាម្ចាស់គង់នៅជាមួយគាត់»។
3ព្រះយេស៊ូបានឆ្លើយទៅគាត់វិញថា៖ «ពិតណាស់ ខ្ញុំសូមប្រាប់អ្នកជាប្រាកដថា ប្រសិនបើនរណាម្នាក់មិនបានកើតជាថ្មី
គាត់មិនអាចឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់បានទេ»។4លោកនីកូដេមទូលទៅកាន់ព្រះអង្គថា៖ «តើមនុស្សអាចកើតម្តងទៀតបានដែរ បើគាត់ចាស់ហើយ?
គាត់មិនអាចចូលទៅក្នុងផ្ទៃម្ដាយរបស់គាត់ជាលើកទីពីរ ហើយកើតជាថ្មីបានទេ តើអាចទេ?»
5ព្រះយេស៊ូឆ្លើយថា៖ «ពិតណាស់ ខ្ញុំសូមប្រាប់អ្នកជាប្រាកដថា ប្រសិនបើ អ្នកនោះមិនកើតចេញពីទឹក និងពីព្រះវិញ្ញាណទេ
គាត់មិនអាចចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់បានទេ។6អ្វីដែលកើតចេញពីរូបកាយគឺជារូបកាយ ហើយអ្វីដែលកើតចេញពីព្រះវិញ្ញាណគឺព្រះវិញ្ញាណ។
7សូមកុំឆ្ងល់អ្វីដែលខ្ញុំនិយាយទៅកាន់អ្នកឡើយ «អ្នកត្រូវតែកើតជាថ្មី»។8ខ្យល់បក់ពីណាតាមតែវាចង់ អ្នកឮសម្លេងរបស់វា ប៉ុន្តែ អ្នកមិនដឹងថាវាមកពីណា ឬទៅណាទេ។
ដូចគ្នាជាមួយអ្នកដែលបានកើតពីព្រះវិញ្ញាណដែរ»។
9លោកនីកូដេមឆ្លើយ ហើយទូលទៅកាន់ព្រះអង្គថា៖ «តើការនេះអាចកើតឡើងបានយ៉ាងដូចម្តេច?»10ព្រះយេស៊ូឆ្លើយ ហើយមានបន្ទូលទៅកាន់គាត់ថា៖
«អ្នកគឺជាគ្រូរបស់អ៊ីស្រាអែល ហើយអ្នកនៅតែមិនយល់ពីការទាំងនេះទៀត?11ពិតណាស់ ខ្ញុំសូមប្រាប់អ្នកជាប្រាកដថា យើងនិយាយអ្វីដែលយើងដឹង
ហើយយើងធ្វើបន្ទាល់ពីអ្វីដែលយើងបានឃើញ។ តែអ្នកមិនទទួលទីបន្ទាល់របស់យើង។
12បើខ្ញុំគ្រាន់តែប្រាប់អ្នកពីកិច្ចការរបស់លោកីយ៍ ហើយអ្នកមិនជឿផង តើអ្នកនឹងជឿពីអ្វីដែលខ្ញុំប្រាប់អ្នកពីស្ថានសួគ៌ដូចម្តេចនឹងកើត?
13គ្មាននរណាម្នាក់បានឡើងទៅស្ថានសួគ៌ លើកលែងតែម្នាក់ដែលចុះពីស្ថានសួគ៌មក គឺបុត្រមនុស្ស។
14ដូចជាលោកម៉ូសេបានលើកសត្វពស់នៅទីរហោស្ថានយ៉ាងណា កូនមនុស្សនឹងត្រូវលើកឡើងយ៉ាងនោះដែរ15ដើម្បីឲ្យអស់អ្នកដែលជឿលើព្រះអង្គ
នឹងមានជីវិតអស់កល្បជានិច្ច។
16ដ្បិតព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ដូច្នេះហើយបានជាព្រះអង្គប្រទានព្រះបុត្រារបស់ព្រះអង្គតែមួយ ដើម្បីអស់អ្នកណាដែលជឿលើព្រះអង្គ
នឹងមិនស្លាប់ឡើយ តែនឹងមានជីវិតអស់កល្បជានិច្ចវិញ។17ដ្បិតព្រះជាម្ចាស់មិនបានចាត់ព្រះបុត្រាមកក្នុងលោកីយ៍ដើម្បីបំផ្លាញមនុស្សលោកទេ
ប៉ុន្តែដើម្បីនឹងសង្គ្រោះមនុស្សលោកតាមរយៈព្រះអង្គវិញ។18អស់អ្នកណាដែលជឿលើព្រះអង្គ នឹងមិនត្រូវមានទោសឡើយ ប៉ុន្តែអស់អ្នកណាដែលមិនជឿវិញ
ពួកគេមានទោសរួចស្រេចទៅហើយ ពួកគេមិនបានជឿលើព្រះនាមរបស់ព្រះ ហើយជាបុត្រារបស់ព្រះជាម្ចាស់តែមួយអង្គគត់។
19នេះគឺជាេហតុផលក្នុងការវិនិច្ឆ័យ ពន្លឺបានមកនៅក្នុងលោកីយ៍ហើយ ហើយមនុស្សស្រឡាញ់សេចក្ដីងងឹតជាជាងពន្លឺ ព្រោះការប្រព្រឹត្តរបស់ពួកគេអាក្រក់។
20ព្រោះមនុស្សគ្រប់រូបដែលប្រព្រឹត្តការអាក្រក់ស្អប់ពន្លឺ ហើយមិនអាចចូលមកក្នុងពន្លឺទេ ដើម្បីកុំឲ្យការប្រព្រឹត្តរបស់ពួកគេនោះត្រូវបានបើកចំហឡើយ។21ប៉ុន្តែ
អស់អ្នកដែលប្រព្រឹត្តសេចក្ដីពិត នឹងចូលមកឯពន្លឺ ដើម្បីឲ្យគេបានឃើញច្បាស់ថា ការប្រព្រឹត្តរបស់គាត់បានធ្វើនៅក្នុងព្រះជាម្ចាស់។
22បន្ទាប់ពីនេះ ព្រះយេស៊ូ និងពួកសិស្សរបស់ព្រះអង្គបានចេញទៅឯទឹកដីស្រុកយូដា។ ព្រះអង្គចំណាយពេលមួយរយៈនៅទីនោះជាមួយពួកគេ ហើយក៏ធ្វើពិធីជ្រមុជដែរ។
23ហើយលោកយ៉ូហានក៏ធ្វើពិធីជ្រមុជនៅអេណូន នៅជិតភូមិសាលីមដែរ ព្រោះនៅទីនោះមានទឹកច្រើន។ មនុស្សបានមករកគាត់
ហើយទទួលពិធីជ្រមុជជាមួយនឹងគាត់24នៅពេលនោះ លោកយ៉ូហានមិនទាន់ត្រូវបានចាប់ដាក់គុកនៅឡើយទេ។

25បន្ទាប់មកមានការប្រកែកគ្នាកើតឡើងរវាងពួកសិស្សរបស់លោកយ៉ូហាន និងសាសន៍យូដាម្នាក់ទាក់ទងរឿងពិធីលាងជម្រះ។26ពួកគេបានទៅជួបលោកយ៉ូហាន
ហើយនិយាយទៅកាន់គាត់ថា៖ «រ៉ាប៊ី មានម្នាក់នៅក្នុងចំណោមលោកគ្រូនៅឯទន្លេយ័រដាន់ម្ខាងទៀត ជាអ្នកដែលលោកបានធ្វើបន្ទាល់ មើល
គាត់កំពុងធ្វើពិធីជ្រមុជដល់មនុស្សគ្រប់គ្នាដែលមកឯគាត់។
27លោកយ៉ូហានឆ្លើយថា៖ «លោកយ៉ូហានមានប្រសាសន៍តបទៅគេថា៖ «បើព្រះជាម្ចាស់មិនប្រទានអោយទេ គ្មាននរណាម្នាក់អាចធ្វើអ្វីកើតឡើយ។
28អ្នកខ្លួនឯងក៏អាចធ្វើបន្ទាល់បានដែរ ពីអ្វីដែលខ្ញុំនិយាយថា៖ «ខ្ញុំមិនមែនជាព្រះគ្រិស្ត ប៉ុន្តែផ្ទុយទៅវិញខ្ញុំគ្រាន់តែត្រូវបានចាត់មកមុនព្រះអង្គប៉ុណ្ណោះ»។
29កូនក្រមុំជាកម្មសិទ្ធិរបស់កូនកម្លោះ។ ឥឡូវនេះ មិត្តសម្លាញ់របស់កូនកម្លោះ ដែលឈរ ហើយឮគាត់ មានអំណរជាខ្លាំងដោយសារសម្លេងរបស់កូនកម្លោះ។
ខ្ញុំពោរពេញដោយអំណរ។30សូមឲ្យព្រះអង្គបានចម្រើនឡើង តែសូមឲ្យទូលបង្គំបានថយចុះវិញ។
31ព្រះអង្គដែលយាងពីស្ថានលើមានអំណាចលើទាំងអស់។ អ្នកណាដែលមកពីផែនដីគឺមកពីផែនដី ហើយនិយាយតែពីរឿងលោកីយ៍។
អ្នកដែលមកពីស្ថានសួគ៌មានអំណាចលើទាំងអស់។32ព្រះអង្គបានធ្វើបន្ទាល់អំពីអ្វីដែលព្រះអង្គបានឃើញនិងឮ ប៉ុន្តែ គ្មាននរណាទទួលទីបន្ទាល់របស់ព្រះអង្គសោះ។
33អស់អ្នកណាដែលបានទទួលទីបន្ទាល់របស់ព្រះអង្គបានបញ្ជាក់ថាព្រះជាម្ចាស់បានសម្ដែងសេចក្ដីពិតមែន។
34ដ្បិតព្រះមួយអង្គដែលព្រះជាម្ចាស់បានចាត់មកឲ្យថ្លែងព្រះបន្ទូលរបស់ព្រះ ព្រោះព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកព្រះអង្គជាបរិបូរណ៌។35ព្រះបិតាស្រឡាញ់ព្រះបុត្រា
ហើយបានប្រទានអ្វីៗទាំងអស់ទៅក្នុងព្រះហស្ដរបស់ព្រះអង្គ។36អ្នកណាដែលជឿលើព្រះបុត្រានឹងមានជីវិតអស់កល្បជានិច្ច
ប៉ុន្តែអ្នកណាដែលមិនស្ដាប់បង្គាប់ដល់ព្រះបុត្រាវិញ នឹងមិនឃើញជីវិតឡើយ ប៉ុន្តែសេចក្ដីក្រោធរបស់ព្រះនឹងស្ថិតនៅលើអ្នកនោះវិញ»។

4 1នៅពេលព្រះយេស៊ូជ្រាបថា ពួកផារីស៊ីបានឮថា ព្រះអង្គបានបង្កើតសិស្ស
និងធ្វើពិធីជ្រមុជច្រើនជាងលោកយ៉ូហានទៅទៀត2(សូម្បីតែព្រះអង្គផ្ទាល់មិនបានធ្វើពិធីជ្រមុជ ផ្ទុយទៅវិញពួកសិស្សរបស់ព្រះអង្គជាអ្នកធ្វើពិធីជ្រមុជ)។
3ព្រះអង្គបានចាកចេញពីស្រុកយូដា ហើយត្រឡប់ទៅកាលីឡេវិញ។
4គ្មានការចាំបាច់អ្វីដែលសម្រាប់ព្រះអង្គក្នុងការឆ្លងកាត់ស្រុកសាម៉ារីទេ។5ប៉ុន្តែ ព្រះអង្គបែរជាចូលទៅក្នុងក្រុងរបស់សាម៉ារី ដែលហៅថា ភូមិស៊ូខារ
នៅជិតដីមួយកន្លែងរបស់លោកយ៉ាកុបបានឲ្យទៅលោកយ៉ូសែបជាកូនរបស់គាត់។
6អណ្ដូងរបស់លោកយ៉ាកុបនៅទីនោះ។ ព្រះយេស៊ូអស់កម្លាំងពីការធ្វើដំណើររបស់ព្រះអង្គ ហើយទ្រង់ក៏គង់នៅជិតអណ្ដូងនោះ។ នៅពេលនោះម៉ោងប្រហែលជាប្រាំមួយ។
7ស្ត្រីសាសន៍សាម៉ារីម្នាក់បានមកដងទឹក ហើយព្រះយេស៊ូមានបន្ទូលទៅកាន់នាងថា៖ «ឲ្យខ្ញុំសូមទឹកផឹកបន្តិចផង»។8រីឯពួកសិស្សរបស់ព្រះអង្គបានចូលទៅទីក្រុង
ដើម្បីទិញអាហារ។
9បន្ទាប់មក ស្ត្រីសាសន៍សាម៉ារីបានទូលទៅកាន់ព្រះអង្គថា៖ «លោកជាសាសន៍យូដា ម្ដេចក៏លោកមកសុំទឹកពីខ្ញុំដែលជាសាសន៍សាម៉ារីដូច្នេះ?»
ដ្បិតសាសន៍យូដាមិនទាក់ទងជាមួយសាសន៍សាម៉ារីទេ។10ព្រះយេស៊ូបានឆ្លើយ ហើយមានបន្ទូលទៅកាន់នាងថា៖ «ប្រសិនបើ នាងបានស្គាល់អំណោយទានរបស់ព្រះ
ហើយស្គាល់ខ្ញុំជានរណាដែលនិយាយទៅកាន់នាងថា៖ “ខ្ញុំសុំទឹកទទួលទានបន្តិច”នោះនាងមុខជាសុំទឹកពីលោកវិញពុំខាន ហើយលោកនឹងអោយទឹកដល់នាង គឺជាទឹក
ដែលផ្ដល់ជីវិត»។ ។
11ស្ត្រីនោះបានទូលទៅកាន់ព្រះអង្គថា៖ «លោកម្ចាស់អើយ លោកមិនមានធុងផង ហើយអណ្ដូងក៏ជ្រៅទៀត។ តើលោកបានទឹករស់មកណា?
12លោកមិនធំជាងលោកយ៉ាកុប ជាឪពុករបស់យើង ដែលបានផ្ដល់អណ្ដូង និងទឹកពីអណ្ដូងនេះ ឲ្យយើងនឹងកូនចៅ ព្រមទាំងហ្វូងសត្វរបស់គាត់ផឹកទេ។
13ព្រះយេស៊ូមានបន្ទូលទៅកាន់នាងថា៖
«មនុស្សគ្រប់គ្នាដែលផឹកពីទឹកនេះនឹងស្រេកម្ដងទៀត14ប៉ុន្តែអស់អ្នកណាដែលផឹកទឹកដែលខ្ញុំនឹងផ្ដល់ដល់អ្នកនោះនឹងមិនស្រេកទៀតទេ។ ផ្ទុយទៅវិញ
ទឹកដែលខ្ញុំឲ្យនោះនឹងផ្ដល់ឲ្យអ្នកនោះក្លាយជាប្រភពទឹកនៅក្នុងអ្នកនោះ ផុសឡើង ដើម្បីឲ្យមានជីវិតអស់កល្បជានិច្ច»។
15ស្ត្រីនោះបានទូលទៅកាន់ព្រះអង្គថា៖ «លោកម្ចាស់ សូមឲ្យទឹកនេះខ្ញុំផង ដើម្បីឲ្យខ្ញុំលែងស្រេកទៀត ហើយខ្ញុំមិនបាច់មកដងទឹកនៅទីនេះទេ»។
16ព្រះយេស៊ូមានបន្ទូលទៅនាងថា៖ «ចូរទៅ ហៅស្វាមីរបស់នាង ហើយត្រឡប់មកទីនេះវិញ»។
17ស្ត្រីនោះឆ្លើយ ហើយទូលទៅកាន់ព្រះអង្គថា៖ «ខ្ញុំគ្មានប្ដីទេ»។ ព្រះយេស៊ូឆ្លើយថា៖ «នាងនិយាយថា៖ «ខ្ញុំគ្មានប្ដីត្រូវហើយ»។18ដ្បិត នាងមានប្ដីចំនួនប្រាំហើយ
ហើយម្នាក់ដែលនៅជាមួយនាងសព្វថ្ងៃ ក៏មិនមែនជាប្ដីរបស់នាងដែរ។ អ្វីដែលនាងនិយាយគឺជាការពិត»។
19ស្ត្រីនោះទូលទៅកាន់ព្រះអង្គថា៖ «លោកម្ចាស់ ខ្ញុំឃើញថា លោកគឺជាព្យាការី។20ឪពុករបស់យើងថ្វាយបង្គំនៅលើភ្នំនេះ ប៉ុន្តែ តើលោកមានប្រសាសន៍ថា
ក្រុងយេរូសាឡិមគឺជាកន្លែងដែលមនុស្សត្រូវថ្វាយបង្គំ»។
21ព្រះយេស៊ូមានបន្ទូលទៅនាងថា៖ «ស្ត្រីអើយ! ចូរជឿដល់ខ្ញុំចុះ ពេលនោះនឹងមកដល់នៅពេលអ្នកថ្វាយបង្គំព្រះបិតានៅលើភ្នំនេះ ឬនៅក្រុងយេរូសាឡិម។
22អ្នកថ្វាយបង្គំអ្វីដែលអ្នកមិនដឹង។ យើងថ្វាយបង្គំអ្វីដែលយើងដឹង ដើម្បីសេចក្ដីសង្គ្រោះចេញពីសាសន៍យូដាមក។
23ប៉ុន្តែ ពេលវេលានឹងមកដល់ ឥឡូវនេះដល់ពេលហើយ នៅពេលអ្នកថ្វាយបង្គំពិត នឹងថ្វាយបង្គំព្រះបិតាដោយវិញ្ញាណ និងសេចក្ដីពិត ដ្បិត
ព្រះបិតាស្វែងរកមនុស្សបែបនេះ ដើម្បីធ្វើជាអ្នកថ្វាយបង្គំព្រះអង្គ។24ព្រះជាម្ចាស់ជាវិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំព្រះអង្គ ត្រូវតែថ្វាយបង្គំដោយវិញ្ញាណ
និងសេចក្ដីពិត»។
25ស្ត្រីនោះទូលទៅកាន់ព្រះអង្គថា៖ «ខ្ញុំដឹងថាព្រះមេស្ស៊ីនឹងយាងមក (ជាព្រះដែលហៅថា ព្រះគ្រិស្ដ)។ នៅពេលព្រះអង្គយាងមក
ព្រះអង្គនឹងពន្យល់គ្រប់យ៉ាងដល់យើង»។26ព្រះយេស៊ូឆ្លើយទៅនាងថា «ខ្ញុំគឺជាព្រះអង្គហើយ ជាព្រះដែលអ្នកកំពុងមានបន្ទូលទៅកាន់នាង»។
27នៅពេលនោះពួកសិស្សរបស់ព្រះអង្គក៏ត្រឡប់មកវិញ។ ពួកគេងឿងឆ្ងល់ថា ហេតុអ្វីបានជាព្រះអង្គមានបន្ទូលជាមួយស្ត្រីនោះ ប៉ុន្តែ គ្មាននរណាហ៊ាននិយាយថា៖
«តើព្រះអង្គចង់បានអ្វី?» ឬ «ហេតុអ្វីបានជាព្រះអង្គមានបន្ទូលជាមួយនាង?»
28ដូច្នេះ ស្ត្រីបានទុកក្អមទឹករបស់នាងចោល ត្រឡប់ទៅក្រុងវិញ ហើយនិយាយប្រាប់មនុស្ស29«មក ខ្ញុំឃើញបុរសម្នាក់ដែលបានប្រាប់អ្វីៗដែលខ្ញុំបានធ្វើគ្រប់យ៉ាង។
តើនេះមិនមែនជាព្រះគ្រិស្ដ ទេឬអី?30ពួកគេបានចេញពីក្រុងទៅរកព្រះអង្គវិញ។
31នៅពេលជាមួយគ្នានោះ ពួកសិស្សបានអង្វរព្រះអង្គ ដោយនិយាយថា៖ «រ៉ាប៊ី សូមអញ្ជើញបរិភោគ!»។32ប៉ុន្តែ ព្រះអង្គមានបន្ទូលទៅពួកគេថា៖
«ខ្ញុំមានអាហារបរិភោគដែលអ្នកមិនស្គាល់ទេ»។33ដូច្នេះហើយ បានជាពួកសិស្សនិយាយទៅគ្នាទៅវិញទៅមកថា៖ «គ្មាននរណាយកអាហារឲ្យព្រះអង្គសោយទេ មែនទេ?»
34ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកគេថា៖ «អាហាររបស់ខ្ញុំគឺធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គដែលចាត់ខ្ញុំឲ្យមក ហើយធ្វើឲ្យកិច្ចការរបស់ព្រះអង្គបានសម្រេច។
35កុំនិយាយថា៖ «នៅសល់ពេលបួនខែទៀត ទើបរដូវចម្រូតមកដល់?» ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា សូមងើយឡើងមើលទៅវាល ដ្បិត ស្រូវទុំរួចរាល់ដើម្បីច្រូតហើយ!
36អស់អ្នកណាដែលច្រូតនឹងទទួលឈ្នួល ហើយប្រមូលផលនៃជីវិតអស់កល្បជានិច្ច ដូច្នេះហើយ អស់អ្នកណាដែលព្រោះ
ហើយអស់អ្នកដែលច្រូតអាចមានអំណរជាមួយគ្នា។
37ស្របតាមពាក្យចាស់លោកថាៈ“ម្នាក់ព្រោះ ម្នាក់ទៀតច្រូត”។38ខ្ញុំបានចាត់អ្នករាល់គ្នាអោយទៅច្រូត នៅក្នុងស្រែដែលអ្នករាល់គ្នាពុំបានធ្វើការនឿយហត់ គឺអ្នកផ្សេងទៀត
បានធ្វើការនឿយហត់ ហើយអ្នករាល់គ្នាទទួលផលពីការនឿយហត់របស់អ្នកទាំងនោះ»។
39មានសាសន៍សាម៉ារីជាច្រើននៅក្នុងក្រុងនោះបានជឿលើព្រះអង្គ ដោយសារការប្រាប់របស់ស្ត្រីដែលបានធ្វើបន្ទាល់ថា៖ «ព្រះអង្គបានប្រាប់អ្វីៗដែលខ្ញុំបានធ្វើគ្រប់យ៉ាង»។
40ដូច្នេះ នៅពេលសាសន៍សាម៉ារីមករកព្រះអង្គ ពួកគេសូមឲ្យព្រះអង្គគង់នៅជាមួយពួកគេ ហើយព្រះអង្គក៏គង់នៅទីនោះពីរថ្ងៃ។

[41]មានមនុស្សជាច្រើនថែមទៀតបានជឿដោយព្រោះព្រះបន្ទូលរបស់ព្រះអង្គ។[42]ពួកគេនិយាយទៅកាន់ស្ត្រីនោះថា៖
«យើងមិនបានជឿដោយសារអ្វីដែលនាងបាននិយាយទៀតទេ ដ្បិត យើងខ្លួនឯងផ្ទាល់បានឮពីព្រះអង្គ ហើយយើងបានដឹងថា
ព្រះអង្គគឺជាព្រះសង្គ្រោះពិភពលោកពិតប្រាកដមែន»។
[43]បន្ទាប់ពីថ្ងៃនោះពីរថ្ងៃមក ព្រះអង្គបានចេញពីទីនោះទៅកាលីឡេវិញ។[44]ដ្បិត ព្រះយេស៊ូផ្ទាល់បានមានបន្ទូលថា គ្មានព្យាការីណាម្នាក់ត្រូវគេគោរពក្នុងស្រុកកំណើតរបស់
ខ្លួនផ្ទាល់ឡើយ។[45]នៅពេលព្រះអង្គយាងទៅស្រុកកាលីឡេ អ្នកស្រុកកាលីឡេមិនស្វាគមន៍ព្រះអង្គទេ។
ពួកគេបានឃើញអ្វីៗទាំងអស់ដែលព្រះអង្គបានធ្វើនៅក្នុងក្រុងយេរូសាឡិមនៅថ្ងៃបុណ្យ ព្រោះពួកគេបានទៅចូលរួមបុណ្យនោះដែរ។
[46]ឥឡូវនេះ ព្រះអង្គបានយាងទៅកាណាក្នុងស្រុកកាលីឡេម្តងទៀត ជាកន្លែងដែលព្រះបានធ្វើទឹកឲ្យក្លាយជាស្រា។ នៅទីនោះមានមន្ត្រីម្នាក់
ដែលកូនរបស់គាត់ឈឺនៅកាពើណិម។[47]នៅពេលគាត់បានឮថាព្រះយេស៊ូមកពីស្រុកយូដាទៅកាលីឡេ គាត់បានទៅរកព្រះយេស៊ូ ហើយអង្វរព្រះអង្គឲ្យចុះទៅកាពើណិម
ហើយប្រោសកូនប្រុសគាត់ដែលជិតស្លាប់ហើយឲ្យជា។
[48]បន្ទាប់មក ព្រះយេស៊ូមានបន្ទូលទៅកាន់គាត់ថា៖ «បើអ្នកមិនឃើញទីសម្គាល់ និងការអស្ចារ្យ នោះអ្នកមិនជឿទេ»។[49]មន្ត្រីនោះមានប្រសាសន៍ទៅកាន់ព្រះអង្គថា៖
«លោកម្ចាស់អើយ សូមចុះទៅ មុនពេលកូនប្រុសខ្ញុំស្លាប់»។[50]ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «ទៅចុះ! កូនលោកនៅរស់ទេ»។
បុរសនោះជឿលើព្រះបន្ទូលដែលព្រះអង្គមានបន្ទូលទៅគាត់ ហើយគាត់ក៏ចេញទៅ។
[51]ក្នុងការដែលគាត់កំពុងចុះទៅ អ្នកបម្រើរបស់គាត់បានមកជួបគាត់ និយាយថា កូនរបស់គាត់នៅរស់ទេ។[52]ដូច្នេះ គាត់ក៏សួរទៅពួកគេ ពីពេលវេលា
ថាកូនគាត់ជាពេលណា។ ពួកគេប្រាប់គាត់ថា៖ «កាលពីម្សិលមិញម៉ោងប្រាំពីរ ជំងឺគ្រុនបានចេញពីគាត់»។
[53]នោះឪពុកបានដឹងថា គឺជាពេលដែលព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «កូនរបស់លោកនៅរស់ទេ»។ ដូច្នេះ គាត់ខ្លួនឯង
និងគ្រួសាររបស់គាត់ទាំងមូលបានជឿលើព្រះអង្គ។[54]នេះគឺជាទីសម្គាល់ទីពីរ ដែលព្រះយេស៊ូបានធ្វើ នៅពេលព្រះអង្គចេញពីស្រុកយូដាទៅកាលីឡេ។

5 [1]បន្ទាប់ពីការនេះ មានបុណ្យរបស់សាសន៍យូដាមួយ ហើយព្រះយេស៊ូបានយាងឡើងទៅក្រុងយេរូសាឡិម។[2]ព្រះអង្គយាងចូលក្រុងយេរូសាឡិមតាមទ្វារចៀម
មានស្រះមួយ ដែលភាសាហេព្រើរហៅថា ស្រះបេថែសដា នៅជិតស្រះនោះមានថែវប្រាំ។[3]មានមនុស្សជាច្រើនដែលឈឺនៅទីនោះ មានអ្នកខ្វាក់ ខ្វិន
ឬស្វិតដៃជើងដេកនៅទីនោះ។[4]ទេវតារបស់ព្រះអម្ចាស់បានចុះមក ហើយកូរទឹកនោះយូរៗម្តង
អ្នកណាដែលចុះទៅក្នុងទឹកដែលកូរនោះមុនគេនឹងបានជាពីជំងឺរោគាដែលធ្វើឲ្យពួកគេឈឺចាប់។
[5]មានបុរសម្នាក់នៅទីនោះ មានជំងឺអស់រយៈពេលសាមសិបប្រាំបីឆ្នាំហើយ។[6]នៅពេលព្រះយេស៊ូឃើញគាត់ដេកនៅទីនោះ ហើយបន្ទាប់ពីព្រះអង្គជ្រាប់ថា
គាត់នៅទីនោះជាយូរមកហើយ ព្រះអង្គមានបន្ទូលទៅគាត់ថា៖ «តើអ្នកចង់ជាទេ?»
[7]អ្នកឈឺនោះបានទូលឆ្លើយថា៖ «លោកម្ចាស់អើយ! ខ្ញុំគ្មាននរណាលើកខ្ញុំចូលទៅក្នុងស្រះទឹក នៅពេលទឹកកម្រើកឡើងទេ។ នៅពេលខ្ញុំមក
អ្នកផ្សេងបានចុះទៅមុនខ្ញុំរួចបាត់ទៅហើយ»។[8]ព្រះយេស៊ូឆ្លើយទៅគាត់ថា៖ «ក្រោកឡើង ចូរយកគ្រែអ្នកឡើង ហើយដើរទៅ!»។
[9]បុរសនោះបានជាមួយរំពេច ហើយគាត់បានយកគ្រែរបស់គាត់ឡើង ហើយដើរចេញទៅ។ ថ្ងៃនោះជាថ្ងៃសប្ប័ទ។
[10]ដូច្នេះ ពួកយូដាបានសួរគាត់ថា តើអ្នកណាធ្វើឲ្យអ្នកជា «ថ្ងៃនេះជាថ្ងៃសប្ប័ទ មិនអនុញ្ញាតឲ្យអ្នកលីគ្រែរបស់អ្នកឡើយ»។[11]គាត់ឆ្លើយថា៖ «អ្នកដែលធ្វើឲ្យខ្ញុំបានជា
គាត់ប្រាប់ខ្ញុំថា «ចូរយកកម្រាលរបស់អ្នកឡើង ហើយដើរទៅ»។
[12]ពួកគេសួរគាត់ថា៖ «តើបុរសដែលនិយាយមកកាន់អ្នកថា «ចូរយកវាឡើង ហើយដើរនោះ ជានរណា?»[13]ប៉ុន្តែ គ្មាននរណាដឹងថាម្នាក់ដែលធ្វើឲ្យគាត់ជានោះជានរណាទេ
ដោយសារព្រះយេស៊ូបានចេញពីទីនោះដោយអាថ៌កំបាំង ដ្បិតមានមនុស្សច្រើនកោះករនៅទីនោះ។
[14]បន្ទាប់ពីនោះមក ព្រះយេស៊ូបានជួបគាត់នៅក្នុងព្រះវិហារ ហើយមានបន្ទូលទៅកាន់គាត់ថា៖ «មើល អ្នកបានជាហើយ! កុំធ្វើបាបទៀតឡើយ
ដើម្បីកុំឲ្យមានអ្វីអាក្រក់ជាងនេះកើតឡើងចំពោះអ្នកទៀត»។[15]បុរសនោះបានចេញទៅ ហើយប្រាប់ទៅពួកយូដាថា គឺព្រះយេស៊ូដែលបានធ្វើឲ្យគាត់បានជា។
[16]ដោយសារការទាំងនេះ ពួកយូដាបានបៀតបៀនដល់ព្រះយេស៊ូ ដោយព្រោះព្រះអង្គធ្វើការទាំងនេះនៅថ្ងៃសប្ប័ទ។[17]ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖
«ព្រះបិតារបស់ខ្ញុំធ្វើការសូម្បីតែពេលនេះ ហើយខ្ញុំក៏ធ្វើការដែរ»។[18]ដោយសារការនេះ បានធ្វើឲ្យពួកយូដាចង់សម្លាប់ព្រះអង្គកាន់តែខ្លាំង
ព្រោះព្រះអង្គមិនគ្រាន់តែប្រព្រឹត្តខុសថ្ងៃសប្ប័ទប៉ុណ្ណោះទេ ប៉ុន្តែ ព្រះអង្គបានហៅព្រះជាម្ចាស់ថា ជាព្រះបិតារបស់ព្រះអង្គផ្ទាល់ ព្រះអង្គលើកអង្គទ្រង់ស្មើព្រះជាម្ចាស់។
[19]ព្រះយេស៊ូមានបន្ទូលពួកគេថា៖ «ពិតណាស់ខ្ញុំប្រាប់អ្នកជាប្រាកដថា ព្រះបុត្រាមិនអាចធ្វើអ្វីដោយខ្លួនបានទេ លើកលែងតែអ្វីដែលព្រះអង្គបានឃើញព្រះបិតាធ្វើ
ព្រោះអ្វីក្តីដែលព្រះបិតាធ្វើ ព្រះបុត្រាក៏ធ្វើការទាំងនោះដូចព្រះអង្គដែរ។[20]ដ្បិតព្រះបិតាស្រឡាញ់ព្រះបុត្រា
ហើយព្រះអង្គបង្ហាញអ្វីៗទាំងអស់ដែលព្រះអង្គផ្ទាល់បានធ្វើដល់ព្រះបុត្រា ហើយព្រះអង្គនឹងបង្ហាញដល់ព្រះបុត្រានូវការដ៏ធំជាងការទាំងនេះ
ដើម្បីឲ្យអ្នករាល់គ្នាមានការងឿងឆ្ងល់។
[21]ដ្បិតព្រះបិតាដែលប្រោសមនុស្សស្លាប់ ហើយប្រទានជីវិតដល់ពួកគេយ៉ាងណា ព្រះបុត្រានឹងប្រទានជីវិតដល់អស់អ្នកណាដែលព្រះអង្គគាប់ព្រះហឫទ័យយ៉ាងនោះដែរ។
[22]ដ្បិតព្រះបិតាមិនបានជំនុំជម្រះនរណាទេ ប៉ុន្តែព្រះអង្គប្រទានគ្រប់ទាំងការជំនុំជម្រះទាំងអស់ដល់ព្រះបុត្រា។
[23]ដើម្បីឲ្យមនុស្សគ្រប់គ្នាបានគោរពដល់ព្រះបុត្រាដូចដែលពួកគេបានគោរពដល់ព្រះបិតាដែរ។ អ្នកណាដែលមិនគោរពព្រះបុត្រា
ក៏មិនគោរពដល់ព្រះបិតាដែលចាត់ព្រះអង្គឲ្យមកដែរ។
[24]ពិតណាស់ ខ្ញុំប្រាប់អ្នកជាប្រាកដថា អ្នកណាដែលឮពាក្យខ្ញុំ ហើយជឿលើព្រះអង្គដែលចាត់ខ្ញុំឲ្យមកនឹងមានជីវិតអស់កល្បជានិច្ច ហើយនិងមិនជាប់មានទោសឡើយ
ប៉ុន្តែឆ្លងផុតពីស្លាប់មកកាន់ជីវិតវិញ។
[25]ពិតណាស់ ខ្ញុំប្រាប់អ្នកជាប្រាកដថា ពេលវេលានឹងមកដល់ ហើយឥឡូវនេះ ដល់ពេលហើយ នៅពេលដែលមនុស្សស្លាប់នឹងឮសម្លេងបុត្រារបស់ព្រះជាម្ចាស់
ហើយអស់អ្នកដែលឮនឹងបានរស់។
[26]ដ្បិតព្រះបិតាមានព្រះជន្មនៅក្នុងអង្គទ្រង់យ៉ាងណា ព្រះអង្គក៏ប្រទានដល់ព្រះបុត្រាយ៉ាងនោះដែរ ដើម្បីឲ្យព្រះអង្គមានព្រះជន្មនៅក្នុងអង្គទ្រង់ដែរ។
[27]ហើយព្រះបិតាបានប្រទានសិទ្ធិអំណាចដល់ព្រះបុត្រាក្នុងការវិនិច្ឆ័យដែរ ព្រោះព្រះអង្គគឺជាបុត្រមនុស្ស។
[28]កុំឲ្យងឿងឆ្ងល់ពីការនេះឡើយ ព្រោះនឹងមានពេលមកដល់ដែលមនុស្សគ្រប់រូបដែលនៅក្នុងផ្នូរនឹងឮព្រះសូរសៀងរបស់ព្រះអង្គ ហើយពួកគេ[29]នឹងចេញមក
អ្នកណាដែលធ្វើល្អនឹងរស់ឡើងដើម្បីទទួលជីវិត ហើយអស់អ្នកដែលបានធ្វើការអាក្រក់នឹងរស់ឡើងដើម្បីទទួលការជំនុំជម្រះ។
[30]ខ្ញុំមិនបានអាចធ្វើអ្វីដោយខ្លួនខ្ញុំទេ។ ខ្ញុំឮ ខ្ញុំជំនុំជម្រះ ហើយសេចក្តីវិនិច្ឆ័យរបស់ខ្ញុំគឺសុចរិត ព្រោះខ្ញុំមិនបានធ្វើតាមបំណងចិត្តរបស់ខ្ញុំផ្ទាល់ទេ
ប៉ុន្តែតាមបំណងព្រះហឫទ័យរបស់ព្រះដែលចាត់ខ្ញុំមកវិញ។[31]ប្រសិនបើខ្ញុំធ្វើបន្ទាល់ពីខ្លួនខ្ញុំ ទីបន្ទាល់របស់ខ្ញុំអាចមិនពិត។[32]មានអ្នកផ្សេងទៀតបានធ្វើបន្ទាល់ពីខ្ញុំ
ហើយខ្ញុំដឹងថាការធ្វើទីបន្ទោល់អំពីខ្ញុំជាសេចក្តីពិត។
[33]អ្នករាល់គ្នាបានចាត់មនុស្សឲ្យទៅរកលោកយ៉ូហាន ហើយគាត់បានធ្វើបន្ទាល់ពីសេចក្តីពិត។[34]ប៉ុន្តែទីបន្ទាល់ដែលខ្ញុំបានទទួលមិនមែនមកពីមនុស្សទេ។
ខ្ញុំនិយាយការទាំងនេះ ដើម្បីឲ្យអ្នករាល់គ្នាបានសង្គ្រោះ។[35]លោកយ៉ូហានជាចង្កៀងដែលកំពុងឆេះ ហើយជះពន្លឺ
ហើយគាត់នឹងរីករាយជាមួយពន្លឺរបស់គាត់តែមួយរយៈប៉ុណ្ណោះ។


generated on Fri Jun 6 10:45:59 2025

36ប៉ុន្តែទីបន្ទាល់ដែលខ្ញុំមានធំជាងលោកយ៉ូហានមាន ព្រោះកិច្ចការដែលព្រះបិតាបានប្រទានឲ្យខ្ញុំបំពេញ ហើយកិច្ចការសំខាន់ដែលខ្ញុំត្រូវធ្វើ
គឺធ្វើបន្ទាល់ពីខ្ញុំដែលព្រះបិតាបានចាត់ខ្ញុំឲ្យមក។ 37ព្រះបិតាបានចាត់ខ្ញុំមក ព្រះអង្គក៏ធ្វើបន្ទាល់អំពីខ្ញុំដែរ។ អ្នករាល់គ្នាមិនដែលបានឮព្រះសូរសៀង
ឬឃើញព្រះកាយរបស់ព្រះអង្គដែរ។ 38អ្នករាល់គ្នាគ្មានព្រះបន្ទូលរបស់ព្រះអង្គនៅជាមួយអ្នករាល់គ្នាទេ ព្រោះអ្នករាល់គ្នាមិនជឿលើព្រះដែលព្រះអង្គចាត់ឲ្យមកទេ។
39អ្នករាល់គ្នាស្វែងរកបទគម្ពីរដោយសារអ្នករាល់គ្នាគិតថា នៅក្នុងបទគម្ពីរនោះមានជីវិតអស់កល្បជានិច្ច
ហើយបទគម្ពីរដដែលនេះហើយធ្វើបន្ទាល់អំពីខ្ញុំ 40ហើយអ្នករាល់គ្នាមិនចង់ចូលមករកខ្ញុំ ដើម្បីឲ្យអ្នករាល់គ្នាបានជីវិតសោះ។
41កុំទទួលការសរសើរពីមនុស្សឡើយ 42ប៉ុន្តែ ខ្ញុំដឹងថា អ្នករាល់គ្នាមិនបានស្រឡាញ់ព្រះជាម្ចាស់នៅក្នុងខ្លួនរបស់អ្នករាល់គ្នាឡើយ។
43ខ្ញុំបានមកក្នុងព្រះនាមរបស់ព្រះបិតានៃខ្ញុំ ហើយអ្នករាល់គ្នាមិនទទួលខ្ញុំ។ ប្រសិនបើ អ្នកផ្សេងទៀតមកក្នុងនាមរបស់គេផ្ទាល់ អ្នកអាចនឹងទទួលអ្នកនោះ។
44តើអ្នកអាចជឿដូចម្ដេចកើត អ្នកគឺជាមនុស្សដែលទទួលការសរសើរពីគ្នាទៅវិញទៅមក ប៉ុន្តែអ្នករាល់គ្នាមិនបានស្វែងរកការសរសើរដែលចេញពីព្រះជាម្ចាស់តែមួយផង?
45កុំគិតថា ខ្ញុំខ្លួនឯងនឹងចោទប្រកាន់អ្នករាល់គ្នានៅចំពោះព្រះបិតាឡើយ។ ម្នាក់ដែលចោទប្រកាន់អ្នករាល់គ្នាគឺលោកម៉ូសេ
គឺជាអ្នកដែលអ្នកបានដាក់សេចក្ដីសង្ឃឹមរបស់អ្នកលើ។ 46ប្រសិនបើ អ្នករាល់អ្នកជឿលោកម៉ូសេ អ្នករាល់គ្នាជឿដល់ខ្ញុំដែរ ព្រោះគាត់សរសរពីខ្ញុំ។ 47ប្រសិនបើ
អ្នកមិនជឿលើការសរសេររបស់គាត់ទេ ធ្វើដូចម្ដេចឲ្យអ្នករាល់គ្នាអាចជឿលើពាក្យរបស់ខ្ញុំបាន?»

6 1បន្ទាប់ពីការនេះ ព្រះយេស៊ូបានយាងចេញទៅម្ខាងទៀតនៃសមុទ្រកាលីឡេ គេក៏ឈ្មោះមួយទៀតថាសមុទ្រទីបេរាស។
2មានបណ្ដាជនយ៉ាងច្រើនកោះករដើរតាមព្រះអង្គ ព្រោះពួកគេបានឃើញទីសម្គាល់ដែលព្រះអង្គបានធ្វើជាមួយពួកអ្នកដែលឈឺ។ 3ព្រះយេស៊ូបានយាងឡើងភ្នំ
ហើយគង់នៅជាមួយពួកសិស្សនៅទីនោះ។
4(ពិធីបុណ្យចម្លង ពិធីបុណ្យរបស់សាសន៍យូដាជិតមកដល់ហើយ)។ 5នៅពេលព្រះយេស៊ូងើបព្រះនេត្រឡើង ព្រះអង្គទតឃើញបណ្ដាជនយ៉ាងច្រើនចូលមករកព្រះអង្គ
ទ្រង់មានបន្ទូលទៅលោកភីលីពថា៖ «តើយើងនឹងត្រូវទៅទិញនំប៉័ងពីណាមក ដើម្បីឲ្យអ្នកទាំងអស់នេះបរិភោគ?» 6(ព្រះយេស៊ូមានបន្ទូលបែបនេះ
ដើម្បីល្បងលលោកភីលីពទេ ដ្បិតព្រះអង្គផ្ទាល់ ទ្រង់ជ្រាបថាអ្វីដែលព្រះអង្គត្រូវធ្វើហើយ)។
7លោកភីលីពទូលព្រះអង្គថា៖ «ទោះបីជាយកលុយកាក់ពីររយឌេណារីទៅទិញនំប៉័ងក៏មិនគ្រប់ដែរ សូម្បីតែចែកម្នាក់បន្តិចក្ដី»។ 8សិស្សម្នាក់ទៀតឈ្មោះ អនទ្រេ
ត្រូវជាបងប្រុសរបស់លោកស៊ីម៉ូនពេត្រុស ទូលទៅព្រះយេស៊ូថា៖ 9«មានក្មេងប្រុសម្នាក់ មាននំប៉័ងប្រាំដុំ និងត្រីពីរ ប៉ុន្តែ តើធ្វើដូចម្ដេចឲ្យគ្រប់បាន
បើមនុស្សមានគ្នាច្រើនយ៉ាងនេះ?»។
10ព្រះយេស៊ូមានបន្ទូលថា៖ «សូមឲ្យមនុស្សអង្គុយចុះ»។ (នៅទីនោះមានស្មៅច្រើន)។ ដូច្នេះ បណ្ដាជនក៏អង្គុយនៅទីនោះ មានគ្នាប្រហែលជាប្រាំពាន់អ្នក។ 11ដូច្នេះ
ព្រះយេស៊ូបានយកនំប៉័ង បន្ទាប់ពីព្រះអង្គបានអរព្រះគុណរួចហើយ ព្រះអង្គបានប្រទាននំប៉័ងទាំងនោះទៅដល់អស់អ្នកដែលបានអង្គុយ។ ចំណែកត្រីវិញ
ព្រះអង្គបានធ្វើដូចគ្នាដែរ 12ចែកដល់ពួកគេតាមអ្វីដែលពួកគេត្រូវការ។ នៅពេលបណ្ដាជនបានឆ្អែតហើយ ព្រះអង្គមានបន្ទូលទៅពួកសិស្សរបស់ព្រះអង្គថា៖
«ចូរប្រមូលនំប៉័ងដែលនៅសល់មកវិញ កុំឲ្យបាត់មួយដុំណាឡើយ»។
13ដូច្នេះ ពួកគេបានប្រមូលនំប៉័ងទាំងនោះមកវិញ ហើយបានដប់ពីរកន្ត្រកពេញពីមនុស្សជាច្រើនដែលបានបរិភោគ ជាដុំនំប៉័ងដែលបាក់បែក
ដែលកើតចេញពីនំប៉័ងប្រាំដុំនោះ។ 14បន្ទាប់ពីមនុស្សបានឃើញការអស្ចារ្យដែលព្រះអង្គបានធ្វើនេះ ពួកគេនិយាយថា៖
«នេះគឺជាព្យាការីដ៏ពិតដែលបានមកនៅក្នុងលោកីយ៍នេះ»។ 15នៅពេលព្រះយេស៊ូជ្រាបថា ពួកគេនាំគ្នា ហើយចង់បង្ខំព្រះអង្គឲ្យធ្វើជាស្ដេច
ព្រះអង្គក៏ចាកចេញពីពួកគេឡើងទៅលើភ្នំម្ដងទៀត។
16នៅពេលល្ងាចមកដល់ ពួកសិស្សរបស់ព្រះអង្គបានចុះទៅឯសមុទ្រ។ 17ពួកគេឡើងជិះទូក ហើយឆ្លងទៅសមុទ្រទៅកាពើណិម។ នៅពេលនេះងងឹតហើយ
ព្រះយេស៊ូមិនទាន់បានយាងទៅរកពួកគេនៅឡើយទេ។ 18មានខ្យល់បក់បោកយ៉ាងខ្លាំង ហើយទឹកសមុទ្រក៏កម្រើកឡើងដែរ។
19នៅពេលដែលពួកគេចែវទូកបានចម្ងាយប្រហែលជាប្រាំ ឬប្រាំមួយគីឡូម៉ែត្រ ពួកគេបានឃើញព្រះយេស៊ូកំពុងយាងនៅលើទឹកសមុទ្រ ហើយចូលមកជិតទូក
ពួកគេមានការភ័យខ្លាច។ 20ប៉ុន្តែ ព្រះអង្គមានបន្ទូលទៅកាន់ពួកគេថា៖ «ខ្ញុំទេ កុំខ្លាចអី»។ 21បន្ទាប់មក ពួកគេចង់ទទួលព្រះអង្គមកក្នុងទូកដែរ
ស្រាប់តែទូករបស់ពួកគេទៅដល់ច្រាំងជាកន្លែងដែលពួកគេចង់ទៅលួម។
22នៅថ្ងៃបន្ទាប់ បណ្ដាជនដែលឈរនៅត្រើយម្ខាងនៃសមុទ្របានឃើញថា គ្មានទូកណាទៀតឡើយ លើកលែងតែមួយ
ហើយពេលនោះព្រះយេស៊ូមិនបានចូលទៅក្នុងទូកជាមួយពួកសិស្សរបស់ព្រះអង្គទេ ពួកសិស្សចេញទៅតែពួកគេទេ។ 23ក៏មានទូកមកពីក្រុងទីបេរាស
ចូលទៅជិតកន្លែងដែលពួកគេបានបរិភោគនំប៉័ងបន្ទាប់ពីព្រះអង្គអរព្រះគុណ។
24នៅពេលបណ្ដាជនរកឃើញថា ព្រះយេស៊ូមិនបាននៅទីនោះជាមួយពួកសិស្សរបស់ព្រះអង្គ ពួកគេនាំគ្នាឡើងទូកទៅរកព្រះយេស៊ូនៅកាពើណិមខ្លួនគេ។
25បន្ទាប់ពីពួកគេបានរកព្រះអង្គឃើញនៅត្រើយម្ខាងនៃសមុទ្រហើយ ពួកគេនិយាយថាព្រះអង្គថា៖ «រ៉ាបី ព្រះអង្គមកទីនេះពេលណា?»
26ព្រះយេស៊ូឆ្លើយទៅកាន់ពួកគេ ដោយបន្ទូលថា៖ «ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នាស្វែងរកខ្ញុំ មិនមែនដោយចង់ឃើញទីសម្គាល់ទេ
ប៉ុន្តែដោយសារអ្នកចង់បរិភោគនំប៉័ង ហើយបានឆ្អែតប៉ុណ្ណោះ។ 27កុំធ្វើការដើម្បីឲ្យបានតែអាហារដែលពុករលួយ ប៉ុន្តែចូរធ្វើការដើម្បីឲ្យបានអាហារដែលស្ថិតស្ថេរ
ដើម្បីឲ្យបានជីវិតអស់កល្បជានិច្ច ដែលបុត្រមនុស្សនឹងផ្ដល់ឲ្យ ដើម្បីព្រះជាម្ចាស់ជាព្រះវរបិតាបានបោះត្រារបស់ព្រះអង្គនៅលើគាត់។
28ពួកគេទូលតបទៅកាន់ព្រះអង្គវិញថា៖ «តើយើងត្រូវធ្វើអ្វី ដើម្បីឲ្យយើងអាចធ្វើការរបស់ព្រះជាម្ចាស់បាន?» 29ព្រះយេស៊ូឆ្លើយ ហើយមានបន្ទូលទៅកាន់ពួកគេថា៖
«នេះគឺជាកិច្ចការរបស់ព្រះជាម្ចាស់៖ គឺថាអ្នករាល់គ្នាត្រូវជឿលើព្រះដែលព្រះអង្គបានចាត់មក»។
30ដូច្នេះ ពួកគេក៏ទូលទៅកាន់ព្រះអង្គថា៖ «តើលោកនឹងធ្វើទីសម្គាល់អ្វី ដើម្បីឲ្យយើងអាចឃើញ ហើយជឿលើលោកបាន?
31បុព្វបុរសរបស់យើងបានបរិភោគនំម៉ាណានៅឯទីរហោស្ថាន ដូចមានសេចក្ដីចែងមកថា៖ «ព្រះអង្គបានប្រទាននំប៉័ងពីស្ថានសួគ៌មកដល់ពួកគេបរិភោគ»។
32បន្ទាប់មក ព្រះយេស៊ូមានបន្ទូលឆ្លើយទៅពួកគេថា៖ «ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា មិនមែនលោកម៉ូសេទេ ដែលផ្ដល់នំប៉័ងពីស្ថានសួគ៌ដល់អ្នករាល់គ្នា
ប៉ុន្តែ ព្រះបិតាខ្ញុំទៅវិញទេ ដែលបានប្រទាននំប៉័ងដ៏ពិតដែលមកពីស្ថានសួគ៌ដល់អ្នករាល់គ្នា។ 33ដ្បិត នំប៉័ងរបស់ព្រះជាម្ចាស់ដែលបានធ្លាក់ចុះពីស្ថានសួគ៌មកនោះ
នឹងផ្ដល់ជីវិតដល់លោកីយ៍»។ 34ដូច្នេះ ពួកគេបានសួរព្រះអង្គថា «លោកម្ចាស់អើយ សូមឲ្យនំប៉័ងនេះដល់យើងរហូតមក»។
35ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «ខ្ញុំជានំប៉័ងជីវិត អ្នកណាដែលមកឯខ្ញុំនឹងមិនឃ្លានទៀតឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំនឹងមិនដែលស្រេកទៀតដែរ។ 36ប៉ុន្តែ
ខ្ញុំសូមប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នាបានឃើញខ្ញុំ ហើយអ្នករាល់គ្នាមិនបានជឿដល់ខ្ញុំទេ។ 37អស់អ្នកណាដែលព្រះបិតាប្រទានដល់ខ្ញុំ នឹងមកឯខ្ញុំ
ហើយអស់អ្នកណាដែលមកឯខ្ញុំ ខ្ញុំនឹងមិនបោះបង់ចោលគេឡើយ។
38ដ្បិតខ្ញុំបានចុះពីស្ថានសួគ៌មក មិនមែនដើម្បីធ្វើតាមចិត្តរបស់ខ្ញុំទេ ប៉ុន្តែធ្វើតាមព្រះហឫទ័យរបស់ព្រះដែលចាត់ខ្ញុំឲ្យមកវិញ។
39នេះគឺជាព្រះហឫទ័យរបស់ព្រះដែលចាត់ខ្ញុំឲ្យមក ដើម្បីកុំឲ្យខ្ញុំបាត់បង់នរណាម្នាក់ដែលព្រះអង្គបានប្រទានដល់ខ្ញុំឡើយ
ប៉ុន្តែនឹងប្រោសពួកគេឲ្យរស់ឡើងវិញនៅថ្ងៃចុងក្រោយ។ 40ដ្បិតនេះគឺជាព្រះហឫទ័យរបស់ព្រះបិតា ដែលថាមនុស្សគ្រប់គ្នាដែលបានឃើញព្រះបុត្រា
ហើយជឿលើព្រះអង្គនឹងមានជីវិតអស់កល្បជានិច្ច ហើយខ្ញុំនឹងប្រោសឲ្យគាត់រស់ឡើងវិញនៅថ្ងៃចុងក្រោយ។
41ពួកយូដាបានរអ៊ូរទាំអំពីព្រះអង្គ ដោយសារទ្រង់មានបន្ទូលថា៖ «ខ្ញុំជានំប៉័ងដែលចុះពីស្ថានសួគ៌មក»។ 42ពួកគេនិយាយថា៖ «តើយេស៊ូនេះ
មិនមែនជាកូនរបស់លោកយ៉ូសែប យើងបានស្គាល់ឪពុកនិងម្ដាយរបស់គាត់ទេឬអី? តើគាត់អាចនិយាយថា៖ «ខ្ញុំជានំប៉័ងដែលចុះមកពីស្ថានសួគ៌ដូចម្ដេចនឹងកើត?»

43ព្រះយេស៊ូឆ្លើយ ហើយមានបន្ទូលទៅកាន់ពួកគេថា៖ «ឈប់រអ៊ូរទាំនៅក្នុងចំណោមអ្នករាល់គ្នាទៀតទៅ។ 44គ្មាននរណាអាចមកឯខ្ញុំបានទេ
លុះត្រាតែព្រះបិតាដែលបានចាត់ខ្ញុំមកឲ្យចូលទៅជិតគាត់ ហើយខ្ញុំនឹងប្រោសគាត់ឲ្យរស់ឡើងវិញនៅថ្ងៃចុងក្រោយ។ 45ដូចមានសេចក្ដីចែងទុកក្នុងពួកព្យាការីថា៖
«ព្រះជាម្ចាស់នឹងបង្រៀនមនុស្សគ្រប់គ្នាដោយផ្ទាល់»។ មនុស្សគ្រប់គ្នាដែលបានឮ ហើយរៀនពីព្រះវរបិតានឹងមកឯខ្ញុំ។
46គ្មាននរណាម្នាក់បានឃើញព្រះបិតាឡើយ លើកលែងតែព្រះអង្គដែលមកពីព្រះជាម្ចាស់ ទ្រង់បានឃើញព្រះបិតា។ 47ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
អស់អ្នកណាដែលជឿនឹងមានជីវិតអស់កល្ប។
48ខ្ញុំជានំប៉័ងជីវិត។ 49បុព្វបុរសរបស់អ្នករាល់គ្នាបានបរិភោគនំម៉ាណានៅក្នុងទីរហោស្ថាន ហើយពួកគេបានស្លាប់។
50នេះគឺជានំប៉័ងដែលមកពីស្ថានសួគ៌ ដើម្បីឲ្យអស់អ្នកដែលបានបរិភោគនំប៉័ងនេះ នឹងមិនស្លាប់ទេ។ 51ខ្ញុំជានំប៉័ងដ៏រស់ដែលមកពីស្ថានសួគ៌។ ប្រសិនបើ
អ្នកណាម្នាក់បរិភោគនំប៉័ងនេះ អ្នកនោះនឹងរស់នៅជារៀងរហូត។ នំប៉័ងដែលខ្ញុំនឹងឲ្យគឺជារូបកាយរបស់ខ្ញុំ សម្រាប់ជីវិតរបស់មនុស្សលោក។
52ពួកយូដាបានខឹងគ្នាទៅវិញទៅមក ហើយចាប់ផ្ដើមឆ្លើយតប ដោយនិយាយថា៖
«តើបុរសនេះអាចឲ្យសាច់របស់ខ្ញុំមកយើងបរិភោគយ៉ាងដូចម្ដេចកើត?» 53បន្ទាប់មកព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
លុះត្រាតែអ្នកបរិភោគសាច់របស់កូនមនុស្ស ហើយផឹកឈាមរបស់គាត់ដែរ អ្នករាល់គ្នានឹងមិនអាចមានជីវិតនៅក្នុងអ្នករាល់គ្នាឡើយ។
54អស់អ្នកណាដែលបរិភោគសាច់ខ្ញុំ ហើយផឹកឈាមរបស់ខ្ញុំ នឹងមានជីវិតអស់កល្បជានិច្ច ហើយខ្ញុំនឹងប្រោសអ្នកនោះឲ្យរស់ឡើងវិញនៅថ្ងៃចុងក្រោយ។
55ដ្បិតសាច់របស់ខ្ញុំគឺជាអាហារដ៏ពិត ហើយឈាមរបស់ខ្ញុំគឺជាភេសជ្ជៈដ៏ពិត។ 56អស់អ្នកណាដែលបរិភោគសាច់របស់ខ្ញុំ ហើយផឹកឈាមរបស់ខ្ញុំនឹងនៅជាប់ជាមួយខ្ញុំ
ហើយខ្ញុំនៅក្នុងអ្នកនោះ។
57ព្រះបិតាដែលចាត់ខ្ញុំមកមានព្រះជន្មរស់ ខ្ញុំក៏រស់ដោយសារព្រះបិតាដូចគ្នាដែរ ដូច្នេះអស់អ្នកណាដែលបរិភោគខ្ញុំ អ្នកនោះនឹងបានរស់ដោយសារខ្ញុំដែរ។
58នេះគឺជានំប៉័ងដែលចុះពីស្ថានសួគ៌មក មិនដូចជានំប៉័ងដែលបុព្វបុរសរបស់អ្នករាល់គ្នាដែលបរិភោគហើយស្លាប់នោះទេ។
អ្នកណាដែលបរិភោគនំប៉័ងនេះនឹងរស់នៅអស់កល្បជានិច្ច»។ 59ប៉ុន្ដែព្រះយេស៊ូមានបន្ទូលការទាំងនេះនៅក្នុងសាលាប្រជុំ
អំឡុងពេលដែលព្រះអង្គបង្រៀននៅក្នុងកាពើណិម។
60បន្ទាប់មក ពួកសិស្សរបស់ព្រះអង្គជាច្រើនដែលបានឮព្រះអង្គមានបន្ទូលដូច្នេះ «នេះគឺជាសេចក្ដីបង្រៀនដ៏ពិបាកមួយ
តើអ្នកណាអាចទទួលយកបាន?» 61ដោយសារព្រះយេស៊ូជ្រាបនៅក្នុងអង្គទ្រង់ផ្ទាល់ថាពួកសិស្សទាំងនេះរអ៊ូរទាំពីការនេះ ទ្រង់មានបន្ទូលទៅកាន់ពួកគេថា៖
«តើការនេះធ្វើឲ្យអ្នករាល់គ្នារវាតចិត្ដមែនទេ?
62ចុះទំរាំបើអ្នកឃើញបុត្រមនុស្សឡើងទៅកន្លែងដែលព្រះអង្គគង់នៅពីមុន? 63គឺជាព្រះវិញ្ញាណដែលប្រទានជីវិត ហើយសាច់ឈាមគ្មានប្រយោជន៍អ្វីទាំងអស់។
ពាក្យដែលខ្ញុំបាននិយាយទៅកាន់អ្នករាល់គ្នាគឺជាវិញ្ញាណ ហើយពាក្យនោះគឺជាជីវិត។
64ប៉ុន្ដែក្នុងចំណោមអ្នករាល់គ្នាមានអ្នកខ្លះមិនបានជឿទេ»។ ដ្បិតព្រះយេស៊ូជ្រាបតាំងពីដំបូងថា តើនរណាដែលអាចនឹងមិនជឿ ហើយអ្នកណាអាចនឹងក្បត់ព្រះអង្គ។
65ព្រះអង្គមានបន្ទូលថា៖ «ដោយសារការនេះហើយបានជាខ្ញុំនិយាយទៅកាន់អ្នករាល់គ្នាថា គ្មាននរណាម្នាក់មកឯខ្ញុំបានទេ លុះត្រាតែព្រះបិតាចាត់អ្នកនោះឲ្យមក»។
66ដោយសារហេតុនេះ ពួកសិស្សរបស់ព្រះអង្គជាច្រើនបានចាកចេញពីព្រះអង្គ ហើយលែងដើរតាមព្រះអង្គទៀត។ 67បន្ទាប់មក
ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកសិស្សទាំងដប់ពីរនាក់ថា៖ «អ្នករាល់គ្នាមិនចង់ចេញពីខ្ញុំដូចគេដែលទេឬ?» 68លោកស៊ីម៉ូនពេត្រុសទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់អើយ
តើយើងគួរទៅតាមនរណា? ព្រះអង្គគឺជាព្រះបន្ទូលនៃជីវិតអស់កល្បជានិច្ច 69ហើយយើងបានជឿ ហើយស្គាល់ថា ព្រះអង្គគឺជាព្រះដ៏វិសុទ្ធរបស់ព្រះជាម្ចាស់។
70ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកគេថា៖ «តើមិនមែនខ្ញុំទេឬដែលជ្រើសរើសអ្នករាល់គ្នា ទាំងដប់ពីរនាក់នេះ
ហើយនឹងមានម្នាក់ក្នុងចំណោមអ្នករាល់គ្នាគឺជាមារ?» 71ព្រះអង្គមានបន្ទូលពីលោកយូដាសកូនរបស់លោកស៊ីម៉ូន អ៊ីស្ការីយ៉ុត ដ្បិត
គាត់ហើយគឺជាម្នាក់ក្នុងចំណោមសិស្សទាំងដប់ពីរដែលក្បត់ព្រះយេស៊ូ។

7 1បន្ទាប់ពីការទាំងនេះហើយ ព្រះយេស៊ូបានធ្វើដំណើរទៅកាលីឡេ ព្រោះព្រះអង្គមិនចង់ចូលទៅក្នុងស្រុកយូដា ដោយសារពួកយូដាកំពុងស្វែងរកធ្វើឃាតព្រះអង្គ។
2ឥឡូវនេះ ពិធីបុណ្យជម្រកបានជិតមកដល់ហើយ។
3ដូច្នេះ ប្អូនប្រុសៗរបស់ព្រះអង្គនិយាយទៅកាន់ព្រះអង្គថា៖ «ចូរចេញពីទីនេះ ហើយទៅស្រុកយូដាទៅ ដើម្បីឲ្យពួកសិស្សរបស់បងបានឃើញពីកិច្ចការដែលបងឯងធ្វើ។
4គ្មាននរណាអាចធ្វើអ្វីអាថ៌កំបាំងបានទេ ប្រសិនបើ គេចង់បើកឲ្យអ្នកដទៃដឹងជាសាធារណៈនោះ។ ប្រសិនបើ បងឯងធ្វើការទាំងនេះ
ចូរបងខ្លួនឯងបង្ហាញឲ្យមនុស្សលោកបានឃើញទៅ»។
5ដ្បិត សូម្បីតែប្អូនៗប្រុសរបស់ព្រះអង្គមិនបានជឿលើព្រះអង្គទេ។ 6ដូច្នេះហើយ បានជាព្រះអង្គមានបន្ទូលទៅកាន់ពួកគេថា៖ «មិនទាន់ដល់ពេលបងនៅឡើយទេ ប៉ុន្ដែ
ពេលវេលាប្អូនៗវិញរួចរាល់ជានិច្ច។ 7មនុស្សលោកមិនស្អប់ប្អូនៗទេ ប៉ុន្ដែ មនុស្សលោកស្អប់បងដោយសារ បងធ្វើបន្ទាល់ពីមនុស្សលោកថា
កិច្ចការរបស់មនុស្សលោកអាក្រក់។
8អ្នករាល់គ្នាចូលទៅចូលរួមបុណ្យទៅ បងមិនទៅបុណ្យនេះទេ ព្រោះពេលវេលារបស់បងមិនទាន់បានសម្រេចនៅឡើយទេ»។
9បន្ទាប់ពីព្រះអង្គមានបន្ទូលទៅកាន់ពួកគេពីការទាំងនេះហើយ ព្រះអង្គស្នាក់នៅក្នុងកាលីឡេដែរ។
10ប៉ុន្ដែ នៅពេលប្អូនៗរបស់ព្រះអង្គបានទៅចូលរួមពិធីបុណ្យហើយ ព្រះអង្គក៏ឡើងទៅដែរ ប៉ុន្ដែព្រះអង្គទៅដោយសម្ងាត់វិញ មិនទៅដោយបើកចំហទេ។
11ពួកយូដាស្វែងរកព្រះអង្គនៅថ្ងៃបុណ្យនោះ ហើយនិយាយថា៖ «តើលោកនោះនៅឯណា?»។
12មានការពិភាក្សាជាច្រើនអំពីព្រះអង្គនៅក្នុងចំណោមហ្វូងមនុស្ស។ អ្នកខ្លះនិយាយថា៖ «ព្រះអង្គជាមនុស្សល្អ»។ ហើយអ្នកខ្លះទៀតនិយាយថា៖ «អត់ទេ
ព្រះអង្គនាំហ្វូងមនុស្សឲ្យវង្វេង»។ 13យ៉ាងណាក្ដី គ្មាននរណាហ៊ាននិយាយពីព្រះអង្គនៅក្នុងទីសាធារណៈឡើយ ព្រោះខ្លាចពួកយូដា។
14ពេលពិធីបុណ្យចប់បានពាក់កណ្ដាលហើយ ព្រះយេស៊ូបានឡើងទៅហើយចូលទៅក្នុងព្រះវិហារ រួចក៏បង្រៀន។ 15បន្ទាប់មក ពួកយូដាមានការងឿងឆ្ងល់យ៉ាងខ្លាំង
ហើយនិយាយថា «លោកនេះ មិនដែលបានរៀនផង ម្ដេចក៏គាត់ដឹងច្រើនម្ល៉េះ?»។ 16ព្រះយេស៊ូឆ្លើយទៅពួកគេ ហើយមានបន្ទូលថា៖
«សេចក្ដីបង្រៀនរបស់ខ្ញុំមិនមែនមកពីខ្ញុំទេ ប៉ុន្ដែ មកពីព្រះអង្គដែលចាត់ខ្ញុំឲ្យមក។
17ប្រសិនបើនរណាម្នាក់ចង់ធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ អ្នកនោះនឹងដឹងអំពីសេចក្ដីបង្រៀននេះ ថាតើមកពីព្រះជាម្ចាស់ ឬខ្ញុំនិយាយចេញពីខ្លួនឯង។
18អ្នកណាដែលនិយាយពីខ្លួនឯង អ្នកនោះស្វែងរកសិរីល្អសម្រាប់ខ្លួនឯងហើយ ប៉ុន្ដែអ្នកណាដែលស្វែងរកសិរីល្អរបស់ព្រះអង្គដែលចាត់ខ្លួនឲ្យមក
អ្នកនោះជាមនុស្សពិតត្រង់ ហើយគ្មានសេចក្ដីទុច្ចរិតនៅក្នុងគាត់ឡើយ។
19តើមិនមែនជាលោកម៉ូសេទេឬអីដែលឲ្យក្រឹត្យវិន័យដល់អ្នករាល់គ្នា? ប៉ុន្ដ គ្មាននរណាម្នាក់នៅក្នុងចំណោមអ្នករាល់គ្នាធ្វើតាមទេ។
ហេតុអ្វីបានជាអ្នករាល់គ្នាស្វែងរកសម្លាប់ខ្ញុំ? 20ហ្វូងមនុស្សឆ្លើយថា៖ «ឯងមានវិញ្ញាណអាក្រក់។ តើអ្នកណាស្វែងរកសម្លាប់ឯង?
21ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកគេថា៖ «ខ្ញុំបានធ្វើការមួយ ហើយអ្នកទាំងអស់គ្នាបែរជាងឿងឆ្ងល់ដោយសារការនោះទៅវិញ។
22លោកម៉ូសេបានឲ្យអ្នករាល់គ្នាកាត់ស្បែក (មិនមែនមកពីលោកម៉ូសេទេ ប៉ុន្ដែមកពីដូនតារបស់អ្នករាល់គ្នាទេតើ) ហើយនៅថ្ងៃសប្ប័ទអ្នករាល់គ្នាក៏កាត់ស្បែកមនុស្សដែរ។
23ប្រសិនបើបុរសម្នាក់ទទួលការកាត់ស្បែកនៅថ្ងៃសប្ប័ទ ដូច្នេះគាត់បានធ្វើខុសនឹងក្រឹត្យវិន័យរបស់លោកម៉ូសេហើយ ហេតុអ្វីបានជាអ្នករាល់គ្នាខឹងនឹងខ្ញុំ
ដោយសារខ្ញុំធ្វើឲ្យបុរសម្នាក់បានជានៅថ្ងៃសប្ប័ទដូច្នេះ? 24កុំវិនិច្ឆ័យតាមលក្ខណៈខាងក្រៅ ប៉ុន្ដែចូរវិនិច្ឆ័យដោយសុចរិតវិញ»។

[25]មានអ្នកខ្លះនៅក្នុងចំណោមពួកគេមកពីក្រុងយេរូសាឡិមនិយាយថា៖ «តើលោកម្នាក់នេះមែនទេ ដែលគេស្វែងរកចង់សម្លាប់នោះ?[26]មើល គាត់និយាយនៅទីសាធារណៈ
ហើយពួកគេមិនបាននិយាយអ្វីទៅកាន់គាត់ឡើយ។ វាមិនអាចទៅជាបែបនឹងបានទេ អ្នកគ្រប់គ្រងប្រាកដជាដឹងថា លោកនេះគឺជាព្រះគ្រិស្ដហើយ តើអាចទេ?[27]ប៉ុន្តែ
យើងដឹងថាលោកនេះមកពីណា។ ប៉ុន្តែ នៅពេលព្រះគ្រិស្ដយាងមក គ្មាននរណាដឹងថាព្រះអង្គមកពីណាទេ»។
[28]ពេលនោះ ព្រះយេស៊ូស្រែកបង្រៀននៅក្នុងព្រះវិហារខ្លាំងៗ ដោយមានបន្ទូលថា៖ «អ្នករាល់គ្នាស្គាល់ខ្ញុំ ហើយដឹងថាខ្ញុំមកពីណា។ ខ្ញុំមិនបានមកដោយខ្លួនឯងទេ ប៉ុន្តែ
ព្រះអង្គទេដែលចាត់ខ្ញុំឲ្យមកពិតត្រង់ ហើយអ្នករាល់គ្នាមិនស្គាល់ព្រះអង្គទេ។[29]ខ្ញុំស្គាល់ព្រះអង្គ ដោយសារខ្ញុំមកពីព្រះអង្គ ហើយព្រះអង្គចាត់ខ្ញុំមក»។
[30]ពួកគេព្យាយាមចង់ចាប់ព្រះអង្គ ប៉ុន្តែគ្មាននរណាអាចចាប់ព្រះអង្គបានទេ ដោយសារពេលកំណត់របស់ព្រះអង្គមិនទាន់មកដល់នៅឡើយទេ។[31]ប៉ុន្តែ
មានមនុស្សជាច្រើននៅក្នុងហ្វូងមនុស្សបានជឿលើព្រះអង្គ ហើយនិយាយថា៖ «នៅពេលព្រះគ្រិស្ដយាងមក ព្រះអង្គនឹងធ្វើទីសម្គាល់ច្រើនជាងបុរសម្នាក់នេះបានធ្វើ?
[32]ពួកផារីស៊ីបានឮហ្វូងមនុស្សនិយាយខ្សិបខ្សៀវគ្នាការទាំងនេះអំពីព្រះយេស៊ូ ហើយនាយកបូជាចារ្យ និងពួកផារីស៊ីបានចាត់មន្ត្រីទៅចាប់ព្រះអង្គ។
[33]បន្ទាប់មកព្រះយេស៊ូមានបន្ទូលថា៖ «ខ្ញុំនៅជាមួយអ្នករាល់គ្នាតែបន្តិចទៀតទេ ហើយបន្ទាប់មកខ្ញុំនឹងត្រឡប់ទៅឯព្រះអង្គដែលចាត់ខ្ញុំឲ្យមកវិញ។
[34]អ្នករាល់គ្នានឹងស្វែងរកខ្ញុំ តែអ្នករាល់គ្នារកខ្ញុំមិនឃើញទេ កន្លែងដែលខ្ញុំទៅ អ្នកមិនអាចទៅបានទេ»។
[35]ដូច្នេះ ពួកយូដាបាននិយាយក្នុងចំណោមពួកគេថា៖ «តើបុរសម្នាក់នេះនឹងទៅណា ដែលយើងមិនអាចទៅរកគាត់ឃើញ? តើគាត់នឹងខ្ចាត់ខ្ចាយនៅក្នុងចំណោមពួកក្រិក
ហើយបង្រៀនដល់ពួកក្រិកដែរ?[36]តើពាក្យដែលគាត់និយាយថា៖ «អ្នកនឹងស្វែងរកខ្ញុំ តែរកកន្លែងដែលខ្ញុំទៅ មិនឃើញ
ហើយអ្នករាល់គ្នាមិនអាចទៅកន្លែងដែលខ្ញុំទៅបានទេ»។
[37]ឥឡូវនេះ ដល់ថ្ងៃចុងក្រោយ នៃពិធីបុណ្យដ៏ធំហើយ ព្រះយេស៊ូបានឈរឡើង ហើយស្រែកឮៗ ថា៖ «ប្រសិនបើ អ្នកណាម្នាក់ស្រេក ចូរឲ្យអ្នកនោះមកឯខ្ញុំ ហើយផឹកចុះ។
[38]អ្នកណាដែលជឿលើខ្ញុំ ដូចដែលបទគម្ពីរបានចែងថា ទន្លេទឹករស់នឹងហូរចេញពីពោះរបស់គាត់មក»។
[39]ប៉ុន្តែព្រះអង្គមានបន្ទូលការនេះអំពីព្រះវិញ្ញាណទេ ដែលអស់អ្នកណាដែលបានជឿលើព្រះអង្គហើយ នឹងបានទទួលព្រះវិញ្ញាណដែលមិនទាន់បានប្រទានមកនៅឡើយទេ
ដោយសារព្រះយេស៊ូមិនទាន់បានទទួលការលើកតម្កើងនៅឡើយ។
[40]មានខ្លះនៅក្នុងចំណោមហ្វូងមនុស្ស នៅពេលពួកគេឮពាក្យទាំងនេះ ពួកគេនិយាយថា៖ «លោកនេះគឺជាព្យាការីពិតប្រាកដមែន»។[41]ហើយអ្នកខ្លះទៀតនិយាយថា៖
«អ្នកនេះគឺជាព្រះគ្រិស្ដ»។ ប៉ុន្តែ អ្នកខ្លះនិយាយថា៖ «តើព្រះគ្រិស្ដមកពីកាលីឡេ?[42]តើបទគម្ពីរមិនបានចែងថា៖ «ព្រះគ្រិស្ដនឹងមកពីបេថ្លេហិម
តាមពូជពង្សរបស់ព្រះបាទដាវីឌ ជាភូមិដែលព្រះបាទដាវីឌបានកើតមកទេឬអី?»។
[43]ដូច្នេះក៏កើតមានការបែកបាក់នៅក្នុងចំណោមហ្វូងមនុស្សដោយសារព្រះអង្គ។[44]អ្នកខ្លះនៅក្នុងចំណោមពួកគេចង់ចាប់ព្រះអង្គ ប៉ុន្តែគ្មានអ្នកណាអាចចាប់ព្រះអង្គបានទេ។
[45]បន្ទាប់មកពួកមន្ត្រីបានត្រឡប់ទៅឯនាយកបូជាចារ្យ និងពួកផារីស៊ីវិញ ជាអ្នកដែលនិយាយទៅកាន់ពួកគេថា៖ «ហេតុអ្វីបានជាមិនចាប់គាត់មក?»[46]ពួកមន្ត្រីឆ្លើយថា៖
«គ្មាននរណាអាចនិយាយដូចគាត់ទេ»។
[47]ដូច្នេះ ពួកផារីស៊ីឆ្លើយទៅពួកគេថា៖ «អ្នករាល់គ្នាក៏ត្រូវបានគេបោកប្រាសដែរមែនទេ?[48]តើមានមេដឹកនាំឬពួកផារីស៊ីណាបានជឿដល់គាត់ទេ?
[49]ប៉ុន្តែហ្វូងមនុស្សដែលមិនស្គាល់ក្រឹត្យវិន័យនេះ ពួកគេត្រូវបណ្ដាសារហើយ។
[50]លោកនីកូដេម (ម្នាក់ក្នុងចំណោមពួកផារីស៊ី ដែលបានមករកព្រះអង្គកាលពីមុន) មានប្រសាសន៍ទៅពួកគេថា៖
[51]«តើក្រឹត្យវិន័យរបស់អ្នករាល់គ្នាវិនិច្ឆ័យមនុស្សមុនពេលអ្នកបានឮលោក និងបានដឹងនូវអ្វីដែលលោកបានធ្វើឬ?[52]ពួកគេឆ្លើយ ហើយនិយាយទៅកាន់ព្រះអង្គថា៖
«តើអ្នកក៏មកពីកាលីឡេដែរមែនទេ? ចូរស្វែងរកហើយមើល គ្មានព្យាការីណាមកពីកាលីឡេទេ»។
[53]បន្ទាប់មក មនុស្សគ្រប់គ្នាបានត្រឡប់ទៅផ្ទះរៀងៗខ្លួន។

8 [1]ព្រះយេស៊ូបានយាងឡើងទៅឯភ្នំអូលីវ។[2]លុះដល់ពេលព្រឹកព្រលឹម ព្រះអង្គបានយាងមកព្រះវិហារម្ដងទៀត ហើយមនុស្សទាំងអស់បានមក ព្រះអង្គក៏គង់ចុះ
ហើយបានបង្រៀនដល់ពួកគេ។[3]ពួកស្គាល់ច្បាស់ខាងវិន័យ និងពួកផារីស៊ីបាននាំស្ត្រីដែលគេចាប់បានម្នាក់ដោយសារការប្រព្រឹត្តអំពើកំផិតសាហាស្មន់។
ពួកគេបានដាក់នាងចំកណ្ដាល។
[4]បន្ទាប់មក ពួកគេបាននិយាយទៅកាន់ព្រះអង្គថា៖ «លោកគ្រូ ស្ត្រីម្នាក់នេះ គេចាប់បានក្នុងពេលដែលប្រព្រឹត្តអំពើកំផិតសាហាយស្មន់។[5]ឥឡូវនេះ
នៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេបានបង្គាប់ឲ្យយើងចោលមនុស្សបែបនេះនឹងដុំថ្ម តើលោកគ្រូ យល់យ៉ាងណាដែរ?»[6]ពួកគេនិយាយយ៉ាងដូច្នេះ ដើម្បីចាប់ព្រះអង្គ
ធ្វើដូច្នេះ ដើម្បីឲ្យពួកគេមានអ្វីមួយដើម្បីចោទប្រកាន់ព្រះអង្គ ប៉ុន្តែ ព្រះយេស៊ូបានឱនចុះ ហើយសរសេរនៅលើដីដោយប្រើម្រាមដៃរបស់ព្រះអង្គ។
[7]នៅពេលពួកគេបន្តសួរសំណួរព្រះអង្គជាច្រើន ព្រះអង្គក៏ក្រោកឈរឡើង ហើយមានបន្ទូលទៅកាន់ពួកគេថា៖
«បើមាននរណាម្នាក់នៅក្នុងចំណោមអ្នករាល់គ្នាដែលគ្មានបាប ចូរឲ្យអ្នកនោះចោលនាងនឹងដុំថ្មមុនគេទៅ!»។[8]រួចព្រះអង្គក៏អង្គុយចុះវិញ
ហើយសរសេរនៅលើដីដោយប្រើម្រាមដៃរបស់ព្រះអង្គម្ដងទៀត។
[9]នៅពេលពួកគេឮដូច្នេោះ ពួកគេបានចេញពីទីនោះម្នាក់ម្ដងៗ ចាប់ផ្ដើមពីមនុស្សចាស់ជាងគេបំផុត។ ទីបំផុត នៅសល់តែព្រះអង្គ
នៅជាមួយនាងដែលគេយកមកដាក់នៅចំកណ្ដាលនោះ។[10]ព្រះយេស៊ូបានក្រោកឈរឡើង ហើយមានបន្ទូលទៅនាងថា៖ «នាងអើយ
តើអ្នកចោទប្រកាន់នាងទៅណាអស់ហើយ? តើមាននរណាម្នាក់ដាក់ទោសនាងទេ?[11]នាងទូលតបថា៖ «អត់មានទេ ព្រះអម្ចាស់»។ ព្រះយេស៊ូមានបន្ទូលថា៖
«ខ្ញុំក៏មិនដាក់ទោសនាងដែរ។ ទៅចុះ ហើយកុំធ្វើបាបទៀត»។
[12]ព្រះយេស៊ូបានមានបន្ទូលទៅកាន់ពួកគេម្ដងទៀតដោយមានបន្ទូលថា៖ «ខ្ញុំជាពន្លឺនៃលោកីយ៍ អ្នកណាដែលដើរតាមខ្ញុំនឹងមិនដើរក្នុងសេចក្ដីងងឹតឡើយ ប៉ុន្តែ
នឹងមានពន្លឺនៃជីវិតវិញ។[13]ពួកផារីស៊ីនិយាយទៅកាន់ព្រះអង្គថា៖ «អ្នកធ្វើបន្ទាល់ពីខ្លួនឯង ទីបន្ទាល់របស់អ្នកមិនពិតទេ»។
[14]ព្រះយេស៊ូមានបន្ទូលឆ្លើយ ហើយមានបន្ទូលថា៖ «ទោះបើខ្ញុំធ្វើបន្ទាល់ពីខ្លួនខ្ញុំក្ដី ទីបន្ទាល់របស់ខ្ញុំជាសេចក្ដីពិត។ ខ្ញុំដឹងថាខ្ញុំមកពីណា ហើយខ្ញុំកំពុងទៅណា ប៉ុន្តែ
អ្នករាល់គ្នាមិនដឹងថា ខ្ញុំមកពីណា ឬខ្ញុំកំពុងទៅណាទេ។[15]អ្នករាល់គ្នាវិនិច្ឆ័យខ្ញុំតាមរបៀបសាច់ឈាម តែខ្ញុំមិនវិនិច្ឆ័យនរណាម្នាក់ឡើយ។[16]ប៉ុន្តែ ប្រសិនបើ ខ្ញុំវិនិច្ឆ័យវិញ
សេចក្ដីវិនិច្ឆ័យរបស់ខ្ញុំគឺជាសេចក្ដីពិត ព្រោះខ្ញុំមិនមែនមានតែម្នាក់ឯង ប៉ុន្តែ ខ្ញុំនៅជាមួយព្រះបិតាដែលចាត់ខ្ញុំឲ្យមក។
[17]ពិតណាស់ នៅក្នុងក្រឹត្យវិន័យរបស់អ្នករាល់គ្នា បានចែងថា ទីបន្ទាល់ដែលមានគ្នាពីរនាក់ឡើងទៅជាសេចក្ដីពិត។[18]ខ្ញុំគឺជាអ្នកដែលធ្វើបន្ទាល់អំពីខ្លួនខ្ញុំ
ហើយព្រះបិតាដែលចាត់ខ្ញុំមក ព្រះអង្គក៏ធ្វើបន្ទាល់ពីខ្ញុំដែរ»។
[19]ពួកគេទូលទៅកាន់ព្រះអង្គថា៖ «ព្រះបិតារបស់លោកនៅឯណា?» ព្រះយេស៊ូមានបន្ទូលឆ្លើយថា៖ «អ្នករាល់គ្នាមិនស្គាល់ខ្ញុំ ហើយក៏មិនស្គាល់ព្រះបិតាដែរ ប្រសិនបើ
អ្នករាល់គ្នាស្គាល់ខ្ញុំ អ្នករាល់គ្នាក៏ស្គាល់ព្រះបិតារបស់ខ្ញុំដែរ»។[20]ព្រះអង្គមានបន្ទូលសេចក្ដីទាំងនេះ ក្នុងការដែលព្រះអង្គបង្រៀននៅជិតឃ្លាំងក្នុងព្រះវិហារ
ហើយគ្មាននរណាអាចចាប់ព្រះអង្គបានទេ ព្រោះពេលកំណត់របស់ព្រះអង្គមិនទាន់មកដល់ទេ។
[21]ដូច្នេះ ព្រះអង្គក៏មានបន្ទូលទៅពួកគេម្ដងទៀតថា៖ «ខ្ញុំនឹងទៅឆ្ងាយ អ្នកនឹងស្វែងរកខ្ញុំ ហើយនឹងស្លាប់នៅក្នុងបាបរបស់អ្នករាល់គ្នា។ កន្លែងដែលខ្ញុំទៅ
អ្នករាល់គ្នាមិនអាចទៅបានទេ»។[22]ពួកយូដានិយាយថា៖ «គាត់នឹងសម្លាប់ខ្លួនឯងមែនទេ? ហេតុដូច្នេះ បានជាគាត់និយាយថា៖ «កន្លែងដែលខ្ញុំទៅ
អ្នកមិនអាចទៅបាន?»។

[23]ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «អ្នករាល់គ្នានៅខាងក្រោម ខ្ញុំមកពីខាងលើ។ អ្នករាល់គ្នាជារបស់លោកីយ៍នេះ ខ្ញុំវិញមិនមែនរបស់លោកីយ៍នេះទេ។[24]ហេតុនេះហើយ
បានជាខ្ញុំប្រាប់អ្នករាល់គ្នាថា អ្នករាល់គ្នានឹងត្រូវស្លាប់ ទាំងមានបាបជាប់ក្នុងខ្លួន។ បើអ្នករាល់គ្នាមិនព្រមទទួលស្គាល់ឋានៈរបស់ខ្ញុំទេ អ្នករាល់គ្នានឹងត្រូវស្លាប់ ទាំងមាន
បាបជាប់ក្នុងខ្លួនជាមិនខាន»។
[25]ដូច្នេះហើយ បានជាពួកគេនិយាយទៅកាន់ព្រះអង្គថា៖ «តើលោកជានរណា?» ព្រះយេស៊ូឆ្លើយទៅកាន់ពួកគេថា៖
«អ្វីដែលខ្ញុំបាននិយាយទៅកាន់អ្នករាល់គ្នាតាំងពីដំបូង។[26]ខ្ញុំមានការជាច្រើនត្រូវនិយាយ ហើយវិនិច្ឆ័យអ្នករាល់គ្នា។ ប៉ុន្តែព្រះអង្គដែលចាត់ខ្ញុំឲ្យមកជាសេចក្ដីពិត
ហើយការអ្វីដែលខ្ញុំបានឮពីព្រះអង្គ ការទាំងនេះហើយ ខ្ញុំនិយាយទៅកាន់លោកីយ៍»។[27]ពួកគេមិនយល់ថាព្រះអង្គកំពុងមានបន្ទូលទៅកាន់ពួកគេអំពីព្រះបិតាទេ។
[28]ព្រះយេស៊ូមានបន្ទូលថា៖ «នៅពេលដែលអ្នករាល់គ្នាលើកតម្កើងបុត្រមនុស្សឡើង នោះអ្នករាល់គ្នានឹងដឹងថាខ្ញុំគឺជាព្រះ ហើយដឹងថា ខ្ញុំធ្វើអ្វីៗមិនមែនចេញពីខ្លួនខ្ញុំទេ។
បើព្រះបិតាបង្រៀនអ្វីដល់ខ្ញុំ ខ្ញុំនិយាយការទាំងនោះ។[29]ព្រះអង្គដែលចាត់ខ្ញុំមក ព្រះអង្គគង់នៅជាមួយខ្ញុំ ហើយព្រះអង្គមិនទុកខ្ញុំចោលឲ្យនៅម្នាក់ឯងឡើយ
ព្រោះខ្ញុំតែងតែធ្វើអ្វីដែលគាប់ព្រះហឫទ័យដល់ព្រះអង្គជានិច្ច»។[30]បន្ទាប់ពីព្រះយេស៊ូមានបន្ទូលការទាំងនេះហើយ មនុស្សជាច្រើនបានជឿលើព្រះអង្គ។
[31]ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកយូដាដែលបានជឿលើព្រះអង្គថា៖ «ប្រសិនបើ អ្នករាល់គ្នានៅជាប់នឹងពាក្យខ្ញុំ ដូច្នេះ អ្នករាល់គ្នាពិតជាសិស្សរបស់ខ្ញុំមែន។
[32]ហើយអ្នកនឹងស្គាល់សេចក្ដីពិត ហើយសេចក្ដីពិតនឹងរំដោះអ្នករាល់គ្នាឲ្យបានរួច»។[33]ពួកគេឆ្លើយទៅកាន់ព្រះអង្គថា៖ «យើងគឺជាពូជពង្សរបស់លោកអប្រាហាំ
ហើយយើងមិនដែលធ្លាប់ធ្វើជាទាសកររបស់នរណាម្នាក់ទេ តើអ្នកអាចនិយាយថា អ្នកនឹងរំដោះយើងឲ្យមានសេរីភាពដូចម្ដេចនឹងកើត?»
[34]ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកគេថា៖ «ពិតណាស់ ខ្ញុំសូមប្រាប់អ្នករាល់គ្នាជាប្រាកដថា មនុស្សគ្រប់គ្នាដែលធ្វើបាប គឺជាទាសកររបស់បាប។
[35]ទាសករមិននៅជាប់ក្នុងផ្ទះរហូតទេ ប៉ុន្តែ កូនទេដែលនៅជាប់ជារៀងរហូត។[36]ដូច្នេះហើយ ប្រសិនបើ កូននោះរំដោះអ្នករាល់គ្នាឲ្យមានសេរីភាព
អ្នកនឹងមានសេរីភាពជាប្រាកដ។
[37]ខ្ញុំនឹងថា អ្នករាល់គ្នាជាពូជពង្សរបស់លោកអប្រាហាំ អ្នករាល់គ្នាស្វែងរកចង់សម្លាប់ខ្ញុំ ដោយសារពាក្យរបស់ខ្ញុំមិននៅក្នុងអ្នករាល់គ្នាទេ។
[38]ខ្ញុំនិយាយអ្វីដែលខ្ញុំបានឃើញព្រះបិតារបស់ខ្ញុំ ហើយអ្នករាល់គ្នាក៏ធ្វើអ្វីតាមដែលអ្នករាល់គ្នាបានឮពីឪពុករបស់អ្នករាល់គ្នាដែរ»។
[39]ពួកគេឆ្លើយ និងទូលទៅកាន់ព្រះអង្គថា៖ «ឪពុករបស់យើងគឺលោកអប្រាហាំ»។ ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកគេថា៖ «ប្រសិនបើ អ្នករាល់គ្នាជាកូនរ
បស់លោកអប្រាហាំមែន អ្នកនឹងធ្វើការរបស់លោកអប្រាហាំដែរ។[40]ផ្ទុយទៅវិញ អ្នកបែរជាស្វែងរកចង់សម្លាប់ខ្ញុំវិញ គឺជាម្នាក់ដែលនិយាយប្រាប់អ្នករាល់គ្នាពីសេចក្ដីពិត
ដែលខ្ញុំបានឮពីព្រះជាម្ចាស់មក។ លោកអប្រាហាំមិនបានធ្វើការនេះទេ។[41]អ្នករាល់គ្នាមិនបានធ្វើការរបស់ឪពុកអ្នករាល់គ្នាឡើយ»។ ពួកគេនិយាយទៅកាន់ព្រះអង្គថា៖
«យើងមិនបានកើតពីអំពើបាបអសីលធម៌ខាងផ្លូវភេទឡើយ យើងមានឪពុកតែមួយគឺ ព្រះជាម្ចាស់»។
[42]ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកគេថា៖ «ប្រសិនបើ ព្រះជាម្ចាស់ជាព្រះបិតារបស់អ្នករាល់គ្នាមែន អ្នករាល់គ្នាមុខជាស្រឡាញ់ខ្ញុំមិនខាន ដ្បិត ខ្ញុំបានមកពីព្រះជាម្ចាស់
ហើយខ្ញុំនៅទីនេះហើយ ព្រោះខ្ញុំមិនបានមកដោយខ្លួនខ្ញុំទេ ប៉ុន្តែ ព្រះអង្គទេ ដែលចាត់ខ្ញុំឲ្យមក។[43]ហេតុអ្វីបានជាអ្នករាល់គ្នាមិនយល់ពាក្យខ្ញុំ?
នោះគឺដោយសារអ្នករាល់គ្នាមិនអាចឮពាក្យរបស់ខ្ញុំ។[44]អ្នករាល់គ្នាកើតចេញពីឪពុករបស់អ្នករាល់គ្នា គឺជាមារ
ហើយអ្នករាល់គ្នាធ្វើដែលអ្នករាល់គ្នាចង់ធ្វើគឺធ្វើតាមបំណងចិត្តឪពុករបស់អ្នករាល់គ្នា។ ឪពុករបស់អ្នករាល់គ្នាគឺជាឃាតករតាំងពីដំបូង
ហើយមិនបានឈរនៅក្នុងសេចក្ដីពិតទេ ដោយសារគ្មានសេចក្ដីពិតនៅក្នុងគាត់ទេ។ នៅពេលដែលគាត់និយាយកុហក គាត់និយាយចេញពីនិស្ស័យរបស់គាត់ផ្ទាល់
ព្រោះគាត់គឺជាអ្នកកុហក ហើយជាឪពុកនៃសេចក្ដីកុហក។
[45]ប៉ុន្តែ នៅពេលដែលខ្ញុំនិយាយសេចក្ដីពិត អ្នករាល់គ្នាមិនជឿដល់ខ្ញុំ។[46]តើអ្នកណាក្នុងចំណោមអ្នករាល់គ្នា អាចបង្ហាញដល់ខ្ញុំបានទេ ពីបាបរបស់ខ្ញុំ? ប្រសិនបើ
ខ្ញុំនិយាយសេចក្ដីពិត ហេតុអ្វីបានជាអ្នករាល់គ្នាមិនជឿខ្ញុំ?[47]អ្នកដែលកើតមកពីព្រះជាម្ចាស់ឮព្រះបន្ទូលរបស់ព្រះជាម្ចាស់
អ្នកមិនបានឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយសារអ្នករាល់គ្នាមិនកើតមកពីព្រះជាម្ចាស់។
[48]ពួកយូដាឆ្លើយ ហើយនិយាយទៅកាន់ព្រះអង្គថា៖ «តើយើងពិតជាបាននិយាយថា អ្នកគឺជាសាសន៍សាម៉ារី ហើយមានវិញ្ញាណអាក្រក់មែន?»[49]ព្រះយេស៊ូឆ្លើយថា៖
«ខ្ញុំគ្មានវិញ្ញាណអាក្រក់ទេ ប៉ុន្តែ ខ្ញុំគោរពព្រះបិតាខ្ញុំ ហើយអ្នករាល់គ្នាមិនបានគោរពដល់ខ្ញុំទេ។
[50]ខ្ញុំមិនបានស្វែករកសិរីល្អរបស់ខ្ញុំទេ មានព្រះមួយអង្គដែលស្វែងរក ហើយវិនិច្ឆ័យ។[51]ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ប្រសិនបើ
អ្នកណាប្រព្រឹត្តតាមពាក្យរបស់ខ្ញុំ អ្នកនោះនឹងមិនឃើញសេចក្ដីស្លាប់ឡើយ»។
[52]ពួកយូដាទូលទៅកាន់ព្រះអង្គថា៖ «ឥឡូវនេះ យើងដឹងថា អ្នកមានវិញ្ញាណអាក្រក់មែន។ លោកអប្រាហាំ និងពួកព្យាការីបានស្លាប់ហើយ ប៉ុន្តែ អ្នកនិយាយថា៖
«ប្រសិនបើ អ្នកណាប្រព្រឹត្តតាមពាក្យខ្ញុំ អ្នកនោះនឹងមិនស្គាល់សេចក្ដីស្លាប់ឡើយ។[53]អ្នកមិនធំជាងលោកអប្រាហាំជាឪពុករបស់យើងដែលបានស្លាប់ទៅទេ តើមែនទេ?
ពួកព្យាការីក៏បានស្លាប់ដែរ។ តើអ្នកតាំងខ្លួនអ្នកជានរណា?
[54]ព្រះយេស៊ូមានបន្ទូលឆ្លើយថា៖ «ប្រសិនបើ ខ្ញុំតម្កើងខ្លួនឯង សិរីល្អរបស់ខ្ញុំនោះគ្មានន័យអ្វីទេ ព្រះបិតារបស់ខ្ញុំទេតើដែលលើកតម្កើងខ្ញុំ
តែចំពោះព្រះអង្គដែលអ្នករាល់គ្នានិយាយថា៖ «ទ្រង់គឺជាព្រះជាម្ចាស់របស់អ្នករាល់គ្នា»។[55]អ្នករាល់គ្នាមិនបានស្គាល់ព្រះអង្គទេ ប៉ុន្តែ ខ្ញុំស្គាល់ព្រះអង្គ។ ប្រសិនបើ
ខ្ញុំអាចនិយាយថា៖ «ខ្ញុំមិនស្គាល់ព្រះអង្គ ខ្ញុំក៏ដូចជាអ្នករាល់គ្នាដែរ ជាមនុស្សកុហក»។ ប៉ុន្តែ ខ្ញុំបានស្គាល់ព្រះអង្គ ហើយប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះអង្គ។
[56]លោកអប្រាហាំជាឪពុករបស់អ្នករាល់គ្នា មានអំណរនឹងក្នុងការឃើញថ្ងៃរបស់ខ្ញុំ គាត់បានឃើញ ហើយគាត់ក៏មានអំណរដែរ»។
[57]ពួកយូដាបានទូលទៅកាន់ព្រះអង្គថា៖ «អ្នកមិនទាន់មានអាយុហាសិបឆ្នាំផង តើអ្នកបានឃើញអប្រាហាំដូចម្ដេចកើត?»[58]ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖
«ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា មុនលោកអប្រាហាំ ខ្ញុំជាព្រះរួចទៅហើយ»។[59]ពួកគេបានរើសដុំថ្ម ចោលទៅកាន់ព្រះអង្គ ប៉ុន្តែព្រះយេស៊ូបានលាក់ខ្លួនព្រះអង្គ
ហើយចេញពីព្រះវិហារបាត់ទៅ។

9 [1]ក្នុងកាលដែលព្រះយេស៊ូយាងកាត់ផ្លូវ ព្រះអង្គទតឃើញបុរសពិការភ្នែកម្នាក់តាំងពីកំណើត។[2]ពួកសិស្សរបស់ព្រះអង្គទូលសួរព្រះអង្គថា៖ «រ៉ាប៊ី តើនរណាបានធ្វើបាប
បុរសនេះ ឬឪពុកម្ដាយរបស់គាត់ បានជាធ្វើឲ្យគាត់ពិការភ្នែកតាំងពីកំណើតយ៉ាងនេះ?»។
[3]ព្រះយេស៊ូឆ្លើយថា៖ «មិនមែនបុរសនេះ ឬឪពុកម្ដាយរបស់គាត់ធ្វើបាបទេ ប៉ុន្តែ គាត់ពិការភ្នែកដូច្នេះ ដើម្បីឲ្យព្រះបង្ហាញកិច្ចការរបស់ព្រះអង្គនៅក្នុងគាត់។
[4]យើងត្រូវធ្វើកិច្ចការរបស់ព្រះអង្គ ដែលចាត់ខ្ញុំឲ្យមកទាន់នៅពេលថ្ងៃនៅឡើយ។ ពេលយប់ជិតមកដល់ហើយ នៅពេលដែលគ្មាននរណាម្នាក់មិនអាចធ្វើការបាន។
[5]ក្នុងពេលដែលខ្ញុំនៅក្នុងពិភពលោកនេះនៅឡើយ ខ្ញុំគឺជាពន្លឺនៃលោកីយ៍»។
[6]បន្ទាប់ពីព្រះយេស៊ូមានបន្ទូលការទាំងនេះហើយ ព្រះអង្គបានស្ដោះទឹកមាត់ទៅដី យកទឹកមាត់ធ្វើជាភក់ ហើយលាបភក់នោះនៅលើភ្នែករបស់គាត់។
[7]ព្រះអង្គមានបន្ទូលទៅគាត់ថា៖ «ចូរទៅលាងនៅក្នុងស្រះទឹកស៊ីឡោម (ដែលប្រែថា ចាត់ឲ្យទៅ)»។ បុរសនោះក៏ចេញទៅ បានលាង
ហើយបានត្រឡប់មកវិញទាំងមើលឃើញ។
[8]បន្ទាប់មក អ្នកជិតខាងរបស់បុរសនោះ និងអស់អ្នកដែលធ្លាប់បានឃើញគាត់ ដែលធ្លាប់ជាអ្នកសុំទានពីមុន បាននិយាយថា៖ «តើបុរសនេះ
មិនមែនជាម្នាក់ដែលធ្លាប់អង្គុយ ហើយសុំទានទេឬអី?»[9]អ្នកខ្លះនិយាយថា៖ «គឺគាត់និងហើយ»។ អ្នកខ្លះទៀតនិយាយថា៖ «មិនមែនទេ ប៉ុន្តែ
គាត់គ្រាន់តែដូចអ្នកនោះប៉ុណ្ណោះ»។ ប៉ុន្តែ បុរសនោះនិយាយថា៖ «គឺខ្ញុំនិងហើយ»។


generated on Fri Jun 6 10:45:59 2025

10ពួកគេនិយាយទៅកាន់គាត់ថា៖ «តើភ្នែករបស់អ្នកអាចមើលឃើញយ៉ាងដូចម្ដេច?»11គាត់បានឆ្លើយថា៖ «បុរសម្នាក់ដែលគេហៅថា យេស៊ូបានយកភក់
ហើយបានយកវាមកដាក់លាបនៅលើភ្នែករបស់ខ្ញុំ ហើយមានបន្ទូលមកខ្ញុំថា៖ «ចូរទៅស្រះទឹកស៊ីឡោម ហើយលាងទៅ»។ ដូច្នេះ ខ្ញុំក៏ទៅ ហើយបានលាងទឹក
ភ្នែករបស់ខ្ញុំក៏ភ្លឺឡើង»។12ពួកគេនិយាយទៅកាន់គាត់ថា៖ «តើគាត់នៅឯណា?» គាត់បានឆ្លើយថា៖ «ខ្ញុំមិនដឹងទេ»។
13ពួកគេបាននាំបុរសម្នាក់ដែលខ្វាក់ពីមុននោះទៅជួបពួកផារីស៊ី។14នៅថ្ងៃដែលព្រះយេស៊ូបានយកភក់ ហើយធ្វើឲ្យភ្នែកអ្នកពិការនោះភ្លឺគឺជាថ្ងៃសប្ប័ទ។
15ហើយពួកផារីស៊ីបានសួរគាត់ម្ដងទៀត ពីការដែលភ្នែករបស់គាត់ភ្លឺឡើងនោះ។ គាត់និយាយទៅកាន់ពួកគេថា «គាត់យកភក់មកដាក់លើភ្នែករបស់ខ្ញុំ ហើយខ្ញុំក៏ទៅលាង
នៅពេលឥឡូវនេះ ខ្ញុំអាចមើលឃើញ»។
16ពួកផារីស៊ីខ្លះបាននិយាយថា៖ «បុរសនេះមិនមែនមកពីព្រះជាម្ចាស់ទេ ព្រោះគាត់មិនបានគោរពតាមថ្ងៃសប្ប័ទ»។ ហើយអ្នកខ្លះទៀតនិយាយថា៖
«បើបុរសនេះជាមនុស្សមានបាបមែន តើគាត់អាចធ្វើទីសម្គាល់ផ្សេងៗដូចម្ដេចកើត?» ដូច្នេះ ក៏មានជម្លោះកើតឡើងនៅក្នុងចំណោមពួកគេ។17ដូច្នេះ
ពួកគេបានសួរទៅបុរសពិការភ្នែកម្ដងទៀតថា៖ «តើអ្នកគិតថាអ្នកនោះជានរណា នៅពេលដែលអ្នកនោះបានធ្វើឲ្យភ្នែករបស់អ្នកបានភ្លឺ?»។
បុរសពិការភ្នែកនោះនិយាយថា៖ «គាត់ជាព្យាការី»។18ហើយពួកគេយូដានៅតែមិនជឿគាត់ថា គាត់ពិការ ហើយអាចមើលឃើញឡើង
ទាល់តែគេហៅឪពុកម្ដាយរបស់អ្នកដែលបានភ្លឺភ្នែកនេះមក។
19ពួកគេបានសួរទៅឪពុកម្ដាយថា៖ «តើនេះគឺជាកូនរបស់ពួកអ្នក ដែលអ្នកនិយាយថាជាអ្នកពិការភ្នែកតាំងពីកំណើតមែនទេ? តើឥឡូវនេះ
គាត់បានមើលឃើញវិញយ៉ាងដូចម្ដេច?»20ដូច្នេះ ឪពុកម្ដាយរបស់គាត់បានឆ្លើយទៅពួកគេវិញថា៖ «យើងដឹងថា នេះគឺជាកូនរបស់យើងខ្ញុំ
ហើយថាគាត់បានពិការតាំងពីកំណើតមកមែន។21ពីការដែលគាត់មើលឃើញឥឡូវនេះ យើងខ្ញុំមិនដឹងទេ ហើយអ្នកណាបានធ្វើឲ្យភ្នែករបស់គាត់បានភ្លឺ
ក៏យើងមិនដឹងដែរ។ សូមសួរគាត់ទៅ គឺគាត់ពេញវ័យហើយ។ គាត់អាចឆ្លើយបាន»។
22ឪពុកម្ដាយរបស់គាត់បាននិយាយការទាំងនេះ ដោយសារពួកគាត់ភ័យខ្លាចនឹងសាសន៍យូដា។ ដ្បិតសាសន៍យូដាបានព្រមព្រៀងគ្នារួចស្រេចហើយថា
ប្រសិនបើនរណាប្រកាសពីព្រះអង្គថាជាព្រះគ្រិស្ដ ពួកគេនឹងត្រូវបណ្ដេញចេញពីសាលាប្រជុំ។23ដោយហេតុនេះហើយ ឪពុកម្ដាយរបស់គាត់បាននិយាយថា៖
«គាត់ពេញវ័យហើយ សួរគាត់ទៅ»។
24ដូច្នេះ ពួកគេបានហៅបុរសដែលពិការភ្នែកនោះមកជាលើកទីពីរ ហើយនិយាយទៅគាត់ថា៖ «ថ្វាយសិរីល្អដល់ព្រះជាម្ចាស់។ យើងដឹងថា
បុរសម្នាក់នេះជាមនុស្សមានបាប»។25បន្ទាប់មក បុរសនោះបានឆ្លើយថា៖ «ខ្ញុំអត់ដឹងទេ ថាគាត់ជាមនុស្សមានបាបមែនឬយ៉ាងណា។ ប៉ុន្តែ ការមួយដែលខ្ញុំដឹងគឺ
ពីមុនខ្ញុំពិការ ហើយឥឡូវខ្ញុំមើលឃើញហើយ»។
26ពួកគេនិយាយទៅកាន់គាត់ថា៖ «តើគាត់បានធ្វើអ្វីដល់អ្នក? តើគាត់បានធ្វើឲ្យភ្នែករបស់អ្នកបានភ្លឺយ៉ាងដូចម្ដេច?»27គាត់ឆ្លើយថា៖ «ខ្ញុំបានប្រាប់អស់លោករួចហើយ
តែអស់លោកមិនព្រមស្ដាប់ ហេតុអ្វីបានជាអស់លោកចង់ឮវាម្ដងទៀត?28ក្រែងអស់លោកមិនចង់ធ្វើជាសិស្សរបស់គាត់ តើមែនទេ? ពួកគេក៏ប្រមាថគាត់
ហើយនិយាយទៅគាត់ថា៖ «តើអ្នកជាសិស្សរបស់គាត់មែនទេ ប៉ុន្តែ យើងជាសិស្សរបស់លោកម៉ូសេ។29យើងដឹងថាព្រះជាម្ចាស់បានមានបន្ទូលជាមួយនឹងលោកម៉ូសេ
ប៉ុន្តែ យើងមិនដឹងថា លោកម្នាក់នេះមកពីណាទេ»។
30បុរសនោះបានឆ្លើយ ហើយនិយាយទៅកាន់ពួកគេថា៖ «គួរឲ្យអស្ចារ្យណាស់ ដែលអស់លោកមិនដឹងថាគាត់មកពីណាទេ ប៉ុន្តែគាត់បានធ្វើឲ្យភ្នែករបស់ខ្ញុំភ្លឺ។
31យើងដឹងថាព្រះជាម្ចាស់មិនស្ដាប់មនុស្សមានបាប ប៉ុន្តែ ប្រសិនបើ នរណាម្នាក់កោតខ្លាច ហើយធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ នោះទ្រង់នឹងស្ដាប់គាត់។
32តាំងពីលោកីយ៍បានកើតមក មិនដែលបានឮនរណាម្នាក់ធ្វើឲ្យភ្នែករបស់បុរសដែលពិការតាំងពីកំណើតភ្លឺឡើងវិញទេ។33ប្រសិនបើ បុរសនេះមិនបានមកពីព្រះជាម្ចាស់
លោកនឹងមិនអាចធ្វើអ្វីបានទាំងអស់។34ពួកគេឆ្លើយហើយនិយាយទៅកាន់គាត់ថា៖ «អ្នកកើតមកនៅក្នុងអំពើបាបពិតប្រាកដមែន ហើយអ្នកមកបង្រៀនយើងមែនទេ?»
បន្ទាប់មក ពួកគេបានបណ្ដេញគាត់ចេញទៅក្រៅ។
35ព្រះយេស៊ូបានឮថា ពួកគេបានបណ្ដេញគាត់ចេញក្រៅពីសាលាប្រជុំ។ ព្រះអង្គបានទៅជួបគាត់ ហើយមានបន្ទូលថា៖ «តើអ្នកជឿលើបុត្ររបស់មនុស្សទេ?»36គាត់ឆ្លើយ
ហើយនិយាយថា៖ «លោកម្ចាស់អើយ តើព្រះអង្គជានរណា? ដើម្បីឲ្យខ្ញុំបានជឿដល់ព្រះអង្គផង»។37ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «អ្នកបានឃើញព្រះអង្គហើយ
ហើយព្រះអង្គគឺជាព្រះដែលកំពុងតែមានបន្ទូលមកកាន់អ្នកហើយ»។38បុរសនោះនិយាយថា៖ «ព្រះអម្ចាស់អើយ ខ្ញុំជឿព្រះអង្គហើយ» ហើយគាត់ក៏ថ្វាយបង្គំព្រះអង្គ។
39ព្រះយេស៊ូមានបន្ទូលថា៖ «ដ្បិត ខ្ញុំបានមកលោកីយ៍នេះ ដើម្បីជំនុំជម្រះ ដូច្នេះ អ្នកណាដែលមិនបានឃើញ ឲ្យបានឃើញ
ហើយអ្នកដែលបានឃើញត្រឡប់ទៅជាមើលមិនឃើញវិញ»។40មានពួកផារីស៊ីខ្លះ ដែលនៅជាមួយព្រះអង្គបានឮការទាំងនេះ ហើយពួកគេបានសួរព្រះអង្គថា៖
«តើយើងក៏មើលមិនឃើញដែរមែនទេ?»41ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកគេថា៖ «ប្រសិនបើ អ្នកមើលមិនឃើញមែន នោះអ្នកអាចគ្មានបាប ប៉ុន្តែ ឥឡូវនេះ
អ្នកនិយាយថា៖ «យើងមើលឃើញ» ដូច្នេះ អ្នកនៅតែមានបាបដដែលទេ។

10 1«ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អស់អ្នកណាដែលមិនចូលទៅតាមទ្វារទៅក្នុងក្រោលចៀម ប៉ុន្តែ បែរជាចូលតាមផ្លូវផ្សេង អ្នកនោះគឺជាចោរលួច
ឬជាចោរប្លន់។2អស់អ្នកណាដែលចូលតាមទ្វារគឺជាអ្នកគង្វាលរបស់ចៀម។
3អ្នកឆ្មាំទ្វារនឹងបើកទ្វារឲ្យគាត់។ ចៀមឮសម្លេងរបស់គាត់ ហើយគាត់ហៅឈ្មោះចៀមរបស់គាត់តាមឈ្មោះ ហើយនាំពួកវាចេញទៅ។
4នៅពេលគាត់បាននាំចៀមរបស់គាត់ទាំងអស់ចេញក្រៅហើយ គាត់ក៏នាំមុខពួកវា ហើយចៀមដើរនឹងតាមគាត់ ព្រោះពួកវាស្គាល់សម្លេងរបស់គាត់។
5ពួកវាមិនដើរតាមមនុស្សចំឡែកទេ ប៉ុន្តែពួកវានឹងគេចពីគេវិញ ដ្បិតពួកវាមិនស្គាល់សម្លេងរបស់មនុស្សចំឡែកនោះទេ»។
6ព្រះយេស៊ូមានបន្ទូលជាប្រស្នានេះទៅកាន់ពួកគេ ប៉ុន្តែពួកគេមិនយល់ការទាំងនេះដែលព្រះអង្គកំពុងមានបន្ទូលទៅកាន់ពួកគេនោះទេ។
7បន្ទាប់មក ព្រះយេស៊ូបានមានបន្ទូលទៅកាន់ពួកគេម្ដងទៀតថា៖ «ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ខ្ញុំគឺជាទ្វារនៃចៀម។8អស់អ្្នកដែលមកមុនខ្ញុំគឺជាចោរលួច
និងចោរប្លន់ ប៉ុន្តែចៀមមិនស្ដាប់តាមពួកគេទេ។
9ខ្ញុំជាទ្វារ។ ប្រសិនបើ នរណាចូលតាមខ្ញុំ អ្នកណានោះនឹងបានសង្គ្រោះ អ្នកនោះនឹងចូល ហើយចេញ ហើយនិងស្វែងរកវាលស្មៅ។10ចោរមិនមកទេ ប្រសិនបើ វាមិនលួច
សម្លាប់ និងបំផ្លាញនោះ។ ខ្ញុំមក ដើម្បីឲ្យមនុស្សមានជីវិត និងមានជីវិតដែលពេញបរិបូរណ៌ផង។
11ខ្ញុំជាអ្នកគង្វាលល្អ។ អ្នកគង្វាលល្អគឺលះបង់ជីវិតដើម្បីចៀម។12អ្នកបម្រើដែលត្រូវបានជួលដោយប្រាក់មិនមែនជាអ្នកគង្វាលទេ ហើយក៏មិនមែនជាម្ចាស់ចៀមដែរ។
ពេលអ្នកនោះឃើញ ឆ្កែចចកមក គេនឹងបោះបង់ចៀមចោល ហើយរត់គេចបាត់ ដូច្នេះ ឆ្កែចចកក៏ចាប់យកពួកវា ហើយធ្វើឲ្យពួកវាបែកខ្ចាត់ខ្ចាយ។13គាត់រត់បាត់
ដោយសារគាត់ជាអ្នកបម្រើដែលជួល ហើយមិនបាននៅការពារចៀមនោះទេ។
14ខ្ញុំជាអ្នកគង្វាលល្អ ហើយខ្ញុំស្គាល់ចៀមខ្ញុំ ហើយចៀមខ្ញុំក៏ស្គាល់ខ្ញុំដែរ។15ព្រះបិតាស្គាល់ខ្ញុំ ហើយខ្ញុំស្គាល់ព្រះបិតា ហើយខ្ញុំលះបង់ជីវិតខ្ញុំដើម្បីចៀម។
16ខ្ញុំមានចៀមផ្សេងទៀត ដែលមិននៅក្នុងក្រោលចៀម។ ខ្ញុំត្រូវតែនាំពួកវាផងដែរ ហើយពួកវានឹងឮសម្លេងខ្ញុំ ដូច្នេះ នឹងមានហ្វូងសត្វតែមួយ និងហ្វូងចៀមតែមួយ។
17ហេតុដូច្នេះហើយ បានជាព្រះបិតាស្រឡាញ់ខ្ញុំៈ «ខ្ញុំលះបង់ជីវិតរបស់ខ្ញុំ ដើម្បីឲ្យខ្ញុំបានវាត្រឡប់មកវិញម្ដងទៀត។18គ្មាននរណាអាចយកវាពីខ្ញុំបានទេ ប៉ុន្តែ
ខ្ញុំលះបង់ជីវិតខ្ញុំដោយខ្លួនឯង។ ខ្ញុំមានសិទ្ធិអំណាចក្នុងការលះបង់ជីវិត ហើយខ្ញុំក៏មានសិទ្ធិអំណាចក្នុងការយកវាមកវិញម្ដងទៀតដែរ។ ខ្ញុំបានទទួលសេចក្ដីបង្គាប់នេះ
ពីព្រះបិតាខ្ញុំមក»។
19ការបាក់បែកបានកើតឡើងម្ដងទៀតនៅក្នុងចំណោមពួកសាសន៍យូដាដោយសារពាក្យទាំងនេះ។20ពួកគេជាច្រើននិយាយថា៖ «គាត់មានអារក្ស ហើយឆ្កួតទៀត។
ហេតុអ្វីបានជាអ្នករាល់គ្នាស្ដាប់វា?»។21ហើយអ្នកខ្លះទៀតនិយាយថា៖ «សម្ដីទាំងនេះ មិនមែនដោយសារអារក្សចូលមនុស្សទេ។ តើអារក្សអាចធ្វើឲ្យភ្នែកពិការភ្លឺដែរទេ?»


generated on Fri Jun 6 10:45:59 2025

[22]បន្ទាប់មក ជាពេលវេលាសម្រាប់ធ្វើពិធីបុណ្យឆ្លងព្រះវិហារនៅក្នុងយេរ៉ូសាឡិម។[23]វាជារដូវរងា
ហើយព្រះយេស៊ូបានយាងឡើងចូលទៅក្នុងព្រះវិហារនៅត្រង់សាលាដំណាក់សាឡូម៉ូន។[24]នោះពួកសាសន៍យូដាបានមកជុំវិញព្រះអង្គ ហើយនិយាយទៅកាន់ព្រះអង្គថា៖
«តើលោកឲ្យយើងមានការសង្ស័យដល់កាលណាទៀត? ប្រសិនបើ លោកជាព្រះគ្រិស្ដមែន ចូលប្រាប់យើងជាសាធារណៈមក»។
[25]ព្រះយេស៊ូមានបន្ទូលឆ្លើយទៅកាន់ពួកគេថា៖ «ខ្ញុំប្រាប់អ្នករាល់គ្នាហើយ ប៉ុន្តែ អ្នករាល់គ្នាមិនជឿ។ កិច្ចការទាំងនះគឺខ្ញុំធ្វើ នៅក្នុងនាមព្រះបិតាខ្ញុំ
បានធ្វើបន្ទាល់ពីខ្ញុំហើយ។[26]ប៉ុន្តែ អ្នករាល់គ្នានៅតែមិនជឿ ព្រោះអ្នករាល់គ្នាមិនមែនជាចៀមខ្ញុំ។
[27]ចៀមខ្ញុំស្ដាប់សម្លេងខ្ញុំ ហើយខ្ញុំស្គាល់ពួកវាដែរ ហើយពួកវាក៏ដើរតាមខ្ញុំ។[28]ខ្ញុំនឹងផ្តល់ឲ្យពួកវាមានជីវិតអស់កល្បជានិច្ច ពួកវានឹងមិនស្លាប់ឡើយ
ហើយគ្មាននរណាឆក់យកពួកវាចេញពីដៃខ្ញុំបានដែរ។
[29]ព្រះបិតាខ្ញុំ ជាអ្នកប្រទានពួកវាមកខ្ញុំ ព្រះអង្គធំជាងអ្នកផ្សេងទាំងអស់ ហើយគ្មាននរណាអាចឆក់យកពួកវាចេញពីព្រះហស្ដរបស់ព្រះបិតាបានឡើយ។[30]ខ្ញុំ
និងព្រះបិតាគឺតែមួយ។[31]ក្រោយមក ពួកយូដាបានយកដុំថ្ម ចោលព្រះអង្គម្ដងទៀត។
[32]ព្រះយេស៊ូបានឆ្លើយទៅពួកគេថា៖ «ខ្ញុំបានបង្ហាញការល្អជាច្រើនពីព្រះបិតាដល់អ្នករាល់គ្នា។ ដោយសារការទាំងនោះ
អ្នករាល់គ្នាចោលខ្ញុំនឹងដុំថ្មមែនទេ?»[33]ពួកយូដាឆ្លើយទៅកាន់ព្រះអង្គថា៖ «យើងមិនបានចោលឯងនឹងដុំថ្មដោយសារការល្អណាមួយឡើយ ប៉ុន្តែឯងបានប្រមាថ
ដោយព្រោះឯងជាមនុស្ស ហើយតាំងខ្លួនឯងជាព្រះជាម្ចាស់»។
[34]ព្រះយេស៊ូបានឆ្លើយទៅពួកគេថា៖ «តើមិនបានសរសេរនៅក្នុងក្រឹត្យវិន័យទេថា «ខ្ញុំនិយាយថា៖ «អ្នករាល់គ្នាគឺជាព្រះ?»[35]បើគម្ពីរហៅអស់អ្នកដែលទទួលព្រះបន្ទូលថា
ជា "ព្រះ"ដូច្នេះ[36]ចុះហេតុដូចម្ដេចបានជាពេលខ្ញុំប្រាប់អ្នករាល់គ្នាថា ខ្ញុំជាបុត្រារបស់ព្រះជាម្ចាស់ អ្នករាល់គ្នាបែរជាពោលថា ខ្ញុំប្រមាថព្រះអង្គទៅវិញ? ព្រះបិតាបានប្រោស
ខ្ញុំអោយវិសុទ្ធ ហើយចាត់ខ្ញុំអោយមកក្នុងពិភពលោកនេះទៀតផង។
[37]ប្រសិនបើ ខ្ញុំមិនបានធ្វើការរបស់ព្រះបិតារបស់ខ្ញុំទេ សូមកុំជឿខ្ញុំ។[38]ប៉ុន្តែ ប្រសិនបើ ខ្ញុំធ្វើការរបស់ព្រះអង្គ ប៉ុន្តែ អ្នករាល់គ្នាមិនជឿដល់ខ្ញុំទេ មិនជឿលើកិច្ចការ
ដែលអ្នករាល់គ្នាក៏ដឹង ហើយយល់ថាព្រះបិតានៅក្នុងខ្ញុំ ហើយដឹងថា ខ្ញុំនៅក្នុងព្រះបិតានោះ»។[39]ពួកគេបានព្យាយាមចាប់ព្រះអង្គម្ដងទៀត ប៉ុន្តែ
ព្រះអង្គបានចេញទៅក្រៅពីការចាប់របស់ពួកគេ។
[40]ព្រះអង្គបានចេញទៅម្ដងទៀតឆ្ងាយពីទន្លេយ័រដាន់ ដើម្បីទៅកន្លែងដែលលោកយ៉ូហានបានធ្វើពិធីជ្រមុជលើកដំបូង ហើយព្រះអង្គស្នាក់នៅទីនោះ។
[41]មានមនុស្សជាច្រើនបានទៅរកព្រះអង្គ ហើយពួកគេនិយាយថា៖ «ពិតប្រាកដណាស់ លោកយ៉ូហានមិនបានធ្វើទីសម្គាល់អ្វីទេ ប៉ុន្តែ
អ្វីគ្រប់យ៉ាងដែលលោកយ៉ូហានបាននិយាយអំពីបុរសម្នាក់នេះគឺជាសេចក្ដីពិត»។[42]មនុស្សជាច្រើនបានជឿព្រះអង្គនៅទីនោះ។

11 [1]មានបុរសម្នាក់ឈ្មោះឡាសាមានជំងឺ។ គាត់នៅភូមិបេតថានី នៅក្នុងភូមិដែលនាងម៉ារី និងបងស្រីរបស់នាងម៉ាថា។
[2]នាងម៉ារីគឺជាអ្នកដែលបានចាក់ប្រេងក្រអូបលាបលើព្រះអម្ចាស់ ហើយយកសក់របស់នាងជូតជើងរបស់ព្រះអង្គ រីឯ ឡាសាដែលឈឺនោះជាប្អូនរបស់នាង។
[3]នោះបងស្រីទាំងពីរបានចាត់គេឲ្យទៅឯព្រះយេស៊ូ និយាយថា៖ «ព្រះអម្ចាស់អើយ មើល អ្នកដែលព្រះស្រឡាញ់ឈឺហើយ»។[4]នៅពេលព្រះយេស៊ូឮដូច្នេះ
ព្រះអង្គមានបន្ទូលថា៖ «ជំងឺនេះមិនស្លាប់ទេ ប៉ុន្តែផ្ទុយទៅវិញ ជំងឺនេះដើម្បីថ្វាយសិរីល្អដល់ព្រះជាម្ចាស់វិញ ដើម្បីឲ្យបុត្រារបស់ព្រះបានទទួលសិរីល្អដោយសារវាដែរ»។
[5]ព្រះយេស៊ូស្រឡាញ់នាងម៉ាថា និងប្អូនស្រីរបស់នាង ព្រមទាំងឡាសាផង។[6]ដូច្នេះ នៅពេលព្រះអង្គឮថា ឡាសាឈឺ
ព្រះយេស៊ូស្នាក់នៅកន្លែងដែលព្រះអង្គនៅនោះពីរយប់ថែមទៀត។[7]បន្ទាប់មក ព្រះអង្គមានបន្ទូលទៅកាន់ពួកសិស្សថា៖ «តោះ យើងទៅស្រុកយូដាម្ដងទៀត»។
[8]ពួកសិស្សនិយាយទៅកាន់ព្រះអង្គថា៖ «រ៉ាប៊ី ពួកយូដាកំពុងតែចង់ចោលព្រះអង្គនឹងដុំថ្ម តើព្រះអង្គនៅតែចង់ត្រឡប់ទៅវិញម្ដងទៀត?»[9]ព្រះយេស៊ូឆ្លើយថា៖
«តើមួយថ្ងៃមិនមានដប់ពីរម៉ោងទេឬអី? ប្រសិនបើ អ្នកណាម្នាក់ដើរនៅពេលថ្ងៃ គាត់នឹងមិនជំពប់ទេ ព្រោះគាត់មើលឃើញ ដោយសារពន្លឺរបស់លោកីយ៍នេះ។
[10]ប៉ុន្តែ ប្រសិនបើ គាត់ដើរពេលយប់វិញ គាត់នឹងជំពប់មិនខាន ព្រោះពន្លឺមិននៅក្នុងគាត់ទេ»។[11]ព្រះអង្គមានបន្ទូលពីការទាំងនេះ
ហើយបន្ទាប់ពីមានបន្ទូលពីការទាំងនេះហើយ ទ្រង់មានបន្ទូលទៅពួកគេថា៖ «មិត្តសម្លាញ់របស់យើងឡាសាបានដេកលក់ហើយ ប៉ុន្តែ ខ្ញុំនឹងទៅ
ដើម្បីខ្ញុំដាស់គាត់ឲ្យក្រោកពីគេវិញ»។
[12]ដូច្នេះហើយ បានជាពួកសិស្សទូលទៅកាន់ព្រះអង្គថា៖ «ព្រះអម្ចាស់អើយ ប្រសិនបើ គាត់ដេកលក់មែន គាត់នឹងភ្ញាក់ឡើងវិញ»។
[13]ព្រះយេស៊ូមានបន្ទូលពីការស្លាប់របស់គាត់ ប៉ុន្តែ ពួកគេគិតថា ព្រះអង្គកំពុងមានបន្ទូលពីការដេកសម្រាក។[14]បន្ទាប់មក ព្រះយេស៊ូមានបន្ទូលទៅពួកគេយ៉ាងច្បាស់ថា៖
«ឡាសាស្លាប់ហើយ»។
[15]ដោយព្រោះអ្នករាល់គ្នា ខ្ញុំសប្បាយចិត្តណាស់ ដែលខ្ញុំមិននៅទីនោះដើម្បីឲ្យអ្នករាល់គ្នាអាចជឿ។ តោះ ចូរយើងទៅជួបគាត់»។[16]លោកថូម៉ាស ដែលហៅថា ឌីឌីម
និយាយទៅពួកសិស្សទាំងអស់ថា៖ «តោះ យើងទៅ ដើម្បីឲ្យយើងអាចស្លាប់ជាមួយព្រះយេស៊ូ»។
[17]នៅពេលព្រះយេស៊ូយាងមកដល់ ព្រះអង្គបានឃើញថា ឡាសាត្រូវបានដាក់ទៅក្នុងផ្នូរបួនថ្ងៃរួចស្រេចទៅហើយ។[18]ភូមិបេថានីនៅជិតយេរ៉ូសាឡិម
ប្រហែលជាបីគីឡូម៉ែត្រ។[19]ពួកយូដាជាច្រើនបានចូលទៅឯនាងម៉ាថា និងម៉ារី ដើម្បីកម្សាន្តចិត្តពួកនាងពីប្អូនរបស់របស់ពួកគេ។[20]បន្ទាប់មក នាងម៉ាថា
នៅពេលដែលនាងបានឮថាព្រះយេស៊ូយាងមក នាងបានទៅជួបព្រះអង្គ ប៉ុន្តែនាងម៉ារីកំពុងអង្គុយនៅក្នុងផ្ទះ។
[21]បន្ទាប់មក នាងម៉ាថាបាននិយាយទៅកាន់ព្រះយេស៊ូថា៖ «ព្រះអម្ចាស់អើយ ប្រសិនបើ ព្រះអង្គនៅទីនេះ ប្អូនប្រុសរបស់ខ្ញុំម្ចាស់មិនស្លាប់ទេ។[22]ខ្ញុំម្ចាស់ដឹងថា
អ្វីក្តីដែលព្រះអង្គទូលសូមដល់ព្រះជាម្ចាស់ ទ្រង់នឹងប្រទានដល់ព្រះអង្គមិនខាន»។[23]ព្រះយេស៊ូឆ្លើយទៅនាងថា៖ «ប្អូនប្រុសរបស់នាងនឹងរស់ឡើងវិញម្ដងទៀត»។
[24]នាងម៉ាថាឆ្លើយទៅកាន់ព្រះអង្គថា៖ «ខ្ញុំម្ចាស់ដឹងថា ព្រះអង្គនឹងប្រោសគាត់ឲ្យរស់ឡើងវិញនៅថ្ងៃចុងក្រោយ»។[25]ព្រះយេស៊ូមានបន្ទូលទៅនាងថា៖
«ខ្ញុំជាសេចក្ដីរស់ឡើងវិញ និងជាជីវិត អស់អ្នកណាដែលជឿដល់ខ្ញុំ ទោះបើស្លាប់ក៏ដោយ នឹងរស់ឡើងវិញជាមិនខាន។[26]ហើយអស់អ្នកដែលរស់នៅនៅឡើយ
ដែលជឿដល់ខ្ញុំ នឹងមិនស្លាប់ឡើយ។ តើអ្នករាល់គ្នាជឿការនេះទេ?»។
[27]នាងនិយាយទៅកាន់ព្រះអង្គថា៖ «ចាស៎ ព្រះអម្ចាស់ ខ្ញុំម្ចាស់ជឿថា ព្រះអង្គគឺជាព្រះគ្រិស្ដ ជាព្រះបុត្រានៃព្រះជាម្ចាស់ ដែលបានយាងមកនៅលើផែនដីនេះ»។
[28]នៅពេលដែលនាងនិយាយការនេះរួចហើយ នាងបានចេញទៅហៅនាងម៉ារីជាប្អូនស្រីរបស់នាងដោយសម្ងាត់។ នាងនិយាយថា៖ «លោកគ្រូមកដល់ហើយ
ហើយសួររកអូនឯង»។[29]នៅពេលនាងឮដូច្នេះ នាងបានក្រោកឡើងយ៉ាងលឿន ហើយទៅរកព្រះអង្គ។
[30]ព្រះយេស៊ូមិនទាន់បានចូលទៅក្នុងភូមិនៅឡើយទេ ប៉ុន្តែ ព្រះអង្គនៅកន្លែងដែលនាងម៉ាថាបានជួបព្រះអង្គ។[31]ដូច្នេះ នៅពេលពួកយូដា ដែលនៅក្នុងផ្ទះជាមួយនាង
និងអ្នកដែលមកកម្សាន្តចិត្តនាង ឃើញនាងម៉ារីក្រោកឡើងយ៉ាងលឿន ហើយចេញក្រៅយ៉ាងដូច្នេះ ពួកគេក៏ដើរតាមនាង គិតថានាងទៅឯផ្នូរ ដើម្បីយំនៅទីនោះ។
[32]នៅពេលនាងម៉ារីមកដល់កន្លែងដែលព្រះយេស៊ូគង់នៅ ហើយបានឃើញព្រះអង្គ។ នាងបានលុតជង្គង់ចុះនៅជិតព្រះបាទាព្រះអង្គ ហើយនិយាយទៅកាន់ព្រះអង្គថា៖
«ព្រះអម្ចាស់អើយ ប្រសិនបើ ព្រះអង្គនៅទីនេះ ប្អូនប្រុសរបស់ខ្ញុំម្ចាស់ មិនស្លាប់ទេ»។
[33]នៅពេលព្រះយេស៊ូឃើញនាងយំ ហើយពួកយូដាដែលមកជាមួយនាងកំពុងយំផងដែរ ព្រះអង្គមានព្រះទ័យក្ដុកក្ដួលជាខ្លាំងនៅខាងក្នុងវិញ្ញាណរបស់ព្រះអង្គ
ហើយអន្ទះសារជាខ្លាំង។[34]ទ្រង់មានបន្ទូលថា៖ «តើអ្នកបានគាត់នៅឯណា?» ពួកគេនិយាយទៅកាន់ព្រះអង្គថា៖ «ព្រះអម្ចាស់អើយ សូមយាងមក ព្រះអង្គនឹងឃើញ»។
[35]ព្រះយេស៊ូទ្រង់ព្រះកន្សែង។
[36]បន្ទាប់មក ពួកយូដានិយាយថា៖ «មើល ព្រះអង្គស្រឡាញ់ឡាសាប៉ុណ្ណា!»[37]ប៉ុន្តែ មានអ្នកខ្លះនៅក្នុងចំណោមពួកគេនិយាយថា៖ «តើបុរសម្នាក់នេះ
ដែលអាចធ្វើឲ្យមនុស្សខ្វាក់ភ្លឺបាន តើគាត់អាចធ្វើឲ្យបុរសនេះមិនស្លាប់បានទេ?»

38បន្ទាប់មក ព្រះយេស៊ូមានព្រះទ័យក្ដុកក្ដួលម្ដងទៀតនៅក្នុងព្រះអង្គ ទ្រង់បានយាងទៅឯផ្នូរ។ នៅឯផ្នូរ មានថ្មបិទជិត។ 39ព្រះយេស៊ូមានបន្ទូលថា៖ «ចូរយកថ្មនេះចេញ!»។
នាងម៉ាថា បងស្រីរបស់ឡាសាទូលទៅកាន់ព្រះយេស៊ូថា៖ «ព្រះអម្ចាស់អើយ មកដល់ពេលនេះរូបកាយរលួយហើយដ្បិតគាត់បានស្លាប់បួនថ្ងៃហើយ»។
40ព្រះយេស៊ូមានបន្ទូលទៅនាងថា៖ «តើខ្ញុំមិនបាននិយាយទេឬអីថា ប្រសិនបើអ្នកជឿ អ្នកនឹងបានឃើញសិរីល្អរបស់ព្រះជាម្ចាស់?»។
41ដូច្នេះ ពួកគេបានយកថ្មចេញ។ ព្រះយេស៊ូបានសម្លឹងមើល ហើយ មានបន្ទូលថា៖ «ព្រះបិតាអើយ ទូលបង្គំដឹងថា ព្រះអង្គស្ដាប់ទូលបង្គំ។ 42ទូលបង្គំដឹងថា
ព្រះអង្គស្ដាប់ទូលបង្គំជានិច្ច ប៉ុន្ដែ ដោយព្រោះហ្វូងមនុស្សដែលកំពុងឈរនៅជុំវិញទូលបង្គំ បានជឿថាព្រះអង្គបានចាត់ទូលបង្គំឲ្យមក»។
43បន្ទាប់ពីព្រះអង្គមានបន្ទូលរួចហើយ ព្រះអង្គក៏ស្រែកសម្លេងយ៉ាងខ្លាំងថា៖ «ឡាសា ចេញមក!» 44បុគ្គលដែលស្លាប់នោះបានចេញមក ជើង
និងដៃរបស់គាត់ត្រូវបានចងដោយក្រណាត់ ហើយមុខរបស់គាត់ក៏ត្រូវបានចងដោយក្រណាត់ដែរ។ ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «ចូរស្រាយគាត់
ហើយឲ្យគាត់ចេញទៅ»។
45បន្ទាប់មក មានពួកយូដាជាច្រើនដែលមកជាមួយនាងម៉ារី បានឃើញអ្វីដែលព្រះយេស៊ូបានធ្វើ ហើយបានជឿលើព្រះអង្គ។ 46ប៉ុន្ដែ
មានអ្នកខ្លះក្នុងចំណោមពួកគេបានចេញទៅឯពួកផារីស៊ី ហើយប្រាប់ពួកគេពីអ្វីដែលព្រះយេស៊ូបានធ្វើ។
47នាយកបូជាចារ្យ និងពួកផារីស៊ីបានជួបជុំគ្នា ប្រឹក្សាជាមួយគ្នា ហើយនិយាយថា «តើយើងត្រូវធ្វើអ្វី?»។ បុរសម្នាក់នេះ បានធ្វើទីសម្គាល់ជាច្រើន។ 48ប្រសិនបើ
យើងទុកគាត់ឲ្យធ្វើដូច្នេះ មនុស្សគ្រប់គ្នាមុខជាជឿលើគាត់មិនខាន។ ពួករ៉ូមនឹងមក ហើយនឹងគ្រប់គ្រងលើយើង និងប្រទេសយើងផង»។
49ប៉ុន្ដែ មានបុរសម្នាក់នៅក្នុងចំណោមពួកគេឈ្មោះ កៃផាស ដែលជាមហាបូជាចារ្យនៅឆ្នាំនោះ មានប្រសាសន៍ទៅពួកគេថា៖ «អ្នករាល់គ្នាគ្មានដឹងអ្វីទាំងអស់។
50អ្នករាល់គ្នាមិនគិតទេថា ប្រសិនបើ មនុស្សម្នាក់ស្លាប់ ជំនួសប្រជាជន ប្រសើរជាងមនុស្សមួយប្រទេសត្រូវវិនាស»។
51គាត់មានប្រសាសន៍ការនេះ មិនមែនដោយខ្លួនគាត់ទេ។ ផ្ទុយទៅវិញ ក្នុងនាមជាមហាបូជាចារ្យនៅក្នុងឆ្នាំនោះ គាត់បានថ្លែងទំនាយថា
ព្រះយេស៊ូត្រូវសុគតដើម្បីប្រទេសជាតិ។ 52ហើយមិនគ្រាន់តែសម្រាប់ប្រទេសជាតិប៉ុណ្ណឹងទេ ប៉ុន្ដែ
ដើម្បីឲ្យបុត្រធីតារបស់ព្រះជាម្ចាស់ដែលបានខ្ចាត់ខ្ចាយអាចប្រមូលមូលរួមតែមួយវិញ។ 53ដូច្នេះ ចាត់តាំងពីថ្ងៃនោះមក
ពួកគេបានរៀបគម្រោងពីរបៀបនៃការសម្លាប់ព្រះយេស៊ូ។
54ព្រះយេស៊ូលែងយាងនៅក្នុងចំណោមពួកគេជាសាធារណៈទៀតហើយ ប៉ុន្ដែ
ព្រះអង្គបានចេញពីទីនោះទៅតំបន់ដែលនៅជិតនឹងទីរហោស្ថានគឺនៅក្នុងក្រុងមួយដែលហៅថា អេប្រាអ៊ីម។ ព្រះអង្គគង់នៅទីនោះជាមួយពួកសិស្ស។
55ហើយពិធីបុណ្យរំលងរបស់សាសន៍យូដាជិតមកដល់ ហើយមានមនុស្សជាច្រើនមកពីប្រទេសផ្សេងបានឡើងទៅក្រុងយេរ៉ូសាឡិម មុនថ្ងៃបុណ្យចម្លង
ដើម្បីធ្វើឲ្យពួកគេវិសុទ្ធ។
56ពួកគេស្វែងរកព្រះយេស៊ូ ហើយបាននិយាយទៅកាន់គ្នាទៅវិញទៅមក នៅពេលដែលពួកគេនៅក្នុងព្រះវិហារថា៖ «តើអ្នកគិតយ៉ាងដូចម្ដេច?
ថាតើគាត់នឹងមិនមកចូលរួមពិធីបុណ្យទេឬអី?»។ 57នាយកបូជាចារ្យ និងពួកផារីស៊ីបានដាក់សេចក្ដីបង្គាប់ថា ប្រសិនបើអ្នកណាម្នាក់ដឹងថាព្រះយេស៊ូនៅទីណា
អ្នកនោះត្រូវរាយការណ៍ ដើម្បីឲ្យពួកគេបានចាប់ព្រះអង្គ។

12 1ប្រាំមួយថ្ងៃមុនថ្ងៃបុណ្យរំលង ព្រះយេស៊ូបានយាងចូលភូមិបេថានី ជាកន្លែងដែល ព្រះយេស៊ូបានប្រោសឡាសា ពីស្លាប់ឡើងវិញ។ 2ដូច្នេះ
ពួកគេបានចម្អិនអាហារល្ងាចសម្រាប់ព្រះអង្គនៅទីនោះ ហើយនាងម៉ាថាជាអ្នកធ្វើម្ហូប ប៉ុន្ដែ ឡាសាគឺជាម្នាក់ដែលអង្គុយរួមតុជាមួយព្រះយេស៊ូ។ 3បន្ទាប់មក
នាងម៉ារីបានយកទឹកអប់ដែលធ្វើឡើងចេញពីទេព្វិរូបបរិសុទ្ធដ៏មានតម្លៃបំផុត ចាក់លាបព្រះបាទារបស់ព្រះយេស៊ូជាមួយទឹកអប់នោះ
ហើយបានជូតជើងព្រះអង្គជាមួយនឹងសក់របស់នាង។ នៅក្នុងផ្ទះពេញដោយក្លិនក្រអូបរបស់ទឹកអប់នោះ។
4លោកយូដាសអ៊ីស្ការីយ៉ុត ជាសិស្សម្នាក់ក្នុងចំណោមសិស្សរបស់ព្រះអង្គ ជាម្នាក់ដែលក្បត់ព្រះអង្គ បាននិយាយថា៖ 5«ម្ដេចមិនយកទឹកអប់ទៅលក់បីរយឌេណារី
រួចចែកដល់អ្នកក្រទៅ?»។ 6គាត់និយាយដូច្នេះ មិនមែនដោយសារគាត់យកទុកដាក់ជាមួយអ្នកក្រទេ ប៉ុន្ដែ ដោយសារគាត់ជាចោរ គាត់ជាអ្នកកាន់ថងលុយ
ហើយគាត់បានលួចពីអ្វីដែលដាក់ទៅក្នុងថង់នោះ។
7ព្រះយេស៊ូមានបន្ទូលថា៖ «ឲ្យនាងបន្ដធ្វើអ្វីដែលនាងមានសម្រាប់ថ្ងៃបញ្ចុះសពរបស់ខ្ញុំចុះ។ អ្នករាល់គ្នាតែងតែមានអ្នកក្រនៅជាមួយអ្នករាល់គ្នាជានិច្ច។ 8ប៉ុន្ដែ
ខ្ញុំមិននៅជាមួយអ្នករាល់គ្នារហូតទេ»។
9មានសាសន៍ជាច្រើនបានដឹងថា ព្រះយេស៊ូនៅទីនោះ ហើយពួកគេក៏មករក មិនគ្រាន់តែមករកព្រះយេស៊ូទេ ប៉ុន្ដែ ពួកគេក៏ចង់ឃើញឡាសា
ដែលព្រះយេស៊ូបានប្រោសគាត់ពីសេចក្ដីស្លាប់ឡើងវិញដែរ។ 10នាយកបូជាចារ្យបានរួមគំនិតគ្នាធ្វើដូច្នោះ ដើម្បីចង់សម្លាប់ឡាសាដែរ។ 11ដោយសារតែគាត់
សាសន៍យូដាជាច្រើនចេញពីពួកគេ ហើយបានជឿលើព្រះយេស៊ូ។
12នៅថ្ងៃបន្ទាប់មានហ្វូងមនុស្សយ៉ាងច្រើនកោះករទៅចូលរួមបុណ្យ។ នៅពេលពួកគេឮថាព្រះយេស៊ូមកក្រុងយេរ៉ូសាឡិមដែរ 13ពួកគេបានយកស្លឹកត្នោត
ហើយចេញទៅជួបព្រះអង្គ ហើយស្រែកឡើងថា «ហូសាណា! មានពរហើយ អ្នកដែលមកក្នុងព្រះនាមព្រះអម្ចាស់ ជាព្រះមហាក្សត្រនៃអ៊ីស្រាអែល»។
14ព្រះយេស៊ូបានជួបជាមួយនឹងសត្វលាស្ទាវមួយ ហើយក៏គង់នៅលើវា ដូចមានសេចក្ដីចែងទុកមកថា៖ 15«កុំខ្លាចអី កូនស្រីស៊ីយ៉ូនអើយ ព្រះមហាក្សត្ររបស់អ្នកមកហើយ
ព្រះអង្គគង់នៅលើខ្នងលា។
16ដំបូង ពួកសិស្សរបស់ព្រះអង្គមិនយល់ពីការទាំងនេះទេ ប៉ុន្ដែ នៅពេលព្រះយេស៊ូបានទទួលសិរីល្អ ពួកគេបាននឹកចាំ ការទាំងនេះដែលបានចែងអំពីព្រះអង្គ
ហើយពួកគេបានធ្វើការទាំងនេះចំពោះព្រះអង្គ។
17បណ្ដាជនបានធ្វើបន្ទាល់ថា ពួកគេបាននៅជាមួយព្រះអង្គ នៅពេលទ្រង់ហៅឡាសាចេញពីផ្នូរ ហើយប្រោសគាត់ឲ្យរស់ពីស្លាប់មកវិញ។ 18ដោយសារហេតុផលនេះហើយ
បានជាបណ្ដាជនចេញទៅជួបព្រះអង្គ ព្រោះពួកគេបានឮថាព្រះអង្គបានធ្វើទីសម្គាល់នេះ។ 19ដូច្នេះ ពួកផារីស៊ីបាននិយាយនៅក្នុងចំណោមពួកគេថា៖
«អ្នករាល់គ្នាមិនអាចធ្វើអ្វីបានទាល់តែសោះ មើល! មនុស្សបានទៅតាមអ្នកនោះអស់ហើយ»។
20សាសន៍ក្រិកមួយចំនួននៅក្នុងចំណោមអស់អ្នកដែលឡើងទៅថ្វាយបង្គំនៅថ្ងៃបុណ្យនោះ។ 21ពួកគេបានទៅជួបលោកភីលីព ជាអ្នកដែលមកពីភូមិបេតសៃដា ក្នុងស្រុក
កាលីឡេ បានសួរគាត់ ហើយនិយាយថា៖ «លោក ពួកយើងចង់ជួបព្រះយេស៊ូ»។ 22លោកភីលីពបានទៅជួប ហើយប្រាប់លោកអនទ្រេ ហើយលោកអនទ្រេ
និងលោកភីលីពបានទៅជួប ហើយពួកគេបានប្រាប់ព្រះយេស៊ូ។
23ព្រះយេស៊ូឆ្លើយទៅពួកគេ ហើយមានបន្ទូលថា៖ «ពេលកំណត់មកដល់ហើយ ដែលកូនមនុស្សនឹងទទួលសិរីល្អ។ 24ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
បើគ្រាប់ស្រូវមិនកប់ទៅក្នុងដី ហើយស្លាប់ទេ វានៅតែជាគ្រាប់ស្រូវដដែល ប៉ុន្ដែ ប្រសិនបើវាស្លាប់ វានឹងបង្កើតផលជាច្រើន។
25អ្នកណាដែលស្រឡាញ់ជីវិតរបស់ខ្លួន នឹងបាត់ជីវិតនោះ ប៉ុន្ដែ អ្នកណាដែលស្អប់ជីវិតរបស់ខ្លួននៅក្នុងលោកីយ៍នេះ នឹងរក្សាវាដើម្បីជីវិតអស់កល្បជានិច្ច។ 26ប្រសិនបើ
អ្នកណាម្នាក់បម្រើខ្ញុំ ឲ្យគេបម្រើខ្ញុំចុះ ហើយបើខ្ញុំនៅទីណា អ្នកបម្រើខ្ញុំនឹងនៅទីនោះដែរ។ ប្រសិនបើ អ្នកណាម្នាក់បម្រើខ្ញុំព្រះបិតាខ្ញុំនឹងផ្ដល់កិត្តិយសដល់អ្នកនោះ។
27ឥឡូវនេះ ព្រលឹងខ្ញុំខ្វល់ខ្វាយ ហើយខ្ញុំនឹងនិយាយយ៉ាងដូចម្ដេច? ឱព្រះបិតាអើយ សូមសង្គ្រោះទូលបង្គំនៅក្នុងវេលានេះ ប៉ុន្ដែ ហេតុផលដែលទូលបង្គំមក
គឺដើម្បីវេលានេះឯង។ 28ឱព្រះបិតាអើយ សូមថ្វាយសិរីរុងរឿងដល់ព្រះនាមព្រះអង្គ»។ បន្ទាប់មក មានសម្លេងពីស្ថានសួគ៌មក ហើយមានបន្ទូលថា៖
«យើងបានទទួលសិរីរុងរឿង ហើយនឹងទទួលសិរីរុងរឿងម្ដងទៀត»។ 29នោះ បណ្ដាជនដែលឈរនៅជិត បានឮ ហើយនិយាយថា «មានសម្លេងផ្គរលាន់»។
ហើយអ្នកខ្លះទៀតនិយាយថា៖ «ទេវតាបាននិយាយជាមួយគាត់»។

[30]ព្រះយេស៊ូឆ្លើយ ហើយមានបន្ទូលថា៖ «សម្លេងដែលឮនេះមិនមែនសម្រាប់ខ្ញុំទេ ប៉ុន្ដែ សម្រាប់អ្នករាល់គ្នាវិញ។
[31]សេចក្ដីជំនុំជម្រះរបស់លោកីយ៍នេះមកដល់ហើយនៅពេលនេះ ហើយដល់ពេលដែលពួកគ្រប់គ្រងលោកីយ៍នេះ ត្រូវបោះទៅក្រៅហើយ។
[32]នៅពេលដែលខ្ញុំត្រូវបានលើកឡើងពីលោកីយ៍ ខ្ញុំនឹងនាំអ្នករាល់គ្នាមកជិតខ្លួនខ្ញុំផ្ទាល់។[33]ព្រះអង្គមានបន្ទូលដូច្នេះ ដើម្បីបង្ហាញពីបែបបទនៃសេចក្ដីស្លាប់
ដែលព្រះអង្គត្រូវសុគត។
[34]បណ្ដាជនបានទូលឆ្លើយទៅកាន់ព្រះអង្គថា៖ «យើងបានឮពីក្រឹត្យវិន័យថា ព្រះគ្រិស្ដនឹងគង់នៅអស់កល្បជានិច្ច។ តើយើងអាចនិយាយយ៉ាងដូចម្ដេច
«បុត្រមនុស្សត្រូវតម្កើងឡើង? តើអ្នកណាជាបុត្ររបស់មនុស្ស?»[35]បន្ទាប់មកព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «ពន្លឺនឹងនៅជាមួយអ្នករាល់គ្នាក្នុងរយៈពេលខ្លីប៉ុណ្ណោះ។
ចូរដើរក្នុងការដែលអ្នករាល់គ្នានៅក្នុងពន្លឺនៅឡើយ ធ្វើដូច្នេះ ដើម្បីកុំឲ្យសេចក្ដីងងឹតយកឈ្នះអ្នករាល់គ្នាឡើយ។ អស់អ្នកណាដែលដើរក្នុងសេចក្ដីងងឹត
មិនដឹងថាពួកគេកំពុងទៅណាទេ។[36]ក្នុងការដែលអ្នករាល់គ្នាមានពន្លឺ ចូរជឿលើពន្លឺ ដើម្បីឲ្យអ្នករាល់គ្នាបានក្លាយជាកូននៃពន្លឺ»។
ព្រះយេស៊ូមានបន្ទូលការទាំងនេះរួចហើយ ព្រះអង្គក៏ចាកចេញទៅ ហើយលាក់ខ្លួនពីពួកគេ។
[37]ទោះបីជាព្រះយេស៊ូបានធ្វើទីសម្គាល់ជាច្រើននៅចំពោះពួកគេ ប៉ុន្ដែ ពួកគេនៅតែមិនជឿលើព្រះអង្គទៀត[38]ដូច្នេះ
ដើម្បីឲ្យពាក្យរបស់ព្យាការីអេសាយបានមានប្រសាសន៍ថា៖ «ព្រះអម្ចាស់អើយ តើអ្នកណាជឿលើការរាយការណ៍របស់យើង
ហើយព្រះអម្ចាស់ចង់ឲ្យអ្នកណាឃើញព្រះហស្ដរបស់ព្រះអង្គ?»
[39]ដ្បិត ហេតុផលដែលពួកគេមិនអាចជឿ ព្រោះលោកអេសាយក៏បានមានប្រសាសន៍ដូច្នេះដែរថា[40]«ព្រះអង្គបានធ្វើឲ្យភ្នែករបស់ពួកគេខ្វាក់
ហើយព្រះអង្គក៏ធ្វើឲ្យចិត្តរបស់ពួកគេរឹងរូសដែរ បើមិនដូច្នោះទេ ពួកគេអាចមើលឃើញដោយភ្នែករបស់ពួកគេ ហើយយល់នៅក្នុងចិត្តរបស់ពួកគេរឹង ហើយអាចប្រែចិត្ត
ហើយយើងអាចប្រោសពួកគេឲ្យជា»។
[41]លោកអេសាយមានប្រសាសន៍ការទាំងនេះ ដោយសារគាត់ឃើញសិរីរុងរឿងរបស់ព្រះយេស៊ូ ហើយក៏មានប្រសាសន៍ពីព្រះអង្គ។[42]ប៉ុន្ដែ សូម្បីតែ
អ្នកដឹកនាំជាច្រើនបានជឿលើព្រះយេស៊ូ ប៉ុន្ដែដោយសារពួកផារីស៊ី ពួកគេមិនទទួលស្គាល់វាទេ ដើម្បីកុំឲ្យពួកគេត្រូវបណ្ដេញចេញពីសាលាប្រជុំ។
[43]ពួកគេស្រឡាញ់ការសរសើរដែលមកពីមនុស្សច្រើនជាការសរសើរដែលមកពីព្រះជាម្ចាស់។
[44]ព្រះយេស៊ូបានបន្លឺសម្លេង ហើយមានបន្ទូលថា៖ «អ្នកណាដែលជឿដល់ខ្ញុំ មិនគ្រាន់តែជឿលើខ្ញុំប៉ុណ្ណោះទេ ប៉ុន្ដែ
អ្នកនោះបានជឿដល់ព្រះអង្គដែលចាត់ខ្ញុំឲ្យមកដែរ[45]ហើយអ្នកណាដែលឃើញខ្ញុំ អ្នកនោះក៏ឃើញព្រះដែលចាត់ខ្ញុំឲ្យមកដែរ។
[46]ខ្ញុំបានមកធ្វើជាពន្លឺនៃលោកីយ៍ ដូច្នេះ អស់អ្នកណាដែលជឿលើខ្ញុំ មិនស្ថិតនៅក្នុងសេចក្ដីងងឹតឡើយ។[47]ប្រសិនបើ អ្នកណាម្នាក់ឮពាក្យខ្ញុំ ប៉ុន្ដែ
មិនប្រព្រឹត្តតាមពាក្យនោះទេ ខ្ញុំមិនជំនុំជម្រះគាត់ទេ ដ្បិត ខ្ញុំមិនបានមកដើម្បីជំនុំជម្រះលោកីយ៍ ប៉ុន្ដែ ដើម្បីសង្គ្រោះលោកីយ៍វិញ។
[48]អ្នកណាដែលបដិសេធខ្ញុំ ហើយអ្នកណាដែលមិនទទួលពាក្យរបស់ខ្ញុំ មានម្នាក់នឹងជំនុំជម្រះអ្នកនោះ។ ពាក្យដែលខ្ញុំបាននិយាយនឹងជំនុំជម្រះអ្នកនោះនៅថ្ងៃចុងក្រោយ។
[49]ដ្បិត ខ្ញុំមិនបាននិយាយដើម្បីខ្លួនខ្ញុំទេ ប៉ុន្ដែ ព្រះបិតាដែលចាត់ខ្ញុំឲ្យមក ជាអ្នកប្រទានសេចក្ដីបង្គាប់ដល់ខ្ញុំ ពីអ្វីដែលខ្ញុំត្រូវនិយាយ និងពីអ្វីដែលត្រូវប្រាប់។[50]ខ្ញុំដឹងថា
សេចក្ដីបង្គាប់របស់ព្រះអង្គគឺជាជីវិតអស់កល្បជានិច្ច នោះជាអ្វីដែលខ្ញុំនិយាយ ដូចដែលព្រះបិតាបានមានបន្ទូលមកកាន់ខ្ញុំ ដូច្នេះ ខ្ញុំក៏ប្រាប់»។

13 [1]ឥឡូវនេះ ជាថ្ងៃមុនពេលពិធីបុណ្យរំលង។ ព្រះយេស៊ូជ្រាបថា ពេលកំណត់របស់ព្រះអង្គបានមកដល់ហើយ ក្នុងការចាកចេញពីលោកីយ៍
ហើយត្រឡប់ទៅព្រះបិតាវិញ។ ព្រះអង្គស្រឡាញ់អស់អ្នកដែលនៅជាមួយព្រះអង្គនៅក្នុងលោកីយ៍ណាស់ ហើយទ្រង់ស្រឡាញ់ពួកគេរហូតដល់ទីបំផុត។[2]ឥឡូវនេះ
មារបានដាក់វានៅក្នុងចិត្តរបស់លោកយូដាសអ៊ីស្ការីយ៉ុតជាកូនលោកស៊ីម៉ូនរួចហើយ ដើម្បីក្បត់ព្រះយេស៊ូ។
[3]ព្រះអង្គជ្រាបថា ព្រះបិតាបានប្រទានអ្វីៗទាំងអស់ក្នុងព្រះហស្ដរបស់ព្រះអង្គ ហើយជ្រាបថា ព្រះអង្គបានយាងមកពីព្រះជាម្ចាស់
ហើយព្រះអង្គនឹងត្រឡប់ទៅឯព្រះជាម្ចាស់វិញ។[4]ព្រះអង្គបានក្រោកឡើងពីអាហារល្ងាច ហើយបានយកសម្លៀកបំពាក់ខាងក្រៅរបស់ព្រះអង្គ។
បន្ទាប់មកព្រះអង្គបានយកកន្សែង ហើយយកវាមកក្រវាត់ខ្លួនរបស់ព្រះអង្គ។[5]បន្ទាប់មក ព្រះអង្គបានចាក់ទឹកចូលទៅក្នុងផើងមួយ
ហើយបានចាប់ផ្ដើមលាងជើងពួកសិស្ស ហើយយកកន្សែងដែលចងនៅនឹងខ្លួនរបស់ព្រះអង្គមកជូត។
[6]ព្រះអង្គបានមកឯលោកស៊ីម៉ូនពេត្រុស ហើយលោកពេត្រុសបានទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់អើយ តើព្រះអង្គនឹងលាងជើងទូលបង្គំឬអី?»[7]ព្រះយេស៊ូឆ្លើយ
ហើយមានបន្ទូលទៅគាត់ថា៖ «អ្វីដែលខ្ញុំកំពុងធ្វើ អ្នកមិនយល់ទេនៅពេលនេះ ប៉ុន្ដែ អ្នកនឹងយល់ការនេះនៅពេលក្រោយ»។[8]លោកពេត្រុសទូលទៅព្រះអង្គថា៖
«ព្រះអង្គមិនត្រូវលាងជើងទូលបង្គំទេ»។ ព្រះយេស៊ូឆ្លើយទៅគាត់ថា៖ «ប្រសិនបើ ខ្ញុំមិនលាងជើងអ្នក អ្នកគ្មានចំណែកអ្វីជាមួយខ្ញុំទេ»។
[9]លោកស៊ីម៉ូនពេត្រុសទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់អើយ សូមកុំគ្រាន់តែលាងជើងទូលបង្គំឡើយ ប៉ុន្ដែ សូមលាងដៃ និងក្បាលរបស់ទូលបង្គំផង»។
[10]ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «អ្នកដែលងូតទឹករួចហើយមិនចាំបាច់ទេ លាងតែជើងរបស់អ្នកនោះទៅបានហើយ អ្នកនោះបានស្អាតទាំងស្រុងហើយ។
អ្នកស្អាតហើយ ប៉ុន្ដែ អ្នកផ្សេងទេដែលមិនស្អាត»។[11](ដើម្បីព្រះយេស៊ូជ្រាបថា អ្នកណានឹងក្បត់ព្រះអង្គ ហេតុដូច្នេះ ហើយបានជាព្រះអង្គមានបន្ទូលថា៖
«អ្នករាល់គ្នាមិនស្អាតទាំងអស់គ្នាទេ»)។
[12]នៅពេលព្រះយេស៊ូបានលាងជើងពួកគេដូច្នេះ ហើយបានយកសម្លៀកបំពាក់របស់ព្រះអង្គមកពាក់ ហើយគង់នៅតុអាហារវិញ ព្រះអង្គមានបន្ទូលទៅពួកគេថា៖
«តើអ្នកដឹងអ្វីដែលខ្ញុំកំពុងធ្វើជាមួយអ្នករាល់គ្នាទេ?[13]អ្នករាល់ហៅខ្ញុំថា៖ «លោកគ្រូ» ឬ «ព្រះអម្ចាស់» អ្នករាល់គ្នានិយាយនោះត្រូវហើយ ខ្ញុំអ៊ីចឹងមែន។[14]ប្រសិនបើខ្ញុំ
ជាព្រះអម្ចាស់ និងជាគ្រូ បានលាងជើងអ្នករាល់គ្នា អ្នកក៏ត្រូវលាងជើងដល់គ្នាទៅវិញទៅមកដែរ។[15]ដ្បិត ខ្ញុំបានធ្វើជាគំរូដល់អ្នករាល់គ្នាហើយ អ្នករាល់គ្នាត្រូវធ្វើដូច្នេះ
បានធ្វើដល់អ្នករាល់គ្នាដែរ។
[16]ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកបម្រើមិនធំជាម្ចាស់របស់ខ្លួនឡើយ ឬអ្នកនាំសារក៏មិនធំជាងអ្នកដែលចាត់គាត់ឲ្យមកនោះទេ។[17]ប្រសិនបើ
អ្នករាល់គ្នាស្គាល់ការទាំងនេះ អ្នកនឹងមានពរ ប្រសិនបើ អ្នករាល់គ្នាធ្វើការទាំងនោះ។[18]ខ្ញុំមិននិយាយពីអ្នករាល់គ្នាទេ ខ្ញុំដឹងអស់អ្នកដែលខ្ញុំបានជ្រើសរើស ប៉ុន្ដែ
ការនេះអាចកើតឡើងដូច្នេះ ដើម្បីឲ្យបានសម្រេចតាមបទគម្ពីរថា៖ «អ្នកដែលបរិភោគនំប៉័ងខ្ញុំ បានលើកកែងជើងរបស់គាត់ទាស់នឹងខ្ញុំ»។
[19]ខ្ញុំប្រាប់អ្នករាល់គ្នានៅពេលនេះ មុនពេលវាកើតឡើង ដើម្បីនៅពេលវាកើតឡើង អ្នកអាចជឿថា ខ្ញុំជាព្រះ។[20]ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
អស់អ្នកណាដែលទទួលអ្នកដែលខ្ញុំចាត់ឲ្យទៅ ទទួលខ្ញុំដែរ ហើយអស់អ្នកណាដែលទទួលខ្ញុំ ទទួលព្រះអង្គដែលចាត់ខ្ញុំឲ្យមកដែរ។
[21]នៅពេលព្រះយេស៊ូមានបន្ទូលការនេះរួចហើយ ព្រះអង្គមានការខ្វល់ខ្វាយក្នុងវិញ្ញាណ។ ព្រះអង្គបានធ្វើបន្ទាល់ ហើយមានបន្ទូលថា៖ «ពិតណាស់
ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា មានម្នាក់ក្នុងចំណោមអ្នករាល់គ្នាក្បត់ខ្ញុំ»។[22]ពួកសិស្សមើលគ្នាទៅវិញទៅមក ងឿងឆ្ងល់ថាព្រះអង្គកំពុងមានបន្ទូលពីអ្នកណា។
[23]សិស្សម្នាក់នៃពួកសិស្សរបស់ព្រះអង្គ ជាអ្នកដែលព្រះអង្គស្រឡាញ់ កំពុងតែអង្គុយតុនៅជិតព្រះយេស៊ូ។[24]លោកស៊ីម៉ូនពេត្រុស បានធ្វើសញ្ញាទៅសិស្សនោះ
ហើយនិយាយថា៖ «សួរព្រះអង្គមើល ព្រះអង្គកំពុងនិយាយអំពីអ្នកណា?»។[25]ដូច្នេះ គាត់បានផ្អែកទៅជិតព្រះយេស៊ូហើយនិយាយទៅកាន់ព្រះអង្គថា «ព្រះអង្គម្ចាស់អើយ
តើអ្នកនោះជាអ្នកណា?»
[26]បន្ទាប់មក ព្រះយេស៊ូឆ្លើយថា៖ «គឺជាម្នាក់ដែលខ្ញុំនឹងជ្រលក់នំប៉័ងមួយដុំ ហើយឲ្យទៅអ្នកនោះ»។ ដូច្នេះ នៅពេលព្រះអង្គបានជ្រលក់នំប៉័ងរួចហើយ
ព្រះអង្គបានប្រទានទៅលោកយូដាសជាកូនរបស់លោកស៊ីម៉ូនអ៊ីស្ការីយ៉ុត។[27]បន្ទាប់ពីបានទទួលនំប៉័ងហើយ សាតាំងបានចូលទៅក្នុងគាត់ ដូច្នេះ
ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «តើអ្នកកំពុងធ្វើអ្វី ចូរធ្វើវាឲ្យលឿនទៅ»។

[28]អស់អ្នកដែលអង្គុយនៅតុ គ្មាននរណាម្នាក់ដឹងថា ហេតុអ្វីបានជាព្រះអង្គមានបន្ទូលការនេះទៅគាត់។[29]អ្នកខ្លះគិតថា ដោយសារលោកយូដាសជាអ្នកកាន់ថង់ប្រាក់
ព្រះយេស៊ូមានបន្ទូលទៅគាត់ «ឲ្យទិញអ្វីដែលយើងត្រូវការ សម្រាប់ពិធីបុណ្យ»។ ឬ អាចឲ្យគាត់ឲ្យអ្វីមួយដល់អ្នកក្រ។[30]បន្ទាប់ពីលោកយូដាសបានទទួលនំប៉័ងហើយ
គាត់ក៏ចេញទៅភ្លាម។ ពេលនោះយប់ហើយ។
[31]នៅពេលលោកយូដាសចេញផុតទៅ ព្រះយេស៊ូមានបន្ទូលថា៖ «ឥឡូវនេះ បុត្ររបស់មនុស្សត្រូវទទួលសិរីរុងរឿង
ហើយព្រះជាម្ចាស់បានទទួលសិរីរុងរឿងបានតាមរយៈព្រះអង្គដែរ។[32]ព្រះជាម្ចាស់នឹងតម្កើងព្រះអង្គនៅក្នុងអង្គទ្រង់ផ្ទាល់ ហើយទ្រង់នឹងតម្កើងព្រះអង្គភ្លាម។[33]កូនតូចអើយ
ខ្ញុំនៅជាមួយអ្នករាល់គ្នាតែមួយរយៈខ្លីទៀតតែប៉ុណ្ណោះ។ អ្នករាល់គ្នានឹងស្វែងរកខ្ញុំ ដូចដែលខ្ញុំបាននិយាយទៅពួកយូដាដែរថា៖ «កន្លែងដែលខ្ញុំទៅ
អ្នករាល់គ្នាមិនអាចទៅបានទៅបានទេ»។ ពេលនេះ ខ្ញុំក៏និយាយទៅកាន់អ្នករាល់គ្នាដែរ។
[34]ខ្ញុំឲ្យដល់អ្នករាល់គ្នានូវក្រឹត្យវិន័យមួយថ្មី គឺថាអ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់ដល់អ្នករាល់គ្នាដែរ ដូច្នេះ
អ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមកដែរ។[35]មនុស្សទាំងអស់នឹងដឹងថា អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំដោយសារការនេះ
គឺដោយសារអ្នករាល់គ្នាស្រឡាញ់អ្នកទៅវិញទៅមក»។
[36]លោកស៊ីម៉ូនពេត្រុសទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់អើយ តើព្រះអង្គយាងទៅណា?» ព្រះយេស៊ូឆ្លើយថា៖ «កន្លែងដែលខ្ញុំទៅ
អ្នកមិនអាចទៅតាមខ្ញុំបានទេនៅពេលនេះ ប៉ុន្តែ អ្នកនឹងទៅតាមខ្ញុំនៅពេលក្រោយ»។[37]លោកពេត្រុសទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ
ហេតុអ្វីបានជាទូលបង្គំមិនអាចទៅតាមព្រះអង្គនៅពេលនេះ? ទូលបង្គំនឹងលះបង់ជីវិតរបស់ទូលបង្គំដើម្បីព្រះអង្គ»។[38]ព្រះយេស៊ូឆ្លើយថា៖
«តើអ្នកនឹងលះបង់ជីវិតដើម្បីខ្ញុំ? ពិតណាស់ ខ្ញុំប្រាប់អ្នកជាប្រាកដថា មាន់នឹងមិនរងាវទេ ប្រសិនបើអ្នកមិនបដិសេធខ្ញុំបីដង»។

14 [1]កុំឲ្យរបស់អ្នករាល់គ្នាខ្វល់ខ្វាយឡើយ។ អ្នកជឿដល់ព្រះជាម្ចាស់ហើយ ក៏ជឿដល់ខ្ញុំដែរ។[2]នៅក្នុងដំណាក់របស់ព្រះបិតាខ្ញុំ មានបន្ទប់ជាច្រើន។
ប្រសិនបើមិនដូច្នោះទេ ខ្ញុំប្រាប់អ្នករាល់គ្នាថា ខ្ញុំនឹងទៅដើម្បីរៀបចំកន្លែងសម្រាប់អ្នករាល់គ្នា។[3]ប្រសិនបើខ្ញុំទៅ ហើយរៀបចំកន្លែងសម្រាប់អ្នករាល់គ្នា
ខ្ញុំនឹងត្រឡប់មកវិញម្តងទៀត ហើយយកអ្នករាល់គ្នាទៅឯខ្ញុំ ដូច្នេះ អ្នករាល់គ្នានឹងបាននៅកន្លែងដែលខ្ញុំនៅដែរ។
[4]អ្នករាល់គ្នាបានស្គាល់ផ្លូវដែលខ្ញុំកំពុងទៅ។[5]លោកថូម៉ាសទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ យើងមិនដឹងថាព្រះអង្គទៅណាផង
ធ្វើដូចម្តេចឲ្យយើងស្គាល់ផ្លូវបានទៅ?»[6]ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «ខ្ញុំជាផ្លូវ ជាសេចក្តីពិត និងជាជីវិត គ្មាននរណាអាចទៅឯព្រះបិតាបានទេ
លើកលែងតែចូលតាមរយៈខ្ញុំ។[7]ប្រសិនបើ អ្នករាល់គ្នាបានស្គាល់ខ្ញុំ អ្នករាល់គ្នាក៏ស្គាល់ព្រះបិតារបស់ខ្ញុំដែរ។ ចាប់ពីពេលនេះតទៅ អ្នករាល់គ្នាស្គាល់ព្រះអង្គ
ហើយក៏បានឃើញព្រះអង្គដែរ»។
[8]លោកភីលីពទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់អើយ សូមបង្ហាញព្រះបិតាដល់យើងខ្ញុំផង នោះយើងខ្ញុំស្កប់ចិត្តហើយ»។[9]ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖
«ខ្ញុំបាននៅជាមួយអ្នកអស់រយៈពេលយ៉ាងយូរ ហើយអ្នកនៅតែមិនស្គាល់ខ្ញុំទៀត ភីលីព? អស់អ្នកណាដែលឃើញខ្ញុំ ឃើញព្រះបិតាដែរ។ តើអ្នកអាចនិយាយថា៖
«សូមបង្ហាញព្រះបិតាឲ្យយើងខ្ញុំឃើញផងដូចម្តេចកើត?
[10]តើអ្នករាល់គ្នាមិនជឿថា ខ្ញុំនៅក្នុងព្រះបិតា ហើយព្រះបិតានៅក្នុងខ្ញុំទេឬអី? ពាក្យដែលខ្ញុំនិយាយទៅកាន់អ្នករាល់គ្នា
ខ្ញុំមិនបាននិយាយចេញដោយសិទ្ធិអំណាចខ្លួនរបស់ខ្ញុំផ្ទាល់ទេ ប៉ុន្តែ ព្រះបិតារស់នៅក្នុងខ្ញុំកំពុងធ្វើការងាររបស់ព្រះអង្គ។[11]ចូរជឿដល់ខ្ញុំថា ខ្ញុំនៅក្នុងព្រះបិតា
ហើយព្រះបិតានៅក្នុងខ្ញុំ ឬជឿដោយសារកិច្ចការទាំងនោះចុះ។
[12]ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលជឿដល់ខ្ញុំ នឹងធ្វើការដូចដែលខ្ញុំធ្វើដែរ ហើយអ្នកនោះនឹងធ្វើការលើសជាងការទាំងនេះផង ដ្បិត
ខ្ញុំបានទៅឯព្រះបិតាខ្ញុំវិញហើយ។[13]អ្វីក្តីដែលអ្នករាល់គ្នាសុំដោយនូវឈ្មោះខ្ញុំ ខ្ញុំនឹងសម្រេចឲ្យ ដើម្បីឲ្យព្រះបិតាបានទទួលសិរីរុងរឿងនៅក្នុងព្រះបុត្រា។[14]ប្រសិនបើ
អ្នករាល់គ្នាសុំអ្វីៗដោយនូវឈ្មោះខ្ញុំ ហើយខ្ញុំនឹងធ្វើវា។
[15]ប្រសិនបើ អ្នករាល់គ្នាស្រឡាញ់ខ្ញុំ នឹងប្រព្រឹត្តតាមបញ្ញាតិរបស់ខ្ញុំ[16]ហើយខ្ញុំនឹងអធិស្ឋានទៅព្រះបិតា ហើយព្រះអង្គនឹងប្រទានអ្នកកម្សាន្តចិត្តដល់អ្នករាល់គ្នា
ដើម្បីឲ្យព្រះអង្គបានគង់នៅជាមួយអ្នករាល់គ្នាជារៀងរហូតតទៅ[17]ជាព្រះវិញ្ញាណនៃសេចក្តីពិត។ លោកីយ៍មិនអាចទទួលព្រះអង្គបានទេ
ដោយសារលោកីយ៍មិនឃើញព្រះអង្គ ឬស្គាល់ព្រះអង្គ។ ប៉ុន្តែ អ្នករាល់គ្នាវិញ ស្គាល់ព្រះអង្គ ដើម្បីព្រះអង្គមានព្រះជន្មរស់នៅជាមួយអ្នករាល់គ្នា
ហើយគង់នៅជាមួយអ្នករាល់គ្នា។
[18]ខ្ញុំនឹងមិនបោះបង់អ្នករាល់គ្នាចោលឡើយ ខ្ញុំនឹងត្រឡប់មករកអ្នករាល់គ្នាវិញ។[19]នៅក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ លោកីយ៍នឹងលែងឃើញខ្ញុំទៀតហើយ ប៉ុន្តែ
អ្នករាល់គ្នាឃើញខ្ញុំ។ ព្រោះខ្ញុំរស់ អ្នករាល់គ្នាក៏រស់ដែរ។[20]នៅថ្ងៃនោះ អ្នកនឹងដឹងថា ខ្ញុំនៅក្នុងព្រះបិតា ហើយថាអ្នករាល់គ្នានៅក្នុងខ្ញុំ ហើយខ្ញុំនៅក្នុងអ្នករាល់គ្នា។
[21]អស់អ្នកណាដែលមានក្រឹត្យវិន័យរបស់ខ្ញុំ ហើយប្រព្រឹត្តតាម គឺជាអ្នកដែលស្រឡាញ់ខ្ញុំ ហើយអ្នកណាដែលស្រឡាញ់ខ្ញុំ ព្រះបិតារបស់ខ្ញុំក៏ស្រឡាញ់អ្នកនោះដែរ
ហើយខ្ញុំនឹងស្រឡាញ់អ្នកនោះ ហើយខ្ញុំនឹងបង្ហាញខ្លួនខ្ញុំដល់អ្នកនោះ»។[22]លោកយូដា (មិនមែនអ៊ីស្ការីយ៉ុត) បានទូលទៅព្រះយេស៊ូថា៖ «ព្រះអម្ចាស់អើយ
ហេតុអ្វីបានជាព្រះអង្គបង្ហាញអង្គទ្រង់ដល់យើង ហើយមិនបង្ហាញដល់លោកីយ៍?»
[23]ព្រះយេស៊ូបានឆ្លើយ ហើយមានបន្ទូលទៅគាត់ថា៖ «ប្រសិនបើ អ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះនឹងប្រព្រឹត្តតាមពាក្យរបស់ខ្ញុំ។ ព្រះបិតារបស់ខ្ញុំនឹងស្រឡាញ់អ្នកនោះ
ហើយយើងនឹងមករកអ្នកនោះ ហើយយើងនឹងតាំងទីលំនៅរបស់យើងជាមួយអ្នកនោះ។[24]អ្នកណាដែលមិនស្រឡាញ់ខ្ញុំ មិនប្រព្រឹត្តតាមពាក្យរបស់ខ្ញុំទេ។
ពាក្យដែលអ្នករាល់គ្នាបានឮមិនមែនជាពាក្យរបស់ខ្ញុំទេ ប៉ុន្តែ មកពីព្រះបិតាដែលចាត់ខ្ញុំឲ្យមក។
[25]ខ្ញុំបាននិយាយការទាំងនេះដល់អ្នករាល់គ្នា ក្នុងពេលដែលខ្ញុំនៅជាមួយនឹងអ្នករាល់គ្នា។[26]ប៉ុន្តែ អ្នកកម្សាន្តចិត្ត គឺព្រះវិញ្ញាណដ៏វិសុទ្ធ
ជាព្រះដែលព្រះបិតាបានចាត់មកដោយនូវឈ្មោះខ្ញុំ ព្រះអង្គនឹងបង្រៀនអ្នករាល់គ្នាគ្រប់យ៉ាង
ហើយព្រះអង្គនឹងរំលឹកអ្នករាល់គ្នាពីអ្វីៗគ្រប់យ៉ាងដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នា។[27]ខ្ញុំទុកសេចក្តីសុខសាន្តដល់អ្នករាល់គ្នា
ខ្ញុំឲ្យសេចក្តីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា។ សេចក្តីសុខសាន្តដែលខ្ញុំឲ្យ មិនដូចជាសេចក្តីសុខសាន្តដែលលោកីយ៍ឲ្យទេ។ កុំឲ្យចិត្តរបស់អ្នករាល់គ្នាខ្វល់ខ្វាយឡើយ
ហើយក៏កុំឲ្យភ័យខ្លាចដែរ។
[28]អ្នករាល់គ្នាបានឮអ្វីដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាថា៖ «ខ្ញុំនឹងចេញទៅឆ្ងាយ ហើយខ្ញុំនឹងត្រឡប់មកឯអ្នករាល់គ្នាវិញ។ ប្រសិនបើ អ្នករាល់គ្នាស្រឡាញ់ខ្ញុំ
អ្នកនឹងមានអំណរ ព្រោះខ្ញុំកំពុងតែទៅឯព្រះបិតា ដ្បិតព្រះបិតាធំជាងខ្ញុំ។[29]ខ្ញុំបានប្រាប់អ្នករាល់គ្នារួចហើយ វានឹងកើតឡើងយ៉ាងដូច្នោះ ដើម្បីនៅពេលវាកើតឡើង
អ្នករាល់គ្នានឹងជឿ។[30]ខ្ញុំនឹងឈប់និយាយច្រើនជាមួយនឹងអ្នករាល់គ្នាទៀតហើយ ដ្បិតមេគ្រប់គ្រងលោកីយ៍នេះមកដល់ហើយ។ វាគ្មានអំណាចអ្វីមកលើខ្ញុំទេ[31]ប៉ុន្តែ
ដើម្បីលោកីយ៍បានដឹងថា ខ្ញុំស្រឡាញ់ព្រះបិតា ហើយខ្ញុំធ្វើអ្វីៗតាមសេចក្តីបង្គាប់របស់ព្រះបិតាខ្ញុំ តែប៉ុណ្ណោះ។ ចូរយើងក្រោកឡើង ហើយចេញពីទីនេះទៅ»។

15 [1]ខ្ញុំជាដើមទំពាំងបាយជូរពិត ហើយព្រះបិតាខ្ញុំជាអ្នកដាំ។[2]ព្រះអង្គកាត់មែកទាំងឡាយណាដែលមិនបង្កើតផលនៅក្នុងខ្ញុំចោល
ហើយព្រះអង្គកាត់លោះមែកទាំងឡាយណាដែលបង្កើតផល ដើម្បីឲ្យមែកនោះបានបង្កើតផលកាន់តែច្រើនឡើងថែមទៀត។
[3]អ្នករាល់គ្នាបានស្អាតហើយ ដោយសារព្រះបន្ទូលដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នា។[4]ចូរនៅជាប់នឹងខ្ញុំ ហើយខ្ញុំនៅជាប់នឹងអ្នករាល់គ្នា។ ដូចជាមែកមួយ
មិនអាចបង្កើតផលដោយខ្លួនវាបានទេ លុះត្រាតែវានៅជាប់នឹងដើមទំពាំងបាយជូរ អ្នករាល់គ្នាក៏ដូចគ្នាដែរ លុះត្រាតែនៅជាប់នឹងខ្ញុំ។


generated on Fri Jun 6 10:45:59 2025

5ខ្ញុំជាដើមទំពាំងបាយជូរ អ្នករាល់គ្នាជាមែក។ អ្នកណាដែលនៅជាប់ក្នុងខ្ញុំ ហើយខ្ញុំនៅក្នុងអ្នកនោះ អ្នកនោះនឹងបង្កើតផលជាច្រើន ដ្បិត បើគ្មានខ្ញុំទេ
អ្នកមិនអាចធ្វើអ្វីបានទាំងអស់។6ប្រសិនបើ អ្នកណាមិននៅជាប់នឹងខ្ញុំ អ្នកនោះនឹងត្រូវបោះចោលទៅក្រៅ ដូចជាមែក ហើយវានឹងស្ងួត
ហើយពួកគេនឹងប្រមូលមែកទាំងនោះ ហើយបោះមែកទាំងនោះចោលទៅក្នុងភ្លើង មែកទាំងនោះនឹងត្រូវឆេះអស់។7ប្រសិនបើ អ្នករាល់គ្នានៅជាប់នឹងខ្ញុំ ហើយប្រសិនបើ
ពាក្យខ្ញុំនៅជាប់ក្នុងអ្នករាល់គ្នា ចូរសុំអ្វីៗតាមតែអ្នកប្រាថ្នាចុះ វានឹងបានសម្រេចដល់អ្នករាល់គ្នា។
8ព្រះបិតាខ្ញុំបានទទួលសិរីល្អ ដោយសារអ្នករាល់គ្នាបង្កើតផលជាច្រើន ហើយបញ្ជាក់ថាអ្នករាល់គ្នាជាសិស្សរបស់ខ្ញុំមែន។9ព្រះបិតាស្រឡាញ់ខ្ញុំយ៉ាងណា
ខ្ញុំក៏ស្រឡាញ់អ្នករាល់គ្នាយ៉ាងនោះដែរ។ ចូរនៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ខ្ញុំ។
10ប្រសិនបើ អ្នករាល់គ្នា ប្រព្រឹត្តតាមក្រឹត្យវិន័យរបស់ខ្ញុំ អ្នករាល់គ្នានឹងនៅជាប់នឹងសេចក្តីស្រឡាញ់របស់ខ្ញុំ ដូចខ្ញុំ បានប្រព្រឹត្តតាមក្រឹត្យវិន័យរបស់ព្រះបិតាខ្ញុំដែរ
ហើយខ្ញុំបាននៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គដែរ។11ខ្ញុំបានប្រាប់ការទាំងនេះដល់អ្នករាល់គ្នា ដើម្បីឲ្យអំណររបស់ខ្ញុំបាននៅជាមួយអ្នករាល់គ្នា
និងដើម្បីឲ្យអំណររបស់អ្នករាល់គ្នាបានពេញលក្ខណៈ។
12នេះគឺជាក្រឹត្យវិន័យរបស់ខ្ញុំ គឺថាអ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់ដល់អ្នករាល់គ្នាដែរ។13គ្មាននរណាមានក្តីស្រឡាញ់ធំជាងនេះទេ
ដោយព្រះអង្គហ៊ានលះបង់ជីវិតដើម្បីមិត្តសម្លាញ់។
14អ្នករាល់គ្នាជាមិត្តសម្លាញ់របស់ខ្ញុំ ប្រសិនបើ អ្នករាល់គ្នាធ្វើការដែលខ្ញុំបានបង្គាប់ដល់អ្នករាល់គ្នា។15ខ្ញុំលែងហៅអ្នករាល់គ្នាថាជាអ្នកបម្រើទៀតហើយ
ដ្បិតអ្នកបម្រើមិនដឹងថាម្ចាស់របស់គាត់កំពុងធ្វើអ្វីនោះទេ។ ខ្ញុំបានហៅអ្នករាល់គ្នាថាមិត្តសម្លាញ់ ដើម្បីអ្វីៗគ្រប់យ៉ាងដែលខ្ញុំបានឮពីព្រះបិតាខ្ញុំ
ហើយខ្ញុំបានប្រាប់ដល់អ្នករាល់គ្នារួចហើយ។
16អ្នករាល់គ្នាមិនបានជ្រើសរើសខ្ញុំទេ ប៉ុន្តែ ខ្ញុំបានជ្រើសរើសអ្នករាល់គ្នា ហើយបានរើសតាំងអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានចេញទៅហើយបង្កើតផល
ហើយផលរបស់អ្នករាល់គ្នាបាននៅជាប់ផង។ ដូច្នេះហើយ អ្វីដែលអ្នករាល់គ្នាទូលសុំពីព្រះបិតាដោយនូវឈ្មោះខ្ញុំ ព្រះអង្គនឹងប្រទានមកអ្នករាល់គ្នា។
17ខ្ញុំបង្គាប់ការទាំងនេះមកអ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក។
18ប្រសិនបើ លោកីយ៍ស្អប់អ្នករាល់គ្នា ចូរដឹងថា ពួកគេស្អប់ខ្ញុំមុនពេលពួកគេស្អប់អ្នករាល់ទៅទៀត។19ប្រសិនបើ អ្នករាល់គ្នាមកពីលោកីយ៍
លោកីយ៍នឹងស្រឡាញ់អ្នករាល់គ្នា ព្រោះអ្នករាល់គ្នាជារបស់លោកីយ៍។ ប៉ុន្តែ ដោយព្រោះអ្នករាល់គ្នាមិនមែនជារបស់លោកីយ៍
ហើយដោយសារខ្ញុំបានជ្រើសរើសអ្នករាល់គ្នាចេញពីលោកីយ៍ ដូច្នេះហើយ បានជាលោកីយ៍ស្អប់អ្នករាល់គ្នា។
20ចាំសម្តីដែលខ្ញុំបាននិយាយជាមួយអ្នករាល់គ្នាទេ ថា៖ «អ្នកបម្រើមិនធំជាងចៅហ្វាយរបស់គាត់ទេ»។ ប្រសិនបើ ពួកគេបៀតបៀនខ្ញុំ
ពួកគេក៏បៀតបៀនដល់អ្នករាល់គ្នាដែរ។ ប្រសិនបើ អ្នករាល់គ្នាប្រព្រឹត្តតាមពាក្យខ្ញុំ ពួកគេនឹងប្រព្រឹត្តពាក្យរបស់អ្នករាល់គ្នាដែរ។
21ពួកគេនឹងធ្វើការទាំងអស់នេះដល់អ្នករាល់គ្នា ដោយព្រោះឈ្មោះខ្ញុំ ព្រោះពួកគេមិនស្គាល់ព្រះអង្គដែលចាត់ខ្ញុំឲ្យមកទេ។22ប្រសិនបើ ខ្ញុំមិនបានមក
ហើយប្រាប់ដល់ពួកគេទេ នោះពួកគេអាចនឹងគ្មានបាបទេ ប៉ុន្តែ ឥឡូវនេះ ពួកគេលែងមានការដោះសារពីបាបរបស់ពួកគេហើយ។
23អ្នកណាដែលស្អប់ខ្ញុំ ក៏ស្អប់ព្រះបិតាខ្ញុំដែរ។24ប្រសិនបើ ខ្ញុំមិនបានធ្វើការ ដែលគ្មាននរណានៅក្នុងចំណោមពួកគេអាចធ្វើការនោះបាន ពួកគេអាចនឹងមិនមានបាបទេ
ប៉ុន្តែ ឥឡូវនេះ ពួកគេបានឃើញ ហើយស្អប់ទាំងខ្ញុំ និងព្រះបិតាខ្ញុំ។25ប៉ុន្តែ ការនេះកើតឡើង ដើម្បីឲ្យបានសម្រេចតាមពាក្យដែលចែងនៅក្នុងក្រឹត្យវិន័យរបស់ពួកគេថា៖
«ពួកគេស្អប់ខ្ញុំ ឥតហេតុផលឡើយ»។
26នៅពេលដែលចាត់អ្នកកម្សាន្តចិត្តមកឯអ្នករាល់គ្នាពីព្រះបិតាខ្ញុំមក ព្រះអង្គជា ព្រះវិញ្ញាណនៃសេចក្តីពិត ដែលយាងពីព្រះបិតាខ្ញុំមក ព្រះអង្គនឹងធ្វើបន្ទាល់ពីខ្ញុំ។
27អ្នករាល់គ្នាដ៏កំពុងធ្វើបន្ទាល់ពីខ្ញុំដែរ ព្រោះអ្នករាល់គ្នាបាននៅជាមួយខ្ញុំតាំងពីដំបូង។

16 1ខ្ញុំបានប្រាប់សេចក្តីទាំងនេះដល់អ្នករាល់គ្នា ដេើម្បីកុំឲ្យអ្នករាល់គ្នាវរាតចិត្ត។2ពួកគេនឹងបណ្តេញអ្នករាល់គ្នាពីសាលាប្រជុំ។ ប៉ុន្តែ នៅពេលកំណត់មកដល់
នៅពេលមនុស្សគ្រប់គ្នាដែលរកសម្លាប់អ្នករាល់គ្នា ពួកគេនឹងគិតថា ដើម្បីធ្វើជាយញ្ញបូជាថ្វាយព្រះជាម្ចាស់។
3ពួកគេធ្វើការទាំងនេះ ដោយសារពួកគេមិនបានស្គាល់ព្រះបិតាខ្ញុំ ឬស្គាល់ខ្ញុំទេ។4ខ្ញុំបានប្រាប់ការទាំងនេះដល់អ្នករាល់គ្នា ដើម្បីនៅពេលកំណត់មកដល់ អ្នកនឹងចាំថា
ខ្ញុំនិយាយពួកគេប្រាប់អ្នករាល់គ្នាហើយ។ ខ្ញុំមិនបានប្រាប់ការនេះដល់អ្នករាល់គ្នាតាំងពីដំបូងមកទេ ដោយសារខ្ញុំនៅជាមួយអ្នករាល់គ្នា។
5ប៉ុន្តែ ឥឡូវនេះ ខ្ញុំត្រឡប់ទៅព្រះអង្គដែលចាត់ខ្ញុំឲ្យមកវិញ ប៉ុន្តែ គ្មាននរណានៅក្នុងចំណោមអ្នករាល់គ្នាសួរខ្ញុំថា៖ «តើព្រះអង្គកំពុងទៅណា?»6ប៉ុន្តែ
ដោយសារខ្ញុំបាននិយាយការនេះដល់អ្នករាល់គ្នា ធ្វើឲ្យចិត្តរបស់អ្នករាល់គ្នាពេញដោយសេចក្តីព្រួយ។ ប៉ុន្តែ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើខ្ញុំទៅ
វាប្រសើរដល់អ្នករាល់គ្នា។7ដ្បិត ប្រសិនបើ ខ្ញុំមិនទៅទេ ព្រះដ៏កម្សាន្តចិត្តនឹងមិនមកទេ ប៉ុន្តែ ប្រសិនបើ ខ្ញុំទៅ ខ្ញុំនឹងចាត់ព្រះអង្គឲ្យមកសម្រាប់អ្នករាល់គ្នា។
8នៅពេលព្រះដ៏កម្សាន្តចិត្តយាងមក ព្រះអង្គបង្ហាញដល់លោកីយ៍កំហុសទាក់ទងនឹងបាប ទាក់ទងនឹងសេចក្តីសុចរិត និងទាក់ទងនឹងការជំនុំជម្រះ។9ទាក់ទងនឹងបាប
ដោយសារពួកគេមិនជឿលើខ្ញុំ10ទាក់ទងនឹងសេចក្តីសុចរិត ដោយសារខ្ញុំត្រឡប់ទៅព្រះបិតាវិញ11ហើយទាក់ទងនឹងការជំនុំជម្រះ
ដោយសារអ្នកគ្រប់គ្រងរបស់លោកីយ៍នេះនឹងត្រូវជំនុំជម្រះ។
12ខ្ញុំមានការជាច្រើនប្រាប់ដល់អ្នករាល់គ្នា ប៉ុន្តែឥឡូវនេះ អ្នករាល់គ្នាមិនយល់ពីវាទេ។13ប៉ុន្តែ នៅពេលព្រះវិញ្ញាណនៃសេចក្តីពិតយាងមក
ព្រះអង្គនឹងនាំអ្នករាល់គ្នាទៅក្នុងសេចក្តីពិតគ្រប់យ៉ាង ដ្បិតព្រះអង្គមិនបានមានបន្ទូលពីអង្គទ្រង់ផ្ទាល់ទេ។ ប៉ុន្តែ ព្រះអង្គនឹងមានបន្ទូលពីអ្វីដែលព្រះអង្គបានឮ
ហើយព្រះអង្គនឹងប្រាប់អ្នករាល់គ្នាពីអ្វីៗដែលនឹងមកដល់។14ព្រះអង្គនឹងថ្វាយសិរីល្អដល់ខ្ញុំ ព្រោះព្រះអង្គនឹងយកអ្វីដែលជារបស់ខ្ញុំ
ហើយព្រះអង្គនឹងប្រាប់ពីការនោះដល់អ្នករាល់គ្នា។
15អ្វីៗទាំងអស់ដែលព្រះបិតាមានជារបស់ខ្ញុំ។ ដូច្នេះ ខ្ញុំនិយាយថា ព្រះវិញ្ញាណនឹងទទួលអ្វីដែលជារបស់ខ្ញុំ និងព្រះអង្គនឹងប្រាប់ដល់អ្នករាល់គ្នា។
16ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ អ្នករាល់គ្នានឹងលែងឃើញខ្ញុំទៀតហើយ ហើយនៅក្នុងរយៈពេលដ៏ខ្លីខាងមុខ អ្នករាល់គ្នានឹងបានឃើញខ្ញុំម្តងទៀត។
17បន្ទាប់មក មានពួកសិស្សរបស់ព្រះអង្គខ្លះនិយាយទៅកាន់គ្នាទៅវិញទៅមកថា៖ «តើមានន័យយ៉ាងដូចម្តេច ដែលព្រះអង្គមានបន្ទូលមកហើយថា៖ «ក្នុងរយៈពេលដ៏ខ្លី
អ្នករាល់គ្នានឹងលែងឃើញខ្ញុំទៀត ហើយនៅក្នុងរយៈពេលដ៏ខ្លះខាងមុន អ្នករាល់គ្នានឹងបានឃើញខ្ញុំម្តងទៀត?» ហើយ «ដោយសារខ្ញុំទៅឯព្រះបិតាខ្ញុំវិញ?»18ដូច្នេះហើយ
បានជាពួកគេនិយាយថា៖ «តើអ្វីទៅដែលព្រះអង្គមានបន្ទូលថា៖ «ក្នុងរយៈពេលដ៏ខ្លី?» យើងមិនដឹងថា ព្រះអង្គមានបន្ទូលអំពីអ្វីទេ»។
19ព្រះយេស៊ូឃើញថា ពួកគេចង់សួរព្រះអង្គ ហើយព្រះអង្គក៏មានបន្ទូលទៅកាន់ពួកគេថា៖ «តើនេះគឺជាអ្វីដែលអ្នករាល់ក៏កំពុងតែសួរនៅក្នុងចំណោមអ្នករាល់គ្នា
តើអ្វីដែលខ្ញុំនិយាយនោះ មានន័យយ៉ាងដូចម្តេចថា៖ «ក្នុងរយៈពេលដ៏ខ្លី ហើយអ្នករាល់គ្នានឹងលែងឃើញខ្ញុំទៀត ហើយក្នុងរយៈពេលដ៏ខ្លី
អ្នករាល់គ្នាបានឃើញខ្ញុំម្តងទៀត?20ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នានឹងយំ ហើយកាន់ទុក្ខ ប៉ុន្តែ លោកីយ៍នឹងសប្បាយរីករាយ។
អ្នករាល់គ្នានឹងមានទុក្ខព្រួយយ៉ាងខ្លាំង ប៉ុន្តែ ទុក្ខព្រួយរបស់អ្នករាល់គ្នានឹងត្រឡប់ទៅជាអំណរវិញ។21នៅពេលស្ត្រីបង្កើតកូន នាងមានទុក្ខព្រួយជាខ្លាំង
ព្រោះពេលកំណត់របស់នាងមកដល់ហើយ ប៉ុន្តែ នៅពេលនាងបង្កើតកូនរួចហើយ នាងលែងនឹកចាំពីការឈឺចាប់របស់នាងទៀតហើយ
ព្រោះតែអំណរដែលនមនុស្សម្នាក់បានកើតមកក្នុងលោកីយ៍នេះ។
22ដូច្នេះ នៅពេលនេះ អ្នករាល់គ្នាមានទុក្ខព្រួយមែន ប៉ុន្តែ ខ្ញុំនឹងជួបអ្នកសារជាថ្មីម្តងទៀត ហើយដួងចិត្តរបស់អ្នកនឹងមានអំណរ
ហើយគ្មានអ្នកណាអាចយកអំណររបស់អ្នកចេញពីអ្នករាល់គ្នាឡើយ។23នៅថ្ងៃនោះ អ្នករាល់គ្នានឹងមិនសួរខ្ញុំទៀតទេ។ ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា

 generated on Fri Jun 6 10:45:59 2025

ប្រសិនបើ អ្នករាល់គ្នាសុំអ្វីពីព្រះបិតាដោយនូវឈ្មោះខ្ញុំ ព្រះអង្គនឹងប្រទានវាមកអ្នករាល់គ្នា។[24]រហូតមកទល់ពេលនេះ អ្នករាល់គ្នាមិនបានសុំអ្វីដោយនូវឈ្មោះខ្ញុំទេ។ ចូរសុំ
ហើយអ្នករាល់គ្នានឹងទទួល ដូច្នេះ អំណររបស់អ្នកនឹងបានគ្រប់លក្ខណៈ។
[25]ខ្ញុំបានប្រាប់ការទាំងនេះដល់អ្នករាល់គ្នា ក្នុងពាក្យនៃការប្រៀបធៀប ប៉ុន្តែ នៅពេលកំណត់មកដល់ ខ្ញុំនឹងលែងនិយាយជាពាក្យនៃការប្រៀបធៀបទៀតហើយ ប៉ុន្តែ
ផ្ទុយទៅវិញ ខ្ញុំប្រាប់អ្នករាល់គ្នាយ៉ាងច្បាស់អំពីព្រះបិតា។
[26]នៅថ្ងៃនោះ ខ្ញុំនឹងសុំដោយនូវឈ្មោះខ្ញុំ ហើយខ្ញុំនឹងមិននិយាយទៅកាន់អ្នកថា ខ្ញុំនឹងអធិស្ឋានដល់ព្រះបិតាសម្រាប់អ្នករាល់គ្នាសិនទេ[27]ដ្បិត
ព្រះបិតាផ្ទាល់ស្រឡាញ់អ្នករាល់គ្នា ដោយសារ អ្នករាល់គ្នាបានស្រឡាញ់ខ្ញុំ ហើយដោយសារអ្នករាល់គ្នាបានជឿថា ខ្ញុំបានមកពីព្រះបិតា។[28]ខ្ញុំបានមកពីព្រះបិតា
ហើយខ្ញុំបានមកក្នុងលោកីយ៍នេះ។ ខ្ញុំកំពុងតែចាកចេញពីលោកីយ៍នេះ ហើយខ្ញុំនឹងទៅឯព្រះបិតាវិញ។
[29]ពួកសិស្សរបស់ព្រះអង្គទូលថា៖ «មើល ឥឡូវនេះ ព្រះអង្គបានមានបន្ទូលយ៉ាងច្បាស់ ហើយព្រះអង្គមិនបានប្រើពាក្យនៃការប្រៀបធៀបទេ។[30]ឥឡូវនេះ
យើងដឹងហើយថា ព្រះអង្គជ្រាបទាំងអស់ ហើយព្រះអង្គមិនត្រូវការឲ្យនរណាសួរព្រះអង្គឡើយ។ ដោយហេតុនេះ យើងខ្ញុំជឿថា ព្រះអង្គបានមកពីព្រះជាម្ចាស់មែន»។
[31]ព្រះយេស៊ូវឆ្លើយទៅកាន់ពួកគេថា៖ «តើអ្នករាល់គ្នាជឿហើយមែនទេ?»
[32]មើល៍ ពេលកំណត់បានមកដល់ហើយ ពិតណាស់ បានមកដល់ពិតប្រាកដមែន នៅពេលដែលអ្នករាល់គ្នាត្រូវខ្ចាត់ខ្ចាយ មនុស្សគ្រប់គ្នានឹងទៅផ្ទះរបស់គេរៀងៗខ្លួន
ហើយអ្នករាល់គ្នាក៏នឹងបោះបង់ខ្ញុំចោលដែរ។ ប៉ុន្តែ ខ្ញុំមិននៅម្នាក់ឯងទេ ព្រោះព្រះបិតានៅជាមួយខ្ញុំ។[33]ខ្ញុំនិយាយការទាំងនេះដល់អ្នករាល់គ្នា
ដើម្បីឲ្យអ្នករាល់គ្នាមានសន្តិភាពនៅក្នុងខ្ញុំ។ នៅក្នុងលោកីយ៍អ្នកមានទុក្ខលំបាកជាច្រើន ប៉ុន្តែ ចូលមានសេចក្តីក្លាហាន ខ្ញុំបានឈ្នះលោកីយ៍ហើយ»។

## 17

[1]បន្ទាប់ពីព្រះេយស៊ូមានបន្ទូលពីសេចក្តីទាំងនោះរួចហើយ ព្រះអង្គបានទតព្រះនេត្រឡើងទៅលើ ឯស្ថានសួគ៌ ហើយមានបន្ទូលថា៖ «ព្រះបិតាអើយ
ពេលកំណត់បានមកដល់ហើយ សូមលើកតម្កើងព្រះបុត្រារបស់ព្រះអង្គ
ដើម្បីឲ្យព្រះបុត្រាបានលើកតម្កើងព្រះអង្គវិញ[2]ដូចដែលព្រះអង្គបានប្រទានសិទ្ធិអំណាចដល់ព្រះបុត្រាលើមនុស្សលោកទាំងអស់
ដើម្បីឲ្យទ្រង់បានប្រទានជីវិតអស់កល្បជានិច្ចដល់មនុស្សគ្រប់គ្នាដែលព្រះអង្គបានប្រទានដល់ព្រះបុត្រាដែរ។
[3]នេះជាជីវិតអស់កល្បជានិច្ច៖ គឺថាពួកគេស្គាល់ព្រះអង្គ ជាព្រះពិតតែមួយគត់ និងជឿព្រះដែលចាត់ព្រះអង្គឲ្យមក គឺព្រះយេស៊ូគ្រិស្ត។
[4]ទូលបង្គំថ្វាយសិរីល្អដល់ព្រះអង្គនៅលើផែនដីនេះ។ ទូលបង្គំបានបញ្ចប់ការងារដែលព្រះអង្គបានប្រទានឲ្យទូលបង្គំធ្វើហើយ។[5]ឥឡូវនេះ បិតាអើយ
សូមលើកតម្កើងទូលបង្គំឡើងជាមួយនឹងសិរីល្អដែលទូលបង្គំមាន នៅចំពោះមុខលោកីយ៍ដែលទ្រង់បានបង្កើត។
[6]ទូលបង្គំបានបង្ហាញព្រះនាមព្រះអង្គ ដល់អស់អ្នកដែលព្រះអង្គបានប្រទានមកទូលបង្គំនៅក្នុងលោកីយ៍នេះ។ ពួកគេជាកម្មសិទ្ធិរបស់ព្រះអង្គ
ហើយព្រះអង្គបានប្រទានទូលបង្គំឲ្យទៅពួកគេ ហើយពួកគេបានប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះអង្គ។[7]ឥឡូវនេះ ពួកគេដឹងថា អ្វីៗដែលព្រះអង្គប្រទានមកទូលបង្គំ
គឺមកពីព្រះអង្គ[8]ដ្បិត ទូលបង្គំបានឲ្យដល់ពួកគេគ្រប់គ្នានូវព្រះបន្ទូលដែលព្រះអង្គបានប្រទានមកទូលបង្គំ។ ពួកគេបានទទួលព្រះបន្ទូល ហើយបានស្គាល់យ៉ាងប្រាកដថា
ទូលបង្គំមកពីព្រះអង្គ ហើយពួកគេបានជឿថា ព្រះអង្គជាអ្នកចាត់ទូលបង្គំឲ្យមក។
[9]ទូលបង្គំអធិស្ឋានឲ្យពួកគេ។ ទូលបង្គំមិនអធិស្ឋានឲ្យលោកីយ៍ទេ ប៉ុន្តែ អធិស្ឋានដល់អស់អ្នកដែលព្រះអង្គប្រទានដល់ទូលបង្គំ ដ្បិត ពួកគេជាកម្មសិទ្ធិរបស់ព្រះអង្គ។
[10]អ្វីៗគ្រប់យ៉ាងដែលជារបស់ទូលបង្គំ ជារបស់ព្រះអង្គ ហើយអ្វីៗគ្រប់យ៉ាងដែលជារបស់ព្រះអង្គ ក៏ជារបស់ទូលបង្គំដែរ ហើយទូលបង្គំបានទទួលសិរីល្អនៅក្នុងពួកគេ។
[11]ទូលបង្គំលែងនៅក្នុងលោកីយ៍ទៀតហើយ ប៉ុន្តែ អ្នកទាំងអស់នេះ នៅក្នុងលោកីយ៍ ហើយទូលបង្គំនឹងត្រឡប់ទៅឯព្រះអង្គវិញ។ ឱបិតាដ៏វិសុទ្ធអើយ
សូមការពារពួកគេនៅក្នុងព្រះនាមព្រះអង្គ ដែលព្រះអង្គបានប្រទានមកទូលបង្គំ ដើម្បីឲ្យពួកគេបានត្រឡប់ទៅជាតែមួយ ដូចយើងបានរួមគ្នាតែមួយដែរ។
[12]អំឡុងពេល ដែលទូលបង្គំនៅជាមួយពួកគេ ទូលបង្គំបានការពារពួកគេនៅក្នុងព្រះនាមរបស់ព្រះអង្គ ដែលព្រះអង្គបានប្រទានមកទូលបង្គំ។ ទូលបង្គំការពារពួកគេ
ហើយមិនឲ្យនរណាម្នាក់ត្រូវវិនាសឡើយ លើកលែងតែកូននៃសេចក្តីវិនាសតែប៉ុណ្ណោះ ដើម្បីឲ្យបទគម្ពីរបានសម្រេច។[13]ឥឡូវនេះ ទូលបង្គំនឹងទៅឯព្រះអង្គ ប៉ុន្តែ
ទូលបង្គំប្រាប់ការទាំងអស់នេះនៅក្នុងលោកីយ៍ ដើម្បីឲ្យអំណររបស់ទូលបង្គំបានបំពេញនៅក្នុងពួកគេ។[14]ទូលបង្គំបានប្រគល់ព្រះបន្ទូលរបស់ព្រះអង្គដល់ពួកគេ
ហើយលោកីយ៍បានស្អប់ពួកគេ ដោយសារពួកគេមិនមែនចេញពីលោកីយ៍មក ដូចជាទូលបង្គំដែរ មិនបានចេញពីលោកីយ៍មកទេ។
[15]ទូលបង្គំមិនបានសុំឲ្យព្រះអង្គដកពួកគេចេញពីលោកីយ៍ទេ ប៉ុន្តែ សុំឲ្យព្រះអង្គការពារពួកគេពីការអាក្រក់គ្រប់យ៉ាង។[16]ពួកគេមិនមែនមកពីលោកីយ៍នេះទេ
ដូចជាទូលបង្គំដែរ មិនមែនមកពីលោកីយ៍នេះទេ។[17]សូមញែកពួកគេ ដោយសារសេចក្តីពិត។ ព្រះបន្ទូលរបស់ព្រះអង្គគឺជាសេចក្តីពិត។
[18]ដូចដែលព្រះអង្គបានចាត់ទូលបង្គំមកក្នុងលោកីយ៍នេះ ដើម្បីទូលបង្គំបានចាត់ពួកគេឲ្យទៅក្នុងលោកីយ៍វិញដែរ។[19]ដ្បិត ទូលបង្គំបានញែកខ្លួនឯង ដោយសារពួកគេ
ដើម្បីឲ្យពួកគេអាចត្រូវបានញែកនៅក្នុងសេចក្តីពិតដែរ។
[20]ទូលបង្គំមិនគ្រាន់តែអធិស្ឋានសម្រាប់ពួកគេទេ ប៉ុន្តែ
អធិស្ឋានដល់អស់អ្នកដែលនឹងជឿដល់ទូលបង្គំតាមរយៈពាក្យរបស់ពួកគេដែរ[21]ដើម្បីឲ្យពួកគេបានត្រឡប់ទៅជាតែមួយ ដូចជាព្រះអង្គ ព្រះបិតា នៅក្នុងទូលបង្គំ
ហើយទូលបង្គំនៅក្នុងព្រះអង្គ។ ទូលបង្គំអធិស្ឋានថា សូមឲ្យពួកគេបាននៅក្នុងយើង ដើម្បីឲ្យលោកីយ៍ជឿថា ព្រះអង្គបានចាត់ទូលបង្គំឲ្យមក។
[22]សិរីល្អដែលព្រះអង្គប្រទានដល់ទូលបង្គំ នោះទូលបង្គំបានឲ្យដល់ពួកគេហើយ ដើម្បីឲ្យពួកគេបានត្រឡប់ទៅជាតែមួយ ដូច យើងដែរ។[23]ទូលបង្គំនៅក្នុងពួកគេ
ហើយព្រះអង្គនៅក្នុងទូលបង្គំ ដើម្បីឲ្យពួកគេអាចនាំភាពរួបរួមទាំងស្រុង ដើម្បីឲ្យលោកីយ៍ដឹងថា ព្រះអង្គបានចាត់ទូលបង្គំឲ្យមក ហើយព្រះអង្គបានស្រឡាញ់ពួកគេ
ដូចព្រះអង្គបានស្រឡាញ់ទូលបង្គំដែរ។
[24]ឱព្រះបិតាអើយ ទូលបង្គំចង់ឲ្យអស់អ្នកដែលព្រះអង្គប្រទានមកទូលបង្គំ បាននៅកន្លែងដែលទូលបង្គំនៅដែរ ហើយនឹងឃើញសិរីល្អរបស់ទូលបង្គំ
គឺជាសិរីល្អរបស់ព្រះអង្គដែលបានប្រទានដល់ទូលបង្គំ ព្រោះព្រះអង្គស្រឡាញ់ទូលបង្គំ មុនលោកីយ៍បានបង្កើតមកម្ល៉េះ។
[25]ឱព្រះបិតាដ៏សុចរិតអើយ លោកីយ៍មិនស្គាល់ព្រះអង្គទេ ប៉ុន្តែ ទូលបង្គំស្គាល់ព្រះអង្គ ហើយពួកគេបានដឹងថាព្រះអង្គចាត់ទូលបង្គំឲ្យមក។
[26]ទូលបង្គំបានធ្វើឲ្យគេស្គាល់ព្រះនាមព្រះអង្គ ហើយទូលបង្គំនឹងធ្វើឲ្យគេស្គាល់ ដើម្បីឲ្យសេចក្តីស្រឡាញ់ដែលព្រះអង្គបានស្រឡាញ់ទូលបង្គំនឹងនៅក្នុងពួកគេ
ហើយទូលបង្គំនឹងនៅក្នុងពួកគេដែរ។

## 18

[1]បន្ទាប់ពីព្រះយេស៊ូមានបន្ទូលសេចក្តីទាំងនោះហើយ ព្រះអង្គបានចេញទៅជ្រលងក្រេដូនម្ខាងទៀតជាមួយពួកសិស្ស
ព្រះអង្គបានចូលទៅក្នុងសួនមួយនៅទីនោះជាមួយពួកសិស្ស។[2]លោកយូដាស ជាអ្នកដែលក្បត់ព្រះអង្គ ក៏ដឹងពីកន្លែងនោះដែរ ដ្បិត
ព្រះយេស៊ូបានយាងទៅទីនោះជាញឹកញាប់ជាមួយពួកសិស្ស។[3]បន្ទាប់មក លោកយូដាស បាននាំទាហានមួយក្រុម ហើយនិងពួកអាជ្ញាធរពីនាយកបូជាចារ្យ និងពួកផារីស៊ី
ទៅទីនោះជាមួយនឹងគោម ចន្លុះ ហើយនិងអាវុធផង។
[4]បន្ទាប់មក ព្រះយេស៊ូបានជ្រាបក្នុងគ្រប់ការទាំងអស់ថាអ្វីនឹងកើតឡើងចំពោះព្រះអង្គ ទ្រង់បានយាងទៅជួបពួកគេ ហើយមានបន្ទូលសួរថា៖
«តើអ្នករាល់គ្នាកំពុងស្វែងរកនរណា?»[5]ពួកគេទូលទៅព្រះអង្គវិញថា៖ «រកយេស៊ូ អ្នកស្រុកណាសារ៉ែត»។ ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «ខ្ញុំហ្នឹងហើយ»។
លោកយូដាស ជាអ្នកដែលក្បត់ព្រះអង្គ ក៏ឈរនៅជាមួយទាហានដែរ។
[6]នៅពេលព្រះអង្គមានបន្ទូលទៅពួកគេថា៖ «ខ្ញុំហ្នឹងហើយ» ដូច្នេះ ពួកគេក៏ផ្ងាក្រោយ ហើយដួលទៅនឹងដី។[7]បន្ទាប់មក ទ្រង់មានបន្ទូលទៅកាន់ពួកគេម្តងទៀតថា៖
«តើអ្នករាល់គ្នាស្វែងរកនរណា?» ពួកគេទូលឆ្លើយម្តងទៀតថា៖ «យេស៊ូ អ្នកស្រុកណាសារ៉ែត»។

8ព្រះយេស៊ូមានបន្ទូលឆ្លើយថា៖ «ខ្ញុំប្រាប់អ្នករាល់គ្នាហើយថា៖ «គឺខ្ញុំហ្នឹងហើយ។ ប្រសិនបើ អ្នករាល់គ្នាស្វែងរកខ្ញុំ ដូច្នេះ សូមឲ្យអ្នកទាំងអស់នេះចេញទៅ»។
9ការនេះកើតឡើង ដើម្បីឲ្យបានសម្រេចតាមព្រះបន្ទូលដែលព្រះអង្គមានបន្ទូលថា៖ «អស់អ្នកណាដែលព្រះអង្គបានប្រទានមកទូលបង្គំ គ្មានអ្នកណាបាត់បង់ឡើយ»។
10បន្ទាប់មក លោកស៊ីម៉ូនពេត្រុស ជាអ្នកដែលមានដាវ បានដក ហើយកាប់អ្នកបម្រើរបស់មហាបូជាចារ្យ ហើយបានកាត់ត្រចៀកខាងស្ដាំរបស់គាត់។
អ្នកបម្រើនោះឈ្មោះម៉ាលកុស។11ព្រះយេស៊ូទៅលោកពេត្រុសថា៖ «ដាក់ដាវទៅក្នុងស្រោមរបស់វាវិញទៅ។ តើខ្ញុំមិនផឹកពែងដែលព្រះបិតាបានប្រទានដល់ខ្ញុំទេឬអី?»
12ដូច្នេះ ក្រុមទាហាន និងមេបញ្ជាការ ព្រមទាំងអាជ្ញាធររបស់សាសន៍យូដា បានចាប់ព្រះយេស៊ូ ហើយចងព្រះអង្គ។13ពួកគេបាននាំព្រះអង្គទៅជួបលោកអេណា
ដ្បិតគាត់គឺជាឪពុកក្មេករបស់លោកកៃផាស ដែលជាមហាបូជាចារ្យនៅឆ្នាំនោះ។14លោកកៃផាសជាម្នាក់ដែលបានផ្ដល់យោបល់ទៅសាសន៍យូដាដែលគឺជាល្អ ប្រសិនបើ
ម្នាក់នះស្លាប់ជំនួសមនុស្ស។
15លោកស៊ីម៉ូនពេត្រុសបានដើរតាមព្រះយេស៊ូ ជាមួយនឹងពួកសិស្សផ្សេងទៀតដែរ។ មានសិស្សម្នាក់នោះបានស្គាល់មហាបូជាចារ្យ
ហើយគាត់បានចូលទៅឯព្រះយេស៊ូនៅទៅទីធ្លាខាងក្នុងដំណាក់របស់មហាបូជាចារ្យ ប៉ុន្តែ លោកពេត្រុសឈរនៅខាងក្រៅទ្វារ។16ដូច្នេះ សិស្សម្នាក់ទៀត
ដែលស្គាល់មហាបូជាចារ្យ បានចូលទៅ ហើយនិយាយជាមួយស្ត្រីអ្នកយាមទ្វារ ហើយគាត់បាននាំលោកពេត្រុសចូលក្នុង។
17បន្ទាប់មក ស្ត្រីបម្រើ ដែលជាអ្នកយាមទ្វារ និយាយទៅកាន់លោកពេត្រុសថា៖ «តើអ្នកក៏ជាសិស្សម្នាក់របស់បុរសនោះមែនទេ?» គាត់ឆ្លើយថា៖ «មិនមែនទេ»។
18ពួកអ្នកបម្រើ និងពួកអាជ្ញាធរកំពុងឈរនៅទីនោះ ពួកគេបង្កាត់ភ្លើងអាំង ដ្បិតពេលនោះរងារណាស់ ពួកគេបានអាំងកម្ដៅរូបកាយរបស់ពួកគេ។
លោកពេត្រុសក៏នៅជាមួយពួកគេ អាំងភ្លើង និងកម្ដៅខ្លួនពួកគេនៅទីនោះដែរ។
19បន្ទាប់មក មហាបូជាចារ្យបានសួរព្រះយេស៊ូអំពីសេចក្ដីបង្រៀនរបស់ពួកសិស្ស និងសេចក្ដីបង្រៀនរបស់ព្រះអង្គ។20ព្រះយេស៊ូបានមានបន្ទូលឆ្លើយទៅគាត់ថា៖
«ខ្ញុំបានប្រាប់ជាសាធារណៈដល់លោកីយ៍ហើយ។ ខ្ញុំតែងតែបង្រៀននៅក្នុងសាលាប្រជុំ និងនៅក្នុងព្រះវិហារ ជាកន្លែងដែលសាសន៍យូដាមកប្រជុំគ្នា។
ខ្ញុំមិនបាននិយាយអ្វីអាថ៌កំបាំងឡើយ។21ហេតុអ្វីបានជាលោកសួរខ្ញុំ? ចូរសួរអស់អ្នកដែលបានស្ដាប់ខ្ញុំពីអ្វីដែលខ្ញុំបានបង្រៀន។ មើល
អ្នកទាំងអស់នេះដឹងអ្វីដែលខ្ញុំបាននិយាយ»។
22នៅពេលព្រះយេស៊ូមានបន្ទូលការនេះហើយ អាជ្ញាធរម្នាក់ដែលឈរនៅទីនោះបានវាយព្រះយេស៊ូ ហើយនិយាយថា៖ «ឯងឆ្លើយបែបនេះ
ទៅកាន់មហាបូជាចារ្យមែនទេ?»23ព្រះយេស៊ូមានបន្ទូលឆ្លើយទៅអ្នកនោះថា៖ «ប្រសិនបើ ខ្ញុំនិយាយខុសមែន ចូរគិតពីកំហុសខ្ញុំចុះ ប៉ុន្តែ ប្រសិនបើខ្ញុំត្រូវ
ហេតុអ្វីបានជាលោកវាយខ្ញុំ?»24បន្ទាប់មកលោកអេណាបានចាត់ព្រះអង្គឲ្យទៅឯកៃផាសជាមហាបូជាចារ្យទាំងជាប់ចំណង។
25លោកស៊ីម៉ូនពេត្រុសកំពុងតែឈរ ហើយកំពុងអាំងភ្លើង។ នោះ បណ្ដាជនបានមកហើយនិយាយទៅគាត់ថា៖
«តើអ្នកមិនមែនជាសិស្សម្នាក់ក្នុងចំណោមពួកសិស្សរបស់អ្នកនោះទេឬអី?» គាត់បដិសេធ ហើយនិយាយថា៖ «ខ្ញុំមិនមែនទេ»។26អ្នកបម្រើម្នាក់របស់មហាបូជាចារ្យ
ជាញាតិរបស់បុរសម្នាក់ដែលលោកពេត្រុសបានកាត់ដាច់ត្រចៀក និយាយថា៖ «តើខ្ញុំមិនបានឃើញអ្នកនៅជាមួយអ្នកនោះនៅក្នុងសួនទេឬអី?»27បន្ទាប់មក
លោកពេត្រុសបដិសេធម្ដងទៀត ហើយរំពេចនោះមាន់ក៏រងាវ។
28បន្ទាប់មក ពួកគេបាននាំព្រះយេស៊ូពីលោកកៃផាសទៅទីស្នាក់ការកណ្ដាលរដ្ឋាភិបាល។ ពេលនោះគឺជាពេលព្រឹកព្រលឹម
ហើយពួកគេមិនបានចូលទៅទីស្នាក់ការកណ្ដាលរដ្ឋាភិបាល ព្រោះបើធ្វើដូច្នោះ ពួកគេនឹងរាប់ជាមិនស្អាត ព្រោះពួកគេបរិភោគក្នុងពិធីបុណ្យរំលង។29ដូច្នេះ
លោកពីឡាតបានចេញមកជួបពួកគេ ហើយមានប្រសាសន៍ថា៖ «តើអ្នកចោទប្រកាន់បុរសនេះរឿងអ្វី?»30ពួកគេឆ្លើយ ដោយនិយាយទៅកាន់គាត់ថា៖ «ប្រសិនបើ
បុរសនេះ មិនបានធ្វើការអាក្រក់ទេ យើងនឹងមិននាំគាត់មកប្រគល់ឲ្យលោកទេ»។
31ដូច្នេះ លោកពីឡាតមានប្រសាសន៍ទៅពួកគេថា៖ «ចូរយកគាត់ទៅខ្លួនឯងទៅ ហើយកាត់ក្ដីគាត់ស្របទៅតាមក្រឹត្យវិន័យរបស់អ្នករាល់គ្នាចុះ»។
ពួកយូដានិយាយទៅកាន់គាត់ថា៖ «វាមិនត្រឹមត្រូវតាមច្បាប់សម្រាប់យើងទេ ក្នុងការសម្លាប់អ្នកណាម្នាក់នោះ»។32ពួកគេនិយាយដូច្នេះ
ដើម្បីឲ្យព្រះបន្ទូលដែលព្រះយេស៊ូបានថ្លែងបានសម្រេច តាមសេចក្ដីដែលព្រះអង្គបានមានបន្ទូលពីការដែលព្រះអង្គត្រូវសុគតយ៉ាងណា។
33បន្ទាប់មកលោកពីឡាតបានចូលទៅក្នុងទីស្នាក់ការកណ្ដាលរដ្ឋាភិបាលម្ដងទៀត ហើយបានហៅព្រះយេស៊ូ ព្រមទាំងនិយាយទៅកាន់ព្រះអង្គថា៖
«តើលោកគឺជាមហាក្សត្ររបស់សាសន៍យូដាមែនទេ?»34ព្រះយេស៊ូឆ្លើយថា៖ «តើលោកនិយាយខ្លួនឯង ឬ អ្នកផ្សេងប្រាប់លោកពីខ្ញុំ?»35លោកពីឡាតឆ្លើយថា៖
«ខ្ញុំមិនមែនជាសាសន៍យូដាទេ តើមែនទេ? សាសន៍របស់អ្នកផ្ទាល់ ហើយនាយកបូជាចារ្យបានប្រគល់អ្នកមកខ្ញុំ។ តើអ្នកបានធ្វើអ្វី?»
36ព្រះយេស៊ូឆ្លើយថា៖ «ព្រះរាជ្យរបស់ខ្ញុំមិនមែនមកពីលោកីយ៍នេះទេ។ ប្រសិនបើរាជ្យរបស់ខ្ញុំមកពីលោកីយ៍នេះមែន នោះពួកអ្នកបម្រើរបស់ខ្ញុំមុខជាតយុទ្ធមិនខាន
ដើម្បីកុំឲ្យខ្ញុំត្រូវចាប់ប្រគល់ទៅឲ្យសាសន៍យូដាឡើយ។ ប៉ុន្តែ រាជ្យរបស់ខ្ញុំមិនមែនមកពីនេះទេ»។37បន្ទាប់ លោកពីឡាតមានប្រសាសន៍ទៅព្រះអង្គថា៖ «អ៊ីចឹង
តើលោកជាមហាក្សត្រមែនទេ?» ព្រះយេស៊ូបានឆ្លើយថា៖ «លោកនិយាយថា ខ្ញុំជាមហាក្សត្រ។ ដ្បិត ខ្ញុំកើតមកក្នុងគោលបំណងនេះឯង
ហើយគោលបំណងដែលខ្ញុំបានមកក្នុងលោកីយ៍នេះ ដើម្បីឲ្យខ្ញុំបានធ្វើបន្ទាល់ចំពោះសេចក្ដីពិតនេះ។ មនុស្សគ្រប់រូបដែលជាកម្មសិទ្ធិសេចក្ដីពិតនឹងស្ដាប់សម្លេងរបស់ខ្ញុំ។
38លោកពីឡាតមានប្រសាសន៍ទៅព្រះអង្គថា៖ «តើសេចក្ដីពិតជាអ្វី?» នៅពេលដែលគាត់បាននិយាយដូច្នេះរួចហើយ គាត់បានចេញទៅជួបពួកយូដាខាងក្រៅម្ដងទៀត
ហើយមានប្រសាសន៍ទៅពួកគេថា៖ «ខ្ញុំរកកំហុសមិនឃើញនៅក្នុងបុរសនេះទេ។39ប៉ុន្តែ អ្នករាល់គ្នាមានទម្លាប់
ខ្ញុំនឹងដោះលែងមនុស្សម្នាក់ដល់អ្នករាល់គ្នានៅថ្ងៃបុណ្យរំលងនេះ។ ដូច្នេះ តើអ្នករាល់គ្នាចង់ឲ្យខ្ញុំដោះលែងស្ដេចរបស់សាសន៍យូដាដល់អ្នករាល់គ្នាឬយ៉ាងណា?»40នោះ
ពួកគេបានស្រែកឡើង ហើយនិយាយថា៖ «មិនមែនបុរសនេះទេ ប៉ុន្តែសូមដោះលែងបារ៉ាបាសវិញ»។ លោកបារ៉ាបាសជាចោរប្លន់។

19 1បន្ទាប់មក លោកពីឡាតបានយកព្រះយេស៊ូហើយវាយព្រះអង្គនឹងខ្សែតី។2ទាហានបានពាក់មកុដបន្លា។ ពួកគេពាក់វានៅលើព្រះសិរសារបស់ព្រះយេស៊ូ
ហើយពាក់អាវពណ៌ស្វាយឲ្យព្រះអង្គ។3ពួកគេបានមករកព្រះអង្គ ហើយនិយាយថា៖ «សូមថ្វាយបង្គំ មហាក្សត្ររបស់យូដា!»។
4បន្ទាប់មក លោកពីឡាតបានចេញទៅក្រៅម្ដងទៀត ហើយមានប្រសាសន៍ទៅពួកគេថា៖ «មើល ខ្ញុំបាននាំគាត់មកឲ្យអ្នករាល់គ្នាហើយ ដើម្បីឲ្យអ្នករាល់គ្នាដឹងថា
ខ្ញុំមិនឃើញថាគាត់មានកំហុសអ្វីទេ»។5ដូច្នេះ ព្រះយេស៊ូបានចេញមក ពាក់មកុដបន្លា និងអាវផាយពណ៌ស្វាយ។ លោកពីឡាតមានប្រសាសន៍ទៅពួកគេថា៖ «មើល
នេះណែ បុរសនេះហើយ!»6នៅពេលនាយកបូជាចារ្យ និងពួកអាជ្ញាធរបានឃើញព្រះយេស៊ូ ពួកគេស្រែកឡើង ហើយនិយាយថា៖ «ឆ្កាងវាទៅ ឆ្កាងវាទៅ!»
លោកពីឡាតមានប្រសាសន៍ទៅពួកគេថា៖ «យកគាត់ទៅឆ្កាងខ្លួនឯងទៅ ដ្បិត ខ្ញុំមិនឃើញថាគាត់មានកំហុសអ្វីទេ»។
7ពួកយូដាឆ្លើយទៅគាត់ថា៖ «យើងមានច្បាប់មួយ ហើយស្របតាមច្បាប់ដែលវាត្រូវស្លាប់ ដោយសារវាបានប្រកាសថា ជាបុត្រារបស់ព្រះជាម្ចាស់»។
8នៅពេលលោកពីឡាតបានឮប្រយោគនេះ គាត់រឹតតែខ្លាចខ្លាំងឡើងថែមទៀត9ហើយគាត់បានចូលទៅក្នុងទីស្នាក់ការកណ្ដាលរដ្ឋាភិបាលវិញ
ហើយមានប្រសាសន៍ទៅព្រះយេស៊ូថា៖ «តើលោកមកពីណា?» ប៉ុន្តែ ព្រះយេស៊ូមិនបានឆ្លើយទៅគាត់ទេ។
10បន្ទាប់មក លោកពីឡាតមានប្រសាសន៍ទៅព្រះអង្គថា៖ «លោកមិននិយាយអ្វីជាមួយខ្ញុំទេឬអី? តើលោកដឹងទេថា ខ្ញុំមានអំណាចនឹងដោះលែងលោក
ហើយមានអំណាចនឹងឆ្កាងលោក?»11ព្រះយេស៊ូមានបន្ទូលឆ្លើយទៅគាត់ថា៖ «លោកគ្មានអំណាចអ្វីលើខ្ញុំទេ
លើកលែងតែអំណាចដែលបានប្រទានដល់លោកពីស្ថានសួគ៌។ ដូច្នេះហើយ អ្នកដែលប្រគល់ខ្ញុំមកឲ្យលោកជាមនុស្សមានបាបយ៉ាងធំ»។
12ពេលព្រះអង្គមានបន្ទូលឆ្លើយដូច្នេះ លោកពីឡាតចង់ដោះលែងព្រះអង្គ ប៉ុន្តែ ពួកយូដាស្រែកឡើង ហើយនិយាយថា៖ «ប្រសិនបើ លោកដោះលែងបុរសនេះ
លោកមិនមែនជាមិត្តសម្លាញ់របស់ស្ដេចសេសាឡើយ»។13អស់អ្នកណាដែលតាំងខ្លួនឯងជាស្ដេច និយាយទាស់នឹងស្ដេចសេសាហើយ»។

 generated on Fri Jun 6 10:45:59 2025

នៅពេលលោកពីឡាតឮពាក្យទាំងនេះ គាត់បាននាំព្រះយេស៊ូចេញក្រៅ ហើយអង្គុយចុះនៅលើកៅអីជំនុំជម្រះ ដែលហៅថាៈ «ទៅលានក្រាលថ្ម» ប៉ុន្តែ
នៅក្នុងភាសាហេព្រើរហៅថាៈ «កាបាថា»។
[14]ពេលនេះ គឺជាពេលនៃការរៀបចំសម្រាប់ថ្ងៃបុណ្យរំលង ប្រហែលជាម៉ោងដប់ពីរថ្ងៃត្រង់។ លោកពីឡាតមានប្រសាសន៍ទៅកាន់ពួកយូដាថាៈ «មើល៍ នេះគឺជា
ស្ដេចរបស់អ្នករាល់គ្នា»។[15]ពួកគេស្រែកឡើងថាៈ «ឆ្កាងវាទៅ! ឆ្កាងវាទៅ! ឆ្កាងវាទៅ!» លោកពីឡាតមានប្រសាសន៍ទៅពួកគេថាៈ
«តើឲ្យខ្ញុំឆ្កាងស្ដេចរបស់អ្នករាល់គ្នាមែនទេ?» នាយកបូជាចារ្យបានឆ្លើយថាៈ «យើងគ្មានស្ដេចទេ មានតែស្ដេចសេសារតែមួយគត់»។[16]នោះ
លោកពីឡាតបានប្រគល់ព្រះយេស៊ូទៅឲ្យពួកគេ ដើម្បីឆ្កាង។
[17]បន្ទាប់មក ពួកគេបាននាំព្រះយេស៊ូ ហើយព្រះអង្គបានចេញទៅក្រៅ ព្រះអង្គបានលីឈើឆ្កាងដោយព្រះអង្គផ្ទាល់ ទៅកន្លែងដែលហៅថាៈ «តំបន់លលាក្បាល» ដែល
នៅក្នុងភាសាហេព្រើរហៅថាៈ «គាល់កូថា»។[18]ពួកគេឆ្កាងព្រះយេស៊ូនៅទីនោះ ជាមួយបុរសពីរនាក់ទៀត ម្នាក់ម្ខាង ហើយព្រះយេស៊ូនៅចំកណ្ដាល។
[19]លោកពីឡាតក៏សរសេរសញ្ញា ហើយដាក់នៅលើឈើឆ្កាង។ សញ្ញានោះសរសេរថាៈ «ព្រះយេស៊ូ អ្នកស្រុកណាសារ៉ែត ស្ដេចរបស់សាសន៍យូដា»។
[20]សាសន៍យូដាជាច្រើនបានអានសញ្ញានេះ ដោយសារកន្លែងដែលព្រះយេស៊ូត្រូវឆ្កាងនោះ នៅជិតទីក្រុង។ សញ្ញានោះសរសេរជាភាសាហេព្រើរ ឡាទីន និងក្រិក។
[21]នោះ នាយកបូជាចារ្យរបស់សាសន៍យូដាមានប្រសាសន៍ទៅកាន់លោកពីឡាតថាៈ «សូមកុំសរសេរថា «ស្ដេចរបស់សាសន៍យូដាអ៊ី» ផ្ទុយទៅវិញ
ចូរសរសេរដូច្នេះវិញថាៈ «អ្នកនេះនិយាយថាៈ «ខ្ញុំគឺជាស្ដេចរបស់សាសន៍យូដា»»។[22]លោកពីឡាតឆ្លើយថាៈ «ខ្ញុំសរសេរយ៉ាងម៉េច សរសេរអ៊ីចឹងហើយ!»។
[23]នៅពេលពួកទាហានឆ្កាងព្រះយេស៊ូ ពួកគេបានយកសម្លៀកបំពាក់របស់ព្រះយេស៊ូ បែងចែកជាបួនចំណែក ចែកគ្នាម្នាក់មួយចំណែកសម្រាប់ពួកគេ
រួមទាំងអាវផងដែរ។ ហើយអាវនោះ គ្មានថ្នេរ ជាក្រណាត់មួយជុំ តាំងពីលើដល់ក្រោម។[24]បន្ទាប់មក ពួកគេនិយាយទៅកាន់គ្នាទៅវិញទៅមកថាៈ «សូមយើងកុំហែកវាអី
ប៉ុន្តែ ចូរយើងចាប់ឆ្នោតវិញ ដើម្បីសម្រេចថា តើអាវនេះនឹងបានទៅលើនរណា!»។ ការនេះកើតឡើង ដើម្បីឲ្យបានសម្រេចតាមបទគម្ពីរដែលចែងថាៈ
«ពួកគេបានបែងចែកសម្លៀកបំពាក់ទូលបង្គំនៅក្នុងចំណោមពួកគេ ហើយចាប់ឆ្នោត ដើម្បីយកសម្លៀកបំពាក់របស់ទូលបង្គំ»។ នេះគឺជាអ្វីដែលពួកទាហានបានធ្វើ។
[25]ព្រះមាតារបស់ព្រះយេស៊ូ ប្អូនស្រីមាតារបស់ព្រះអង្គ នាងម៉ារីភរិយារបស់លោកក្លូប៉ាស និងម៉ារីជាអ្នកក្រុងម៉ាក់ដាឡាកំពុងឈរនៅជិតឈើឆ្កាងរបស់ព្រះយេស៊ូ។
[26]នៅពេលព្រះយេស៊ូទតឃើញមាតារបស់ព្រះអង្គ ហើយសិស្សម្នាក់ដែលព្រះអង្គស្រឡាញ់កំពុងឈរនៅជិតនោះ ព្រះអង្គមានបន្ទូលទៅមាតារបស់ព្រះអង្គថាៈ
«អ្នកម្ដាយអើយ! មើល៍ នោះជាកូនរបស់អ្នកម្ដាយហើយ»[27]បន្ទាប់មក ព្រះអង្គមានបន្ទូលទៅសិស្សថាៈ «មើល៍! នេះជាអ្នកម្ដាយរបស់អ្នកហើយ» ចាត់ពីម៉ោងនោះមក
សិស្សរបស់ព្រះអង្គបានយកនាងទៅនៅផ្ទះរបស់គាត់ផ្ទាល់។
[28]បន្ទាប់ពីនេះ ទើបបានដឹងថាអ្វីៗបានសម្រេចហើយ ដើម្បីឲ្យបានសម្រេចតាមបទគម្ពីរ ព្រះយេស៊ូមានបន្ទូលថាៈ «ខ្ញុំស្រេកទឹក»។
[29]មានក្រឡមួយពេញដោយទឹកខ្មេះបានដាក់នៅទីនោះ ដូច្នេះ ពួកគេបានយកសារាយស្ងួតរុំនឹងមែកហ៊ីសុបជ្រលក់ទឹកខ្មេះជោក រួចហុចដល់ព្រះឱស្ឋរបស់ព្រះអង្គ។
[30]នៅពេលយេស៊ូផឹកទឹកខ្មេះនោះហើយ ព្រះអង្គមានបន្ទូលថាៈ «សម្រេចហើយ»។
[31]បន្ទាប់មក សាសន៍យូដា ដោយព្រោះថ្ងៃនោះគឺជាថ្ងៃនៃការរៀបចំ ដូច្នេះ ពួកគេបានទុកឲ្យព្រះកាយរបស់ព្រះយេស៊ូនៅលើឈើឆ្កាងនៅក្នុងថ្ងៃសប្ប័ទទេ
(ដ្បិតថ្ងៃសប្ប័ទគឺជាថ្ងៃបុណ្យធំ) ពួកគេបានសូមលោកពីឡាត ដើម្បីបំបាក់ជើងរបស់ពួកគេ ហើយយកសាកសពរបស់ពួកគេចុះមក។[32]បន្ទាប់មក ពួកទាហានបានមកដល់
ហើយបំបាក់ជើងរបស់បុរសទីមួយ និងបំពាក់ជើងបុរសទីពីរ ដែលបានឆ្កាងជាមួយព្រះយេស៊ូ។[33]នៅពេលពួកគេមកដល់ព្រះយេស៊ូ ពួកគេឃើញថា
ព្រះអង្គសុគតរួចស្រេចបាត់ទៅហើយ ដូច្នេះ ពួកគេមិនបានបំបាក់ជើងរបស់ព្រះអង្គទេ។
[34]ប៉ុន្តែ មានទាហានម្នាក់បានចាក់ចំហៀងខ្លួនរបស់ព្រះអង្គជាមួយនឹងលំពែង ហើយរំពេចនោះឈាម និងទឹកបានហូរចេញមក។[35]ម្នាក់ដែលបានឃើញការនេះ
បានធ្វើបន្ទាល់ ហើយទីបន្ទាល់របស់គាត់គឺជាការពិត។ គាត់ដឹងថា អ្វីដែលគាត់និយាយគឺជាការពិត ដើម្បីឲ្យអ្នករាល់គ្នាអាចជឿដែរ។
[36]ដ្បិត ការទាំងអស់នេះ បានកើតឡើង ដើម្បីឲ្យបានសម្រេចតាមបទគម្ពីរថាៈ «គ្មានឆ្អឹងណាមួយរបស់ព្រះអង្គត្រូវបានបាក់ឡើយ»។
[37]ក៏មានបទគម្ពីរផ្សេងទៀតបានចែងថាៈ «ពួកគេសម្លឹងមើលព្រះអង្គដែលត្រូវគេចាក់ទម្លុះ»។
[38]បន្ទាប់ពីការទាំងនេះហើយ លោកយ៉ូសែប អ្នកស្រុកអើរីម៉ាថេ គាត់ក៏ជាសិស្សម្នាក់របស់ព្រះយេស៊ូដែរ (ដោយសារខ្លាចពួកយូដា
គាត់មិនបង្ហាញថាជាសិស្សរបស់ព្រះអង្គទេ) បានសូមលោកពីឡាត ដើម្បីគាត់អាចនឹងយកព្រះសពរបស់ព្រះយេស៊ូបានឬអត់។
[39]លោកពីឡាតបានផ្ដល់ការអនុញ្ញាតឲ្យគាត់។ ដូច្នេះ លោកយ៉ូសែបបានមក ហើយយកព្រះសពរបស់ព្រះអង្គទៅ។ លោកនីកូដេមក៏បានមកដែរ
គាត់គឺជាម្នាក់ដែលបានមករកព្រះយេស៊ូនៅពេលយប់មុនគេ។ គាត់បានយកជ័រល្វីងទេសលាយជាមួយគ្រឿងក្រអូប ប្រហែលជាហាសិបគីឡូក្រាម។
[40]ដូច្នេះ ពួកគេបានយកព្រះកាយរបស់ព្រះយេស៊ូ ហើយបានរុំព្រះកាយនោះនឹងក្រណាត់សរមួយជុំ ដូចទម្លាប់របស់សាសន៍យូដា ដើម្បីបញ្ចុះសព។
[41]នៅកន្លែងដែលគេឆ្កាងព្រះអង្គនោះ មានសួនមួយ ហើយនៅក្នុងសួននោះមានផ្នូរថ្មីមួយដែលគ្មាននរណាយកសពមកដាក់នៅឡើយទេ។
[42]ដោយសារថ្ងៃនោះជាថ្ងៃរៀបចំរបស់សាសន៍យូដា ហើយដោយសារផ្នូរនោះនៅជិតផង ពួកគេបានបញ្ចុះព្រះយេស៊ូនៅទីនោះទៅ។

20 [1]នៅព្រឹកព្រលឹមនៅថ្ងៃទីមួយនៃសប្ដាហ៍ កាលនៅងងឹតនៅឡើយ នាងម៉ារី អ្នកស្រុកម៉ាដាឡា បានមកឯផ្នូរ ហើយឃើញថ្មដែលបិទផ្នូរចំហរពីផ្នូរ។[2]ដូច្នេះ នាងក៏រត់
ហើយទៅរកលោកស៊ីម៉ូនពេត្រុស ហើយទៅរកសិស្សម្នាក់ទៀតដែលស្រឡាញ់ព្រះអង្គ ហើយនាងនិយាយទៅកាន់ពួកគេថាៈ
«ពួកគេយកព្រះអម្ចាស់ពីផ្នូរទៅបាត់ហើយ យើងមិនដឹងថាពួកគេយកព្រះអង្គទៅដាក់នៅទីណាទេ»។
[3]នោះ លោកពេត្រុស និងសិស្សម្នាក់ទៀតបានចេញទៅ ហើយពួកគេបានទៅដល់ផ្នូរ។[4]ពួកគេទាំងពីរបានរត់ជាមួយគ្នា
ហើយសិស្សម្នាក់ទៀតរត់លឿនជាងទៅមុខលោកពេត្រុស ហើយបាននៅដល់ផ្នូរមុន។[5]បន្ទាប់មក ឱនមើល គាត់បានឃើញក្រណាត់សរនៅទីនោះ ប៉ុន្តែ
គាត់មិនបានចូលទៅខាងក្នុងទេ។
[6]បន្ទាប់មកលោកស៊ីម៉ូនពេត្រុសក៏មកដល់ ហើយបានចូលទៅក្នុងផ្នូរ។ គាត់ក៏បានឃើញក្រណាត់សរនៅទីនោះដែរ។
និងជាក្រណាត់ដែលនៅលើព្រះសិរសារបស់ព្រះអង្គ។[7]ក្រណាត់នោះបាននៅជាមួយនឹងក្រណាត់សម្លៀកបំពាក់ ប៉ុន្តែ រមូរនៅកន្លែងមួយដោយឡែក។
[8]បន្ទាប់មក សិស្សម្នាក់ទៀត ម្នាក់ដែលមកដល់ផ្នូរមុនគេ ក៏ចូលទៅក្នុងដែរ ហើយគាត់បានឃើញ ហើយក៏ជឿ។[9]ដ្បិត រហូតមកដល់ពេលនេះ ពួកគេនៅតែមិនដឹងបទគ
ម្ពីរដែលថា ព្រះអង្គនឹងរស់ពីស្លាប់ឡើងវិញ។[10]ដូច្នេះ ពួកសិស្សក៏ត្រឡប់ទៅផ្ទះវិញ។
[11]ប៉ុន្តែ នាងម៉ារីដែលកំពុងឈរយំនៅខាងក្រៅផ្នូរ។ ក្នុងកាលដែលនាងកំពុងនៅយំនៅឡើយ នាងបានឈ្ងោកមើលទៅក្នុងផ្នូរ។
[12]នាងបានឃើញទេវតាពីរនាក់ក្នុងសម្លៀកបំពាក់សអង្គុយនៅទីនោះ ម្នាក់អង្គុយនៅខាងក្បាល ម្នាក់ទៀតអង្គុយនៅខាងចុងជើង នៅកន្លែងដែលគេបានដាក់ព្រះយេស៊ូ។
[13]ពួកគេបាននិយាយទៅនាងថាៈ «នាងអើយ ហេតុអ្វីបានជានាងយំ?» នាងឆ្លើយទៅពួកគេថាៈ «ដោយសារគេយកព្រះជាម្ចាស់របស់ខ្ញុំម្ចាស់ទៅបាត់ហើយ
ហើយខ្ញុំមិនដឹងថា ពួកគេយកព្រះអង្គទៅដាក់នៅទីណាទេ»។
[14]នៅពេលនាងឃើញការនេះ នាងបានបែរក្រោយ ហើយឃើញព្រះយេស៊ូកំពុងឈរនៅទីនោះ ប៉ុន្តែ នាងមិនស្គាល់ថា ជាព្រះយេស៊ូទេ។[15]ព្រះយេស៊ូមានបន្ទូលទៅនាងថាៈ
«នាងអើយ ហេតុអ្វីបានជានាងយំដូច្នេះ? តើនាងកំពុងស្វែងរកនរណា?» នាងស្មានថា ព្រះអង្គជាអ្នកថែសួន ដូច្នេះ នាងបានទូលឆ្លើយទៅព្រះអង្គថាៈ «លោកអើយ
ប្រសិនបើ លោកបានយកព្រះអង្គទៅ សូមប្រាប់ខ្ញុំផងថា លោកទុកព្រះអង្គនៅទីណា ខ្ញុំនឹងទៅយកព្រះអង្គ»។
[16]ព្រះយេស៊ូមានបន្ទូលទៅនាងថាៈ «ម៉ារីអើយ»។ នាងបានបែរមករក ហើយឆ្លើយទៅព្រះអង្គវិញជាភាសាហេព្រើរថាៈ «រ៉ាប៊ូនី» ប្រែថា (លោកគ្រូ)។
[17]ព្រះយេស៊ូមានបន្ទូលទៅនាងថាៈ «កុំប៉ះខ្ញុំអី ដើម្បីខ្ញុំមិនទាន់ឡើងទៅព្រះបិតាខ្ញុំនៅឡើយទេ ប៉ុន្តែ ខ្ញុំនឹងទៅបងប្អូនខ្ញុំ ហើយនិយាយទៅកាន់ពួកគេថា

ខ្ញុំនឹងឡើងទៅឯព្រះបិតារបស់ខ្ញុំ និងជាបិតារបស់អ្នក ហើយព្រះជាម្ចាស់របស់ខ្ញុំ និងជាព្រះជាម្ចាស់របស់អ្នកដែរ»។[18]នាងម៉ារីអ្នកស្រុកម៉ាដាឡាបានមក
ហើយប្រាប់ដល់ពួកសិស្សថា៖ «ខ្ញុំបានឃើញព្រះអម្ចាស់» ហើយប្រាប់ថា ព្រះអង្គមានបន្ទូលសេចក្ដីទាំងនេះមកនាង។
[19]នៅពេលល្ងាច ថ្ងៃនោះ គឺជាថ្ងៃទីមួយនៃសប្ដាហ៍ ទ្វារផ្ទះដែលពួកសិស្សនៅបានបិទ ព្រោះខ្លាចពួកយូដា ព្រះយេស៊ូបានយាងចូល ហើយឈរនៅក្នុងចំកណ្ដាលពួកគេ
ហើយមានបន្ទូលទៅពួកគេថា៖ «សូមឲ្យអ្នករាល់គ្នាប្រកបដោយសេចក្ដីសុខសាន្ត»។[20]បន្ទាប់ពីព្រះអង្គមានបន្ទូលរួចហើយ
ព្រះអង្គបានបង្ហាញព្រះហស្តរបស់ព្រះអង្គដល់ពួកគេ និងចំហៀងខ្លួនរបស់ព្រះអង្គដែរ។ ពួកសិស្សមានអំណរ នៅពេលពួកគេបានឃើញព្រះអម្ចាស់។
[21]បន្ទាប់មក ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត។ ព្រះបិតាបានចាត់ខ្ញុំឲ្យមកយ៉ាងណា
ខ្ញុំក៏ចាត់អ្នករាល់ឲ្យចេញទៅយ៉ាងនោះដែរ»។[22]នៅពេលព្រះយេស៊ូមានបន្ទូលរួចហើយ ព្រះអង្គបានផ្លុំខ្យល់ដង្ហើមលើពួកគេ ហើយមានបន្ទូលទៅពួកគេថា៖
«ចូរទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។[23]ប្រសិនបើ អ្នករាល់គ្នាអត់ទោសឲ្យអ្នកណា ពួកគេនឹងបានទទួលការអត់ទោស តែប្រសិនបើ អ្នករាល់គ្នាមិនអត់ទោសទេ
ពួកគេក៏មិនអាចទទួលការអត់ទោសដែរ»។
[24]លោកថូម៉ាស ជាម្នាក់នៃសិស្សទាំងដប់ពីរ ហៅថា ឌីឌីមមិនបាននៅជាមួយពួកគេ នៅពេលព្រះយេស៊ូយាងមក។[25]ក្រោយមក
មានសិស្សម្នាក់ទៀតទូលទៅកាន់ព្រះអង្គថា៖ «យើងបានឃើញព្រះអម្ចាស់»។ គាត់និយាយទៅកាន់ពួកគេថា៖ «ប្រសិនបើ ខ្ញុំមិនឃើញព្រះហស្តដែលដំដោយដែកគោល
ហើយដាក់ម្រាមដៃទៅប៉ះចំហៀងខ្លួនរបស់ព្រះអង្គនោះទេ ខ្ញុំនឹងមិនជឿទេ»។
[26]ប្រាំបីថ្ងៃក្រោយមក ពួកសិស្សរបស់ព្រះអង្គនៅខាងក្នុងផ្ទះម្ដងទៀត ហើយលោកថូមាសបាននៅជាមួយពួកគេដែរ។ ព្រះយេស៊ូបានយាងមក
ក្នុងពេលដែលទ្វារបានបិទនៅឡើយ ហើយគង់នៅក្នុងកណ្ដាលចំណោមពួកគេ ហើយមានបន្ទូលថា៖ «សូមឲ្យអ្នករាល់គ្នាប្រកបដោយសេចក្ដីសុខសាន្ត»។[27]បន្ទាប់មក
ព្រះអង្គមានបន្ទូលទៅលោកថូម៉ាសថា៖ «ចូរយកម្រាមដៃរបស់អ្នកមកដាក់នៅត្រង់នេះ ហើយមើលដៃខ្ញុំចុះ។ ចូរហុចដៃរបស់អ្នកមកត្រង់នេះ
ហើយដាក់វាចូរមកក្នុងចំហៀងខ្លួនរបស់ខ្ញុំចុះ។ ចូរជឿ កុំធ្វើជាអ្នកមិនជឿឡើយ»។
[28]លោកថូម៉ាសបានឆ្លើយ ហើយទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់របស់ខ្ញុំ ព្រះជាម្ចាស់របស់ខ្ញុំ»។[29]ព្រះយេស៊ូមានបន្ទូលទៅកាន់គាត់ថា៖ «អ្នកជឿ
ដោយសារអ្នកបានឃើញខ្ញុំ។ មានពរហើយ អស់អ្នកណាដែលជឿ ដោយមើលមិនឃើញ»។
[30]ព្រះយេស៊ូបានធ្វើទីសម្គាល់ជាច្រើន នៅក្នុងចំណោមពួកសិស្ស ទីសម្គាល់ជាច្រើនទៀតដែលបានសរសេរនៅក្នុងសៀវភៅនេះ[31]ប៉ុន្តែ ទីសម្គាល់ដែលបានកត់ត្រាទាំងនោះ
ដើម្បីឲ្យអ្នករាល់គ្នាបានជឿថា ព្រះយេស៊ូគឺជាព្រះគ្រិស្ត ជាព្រះបុត្រារបស់ព្រះជាម្ចាស់ និងដើម្បីឲ្យអ្នករាល់គ្នាបានជឿ ហើយដើម្បីឲ្យអ្នកមានជីវិតនៅក្នុងព្រះនាមព្រះអង្គ។

21 [1]បន្ទាប់ពីការទាំងនេះមក ព្រះយេស៊ូបានបង្ហាញអង្គទ្រង់ម្ដងទៀតដល់ពួកសិស្សនៅសមុទ្រទីបេរាស ។
នេះគឺជារបៀបដែលព្រះអង្គបង្ហាញអង្គទ្រង់៖[2]លោកស៊ីម៉ូនពេត្រុសបាននៅជាមួយនឹងលោកថូម៉ាស ដែលហៅថា ឌីឌីម លោកណាថានណែលជាអ្នកភូមិកាណា
ស្រុកកាលីឡេ ត្រូវជាកូនប្រុសរបស់លោកបេសេដេ និងសិស្សរបស់ព្រះយេស៊ូពីរនាក់ទៀត។[3]លោកស៊ីម៉ូនពេត្រុសនិយាយទៅកាន់ពួកគេថា៖ «ខ្ញុំទៅរកត្រីហើយ»។
ពួកគេនិយាយទៅកាន់គាត់ថា៖ «យើងក៏ទៅរកត្រីជាមួយអ្នកដែរ»។ ពួកគេក៏ចេញទៅ ហើយឡើងទៅលើទូក ប៉ុន្តែ ពួកគេរកត្រីពេញមួយយប់មិនបានត្រីសោះ។
[4]នៅពេលព្រឹកព្រលឹម ព្រះយេស៊ូបានគង់នៅមាត់សមុទ្រ ប៉ុន្តែ ពួកសិស្សមិនបានដឹងថា ជាព្រះយេស៊ូទេ។[5]ដូច្នេះ ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «អ្នកកម្លោះអើយ
តើមានអ្វីបរិភោគទេ?» ពួកគេបានទូលឆ្លើយទៅកាន់ព្រះអង្គថា៖ «អត់មានទេ»។[6]ទ្រង់មានបន្ទូលទៅពួកគេថា៖ «ចូរទំលាក់អួននៅខាងស្ដាំទូកវិញ ហើយនឹងរកត្រីបាន»។
ដូច្នេះ ពួកគេក៏ទំលាក់អួនរបស់ពួកគេ ហើយមិនអាចទាញអួនមកវិញបានទេ ដោយសារតែជាប់ត្រីច្រើនពេក។
[7]បន្ទាប់មក សិស្សដែលព្រះអង្គស្រឡាញ់បាននិយាយទៅកាន់លោកពេត្រុសថា៖ «គាត់ជាព្រះអម្ចាស់»។ ពេលលោកស៊ីម៉ូនពេត្រុសឮថា ជាព្រះអម្ចាស់ដូច្នោះ
គាត់បានដោះអាវខាងក្រៅរបស់គាត់ចេញ (គាត់មិនបានស្លៀកពាក់ទេ) ហើយក៏លោតចូលទៅក្នុងសមុទ្រ។[8]មានពួកសិស្សផ្សេងទៀតបានមកឯទូក (ដ្បិត
ពួកគេនៅមិនឆ្ងាយពីច្រាំងប៉ុន្មានទេ ប្រហែលជាពីររយម៉ែត្រប៉ុណ្ណោះ ហើយពួកគេបានទាញអួនដែលមានសុទ្ធតែត្រី។[9]នៅពេលពួកគេមកដល់ច្រាំងហើយ
ពួកគេបានឃើញរងើកភ្លើង មានត្រីអាំងនៅពីលើ ជាមួយនឹងនំប៉័ងផង។
[10]ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «ចូរយកត្រីដែលអ្នករាល់គ្នាចាប់បានខ្លះមក!»។[11]លោកស៊ីម៉ូនពេត្រុសក្រោកឡើង ហើយទៅទាញអួនមកលើដីដែលមានត្រីជាច្រើន
១៥៣។ មានត្រីជាច្រើន ប៉ុន្តែ អួនមិនបានរហែកទេ។
[12]ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «មក បរិភោគអាហារពេលព្រឹក»។ គ្មាននរណាម្នាក់ហ៊ានសួរព្រះអង្គថា៖ «តើលោកជានរណា?»។ ពួកគេដឹងថា
ព្រះអង្គជាព្រះអម្ចាស់។[13]ព្រះយេស៊ូមកដល់ ហើយកាច់នំប៉័ង ហើយប្រទានទៅពួកគេ ព្រមទាំងត្រីផង។[14]នេះគឺជាលើកទីបីហើយ
ដែលព្រះយេស៊ូបានបង្ហាញអង្គទ្រង់ដល់ពួកសិស្ស បន្ទាប់ពីទ្រង់រស់ពីស្លាប់ឡើងវិញ។
[15]បន្ទាប់ពីពួកគេបានបរិភោគអាហារពេលព្រឹករួចហើយ ព្រះយេស៊ូមានបន្ទូលទៅលោកស៊ីម៉ូនពេត្រុសថា៖ «ស៊ីម៉ូនកូនលោកយ៉ូហានអើយ
តើអ្នកស្រឡាញ់ខ្ញុំច្រើនជាងរបស់ទាំងនេះឬទេ?» លោកពេត្រុសទូលឆ្លើយទៅព្រះអង្គថា៖ «ក្រាបទូលព្រះអម្ចាស់ ព្រះអង្គជ្រាបហើយថា
ទូលបង្គំស្រឡាញ់ព្រះអង្គហើយ»។[16]ព្រះយេស៊ូមានបន្ទូលទៅគាត់ជាលើកទីពីរទៀតថា៖ «ស៊ីម៉ូន កូនលោកយ៉ូហានអើយ តើអ្នកស្រឡាញ់ខ្ញុំឬទេ?»
លោកពេត្រុសទូលឆ្លើយទៅព្រះអង្គថា៖ «ក្រាបទូល ព្រះអម្ចាស់ ព្រះអង្គជ្រាបហើយថា ទូលបង្គំស្រឡាញ់ព្រះអង្គ»។ ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖
«ចូរមើលថែចៀមខ្ញុំ»។
[17]ព្រះអង្គមានបន្ទូលទៅគាត់ជាលើកទីបីថា៖ «ស៊ីម៉ូន កូនលោកយ៉ូហានអើយ តើអ្នកស្រឡាញ់ខ្ញុំឬទេ?» លោកពេត្រុសព្រួយចិត្ត
ដោយសារព្រះយេស៊ូបានសួរគាត់ជាលើកទីបីថា៖ «តើអ្នកស្រឡាញ់ខ្ញុំឬទេ?» គាត់ទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់ ព្រះអង្គជ្រាបគ្រប់យ៉ាង ព្រះអង្គជ្រាបថា
ទូលបង្គំស្រឡាញ់ព្រះអង្គហើយ»។ ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «ចូរឲ្យចំណីចៀមខ្ញុំផង»។[18]ពិតណាស់ ខ្ញុំប្រាប់អ្នកជាប្រាកដថា នៅពេលអ្នកនៅក្មេង
អ្នកស្លៀកពាក់ខ្លួនអ្នក ហើយដើរតាមតែចិត្តអ្នកចង់ ប៉ុន្តែ នៅពេលអ្នកចាស់ អ្នកនឹងបោះដៃរបស់អ្នក ហើយអ្នកម្នាក់ផ្សេងទៀតនឹងស្លៀកពាក់ឲ្យអ្នក
ហើយនាំអ្នកទៅកន្លែងដែលអ្នកមិនចង់ទៅ»។
[19]ព្រះយេស៊ូមានបន្ទូលដូច្នេះ ដើម្បីបង្ហាញពីការដែលលោកពេត្រុសត្រូវស្លាប់ជាយ៉ាងណា ក្នុងការថ្វាយសិរីល្អដល់ព្រះ។ បន្ទាប់មក ព្រះអង្គមានបន្ទូលការនេះរួចហើយ
ព្រះអង្គមានបន្ទូលទៅលោកពេត្រុសថា៖ «ចូរដើរតាមខ្ញុំ!»។
[20]លោកពេត្រុសមើលជុំវិញ ហើយឃើញសិស្សម្នាក់ដែលព្រះយេស៊ូស្រឡាញ់ ដើរតាមពួកគេ ម្នាក់ដែលគាត់ផ្អែកខ្លួននៅលើព្រះយេស៊ូនៅអាហារពេលល្ងាច
និងជាអ្នកដែលសួរព្រះអង្គថា៖ «ព្រះអម្ចាស់អើយ តើនរណានឹងក្បត់ព្រះអង្គ?»[21]ពេត្រុសឃើញគាត់ ហើយបន្ទាប់មកទូលទៅព្រះយេស៊ូថា៖ «ព្រះអម្ចាស់អើយ
តើបុរសនេះនឹងធ្វើអ្វី?»
[22]ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «ប្រសិនបើ ខ្ញុំចង់ឲ្យគាត់នៅ រហូតទាល់តែខ្ញុំមកវិញ គ្មានអ្វីទាក់ទងជាមួយអ្នកទេ? ចូរតាមខ្ញុំមក!»។[23]ប្រយោគនេះ
បានរីកសាយភាយនៅក្នុងចំណោមបងប្អូន ថាសិស្សម្នាក់នោះនឹងមិនស្លាប់ទេ។ លើសពីនេះទៀត ព្រះយេស៊ូមិនបានមានបន្ទូលទៅលោកពេត្រុសថា សិស្សផ្សេងៗទៀត
មិនស្លាប់ទេ ប៉ុន្តែ «ប្រសិនបើ ព្រះអង្គចង់ឲ្យគាត់នៅ រហូតទាល់តែព្រះអង្គយាងមក គ្មានអ្វីទាក់ទងជាមួយគាត់ទេ»។
[24]ពួកសិស្សរបស់ព្រះអង្គបានធ្វើបន្ទាល់សេចក្ដីទាំងនេះឯង ហើយបានកត់ត្រាសេចក្ដីទាំងនេះ ហើយយើងដឹងថា ទីបន្ទាល់របស់ពួកគេគឺជាសេចក្ដីពិត។
[25]មានការជាច្រើនទៀតផងដែរ ដែលព្រះយេស៊ូបានធ្វើ។ ប្រសិនបើ កត់ត្រាសេចក្ដីទាំងអស់ តាមដែលបានឃើញនោះ
សូម្បីតែលោកីយ៍ទាំងមូលក៏មានអាចទុកសៀវភៅនោះបានផង។


generated on Fri Jun 6 10:45:59 2025